# កិច្ចសម្ភាសរបស់អ៊ុំម៉ា ធៀង

កៈ អ្នកសម្ភាសឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ ម៉ា ធៀង

គៈ ឡេង ធារី

កៈ ចាសអ៊ុំជាដំបូងសូមជម្រាបសួរអ៊ុំ!

ខៈ ចាស! លើកដៃថ្វាយព្រះក្មួយ!

កៈ ចាស! អរគុណច្រើនអ៊ុំហើយថ្ងៃនេះខ្ញុំមានឱកាសដើម្បីនឹងមកសម្ភាសដល់អ៊ុំផ្ទាល់ហើយ ខ្ញុំអឺ... ធ្វើការងារស្ម័គ្រចិត្តនៅក្នុងគម្រោងរបស់ខាងសាលាBYU នៅខាងសហរដ្ឋអាមេរិក ហើយគម្រោងរបស់ខាងសាលាមួយហ្នឹងគេបានតម្រូវឱ្យសម្ភាសប្រជាជនកម្ពុជាដែលមានវ័យចាប់ពី៣៥ឆ្នាំឡើង នូវពង្សប្រវិត្តរបស់គាត់ នូវបទពិសោធន៍កាលពីមុន រហូតមកដល់ពេលឥឡូវហ្នឹង គាត់បានឆ្លងកាត់បទពិសោធន៍អ្វីគេខ្លះដើម្បីគេយកទៅចង់ក្រងនូវឯកសារទុកឱ្យកូនចៅជំនាន់ក្រោយទៀតគេបានស្ដាប់។

ខៈ ចាស!

កៈ ចាស ចឹងថ្ងៃនេះខ្ញុំមានឱកាសដើម្បីនឹងមកសម្ភាសដ៏អ៊ុំផ្ទាល់ចឹង តើអ៊ុំអនុញ្ញាតឱ្យខ្ញុំធ្វើការសម្ភាសដ៏អ៊ុំដែរឬទេ?

ខៈ មានទៅអីអូន សម្ភាសក៏សម្ភាសទៅ។

កៈ ចាស! ចឹងថ្ងៃនេះគឺជាថ្ងៃទី៥ខែ៧ឆ្នាំ២០១៨។

ខៈ ចាស!

កៈ ចាស! ហើយចឹងការសម្ភាសជាដំបូងហ្នឹង ខ្ញុំសូមសួរឈ្មោះអ៊ុំវិញ តើអ៊ុំមានឈ្មោះអ្វីដែរ?

ខៈ ខ្ញុំមានឈ្មោះថា ម៉ា ធៀង។

កៈ ចាសអ៊ុំ! ហើយចឹងឈ្មោះនឹងត្រូវជាមួយនឹងអត្តសញ្ញាប័ត្រទាំងនាមត្រកូលអីហ្នឹងហ្ន៎?

ខៈ ចាស! ហ្នឹងហើយ។ ខ្ញុំមានឈ្មោះថា ម៉ាធៀងនៅក្នុងអត្តសញ្ញាប័ត្រហ្នឹងតែម្ដងគឺមានឈ្មោះថាចឹង។

កៈ ចាស! ហើយទៅចឹងអ៊ុំមានអត្តសញ្ញាប័ត្រដើម្បីឱ្យខ្ញុំសូមថតបានទេអ៊ុំ?

ខៈ ហឺ! អត្តសញ្ញាប័ត្រហ្នឹង ខ្ញុំមិនបានដឹងថានៅឯទីណានោះទេមីអូនហ្នាំ។

កៈ ចាស! ហើយចុះអ៊ុំអាយុប៉ុន្មានហើយឆ្នាំហ្នឹងអ៊ុំ?

ខៈ ខ្ញុំមានអាយុ៦៨ឆ្នាំ។

កៈ អ៊ុំបានកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរទៅអ៊ុំ?

ខៈ កើតនៅថ្ងៃខែឆ្នាំ១៩៥០ ខែវិច្ឆិកា ឆ្នាំ១៩៥០ហ្នឹង។

កៈ ថ្ងៃទីប៉ុន្មានដែរទៅអ៊ុំ?

ខៈ អ៊ូ! ថ្ងៃទី១៦។

កៈ ចាស! ថ្ងៃទី១៦ ចុះអ៊ុំបើសិនជាថ្ងៃខែឆ្នាំខ្មែររបស់យើងដូចជាឆ្នាំចន្ទគតិនិងសុរិយគតិដែលត្រូវជាឆ្នាំសត្វវិញនោះអ៊ុំ?

ខៈ អឺនៅក្នុងខែវិច្ឆិកា គឺខ្មែរយើងហ្នឹងគឺជាខែលំហើយហ្មែស? ខែវិច្ឆិកាហ្នឹង វាមិនមានដឹងថានៅថ្ងៃណា...

កៈ អ៊ុំដូចថាជាឆ្នាំសត្វដូចជាឆ្នាំឆ្លូវខាល ថោះអីនោះអ៊ុំ?

ខៈ អ៊ូចាស! ឆ្នាំខ្ញុំឆ្នាំថោះ។

កៈ អ៊ូ! អ៊ុំកើតនៅឆ្នាំថោះណអ៊ុំ?

ខៈ ចាស! ចាសខ្ញុំកើតនៅក្នុងឆ្នាំថោះ។

កៈ ចាស!ហើយចុះអ៊ុំបានកើតនៅក្នុងស្រុកកំណើតនៅឯណាដែរ?

ខៈ ចាស! ស្រុកកំណើតរបស់ខ្ញុំហ្នឹងគឺនៅឯអឺ....នៅឯភូមិព្រៃកគី ស្រុកស្វាយទាប ខេត្តស្វាយរៀង។

កៈ ចាសអ៊ុំ! ហើយអឺ..ឥឡូវហ្នឹងអ៊ុំមានទីលំនៅ នៅឯណាដែរទៅអ៊ុំ?

ខៈ ចាស! បច្ចុប្បន្នខ្ញុំនៅផ្ទះ៧២K អឺ....៧២Kនៅផ្លូវលំ ផ្លូវទឹកថ្លា សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ។

កៈ ចាស! ហើយទៅអ៊ុំធ្លាប់មានទីលំនៅផ្សេងពីនឹងដែរឬទេអ៊ុំ?

ខៈ អូ..មានពីមុនដែលនៅក្នុងផ្លូវកម្ពុជាក្រោមហើយទៅខ្ញុំបានប្តូរមកនៅឯទីហ្នឹងហ្នាំ។

កៈ ចាស! ចឹងមានន័យថាអ៊ុំបានផ្លាស់ទីលំនៅបាន២ដងហើយ?

ខៈ ចាស។! កាលមុននៅផ្លូវកម្ពុជាក្រោមវាចង្អៀតពេកក៏បានប្តូរទីលំនៅមកនៅឯទីនេះមកឱ្យវារាងបានស្រឡះបន្តិច។

កៈ ចាសអ៊ុំ! ហើយចុះឪពុកម្តាយរបស់អ៊ុំគាត់មានឈ្មោះអ្វីដែរ?

ខៈ អូ! ឪពុកម្តាយរបស់ខ្ញុំគាត់បានស្លាប់អស់ទៅហើយ តែថាឪពុករបស់ខ្ញុំគាត់មានឈ្មោះថា ម៉ា ហឹម ចំណែកឯម្តាយរបស់ខ្ញុំវិញនឹងគាត់មានឈ្មោះថា គៀប ឈុន។

កៈ ចាស!ហើយចុះអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរទៅអ៊ុំ?

ខៈ ចាស! បងប្អូនមានចំនួន៧នាក់ ប៉ុន្តែគាត់បានស្លាប់នៅក្នុងសម័យសង្គ្រាមអស់២នាក់នៅសល់ស្រីបាន៥នាក់ហើយប្រុស។ស្លាប់អស់ទៅហើយគាត់ជាគ្រូបង្រៀនហើយអឺ...មួយនាក់ទៀតហ្នឹគាត់បានធ្វើជាទាហានហ្នាំ។ គាត់បានស្លាប់នៅក្នុងសម័យប៉ុលពតហ្នឹង ព្រោះអីកាលហ្នឹងអាពពតគេបានយកគាត់នឹងទៅវៃចោល ព្រោះអីគាត់នឹងជាអ្នកចេះដឹងចឹង។

កៈ ចាស! កាលនឹងសោកស្តាយមែនទែនអ៊ុំ! ហើយចុះបងប្អូនរបស់អ៊ុំស្រីនិងប្រុសមានប៉ុន្មាននាក់ដែរ?

ខៈ ចាស! ស្រីនិងប្រុស៧នាក់ ស្រី៥នាក់ហើយប្រុស២នាក់។

កៈ ចាស! ហើយចឹងពួកគាត់មានឈ្មោះអ្វីគេខ្លះទៅអ៊ុំ?

ខៈ អូ! បងប្អូនរបស់ខ្ញុំ នឹកដល់រឿងហ្នឹង ចង់តែស្រក់ទឹកភ្នែក។ បងខ្ញុំបងគេបង្អស់គាត់មានឈ្មោះថា ម៉ាសមុត ហើយក្រោយមកទៀតមានឈ្មោះថាអឺ...ម៉ាខ បន្ទាប់មកទី៣ មានឈ្មោះថា ម៉ា សុនទៈរី ចាសទី៤មានឈ្មោះថាម៉ាស៊ី ម៉ាធៀន ចាស! ម៉ា ធៀន ហៅហ្នា! ហើយខ្ញុំឈ្មោះថា ម៉ា ធៀង ហើយទៅបន្ទាប់ពីខ្ញុំហ្នឹងមានឈ្មោះថា ម៉ាសូលីដាហៅ ថា សុន...

កៈ ចាស!

ខៈ ចាស! ហើយទៅបន្ទាប់មកទៀតមានឈ្មោះថា ម៉ា សៀង ដែលត្រូវជាប្អូនពៅ។ ចាស!

កៈ ចាស!ចុះអ៊ុំជាកូនទីប៉ុន្មានដែរ?

ខ៖ ខ្ញុំអឺម....មើលបងរបស់ខ្ញុំ! ទី១ទី២... ខ្ញុំជាកូនទី៥។

ក៖ ចាសអ៊ុំ!

ខ៖ ចាស!

ក៖ ចាស!ហើយចុះអ៊ុំបានការនៅក្នុងថ្ងៃខែឆ្នាំណាដែរអ៊ុំ?

ខ៖ ខ្ញុំបានការនៅក្នុងឆ្នាំ១៩៧០ ស្រុកកើតសង្គ្រាម។

ក៖ អូ...

ខ៖ ការនៅស្វាយរៀង។

ក៖ ចាស! ការក្នុងពេលស្រុកកើតសង្គ្រាម។

ក៖ ស្វាមីរបស់អ៊ុំគាត់មានឈ្មោះអ្វីដែរ?

ខ៖ ចាស! គាត់ឈ្មោះអិន សាយ។ គាត់បានស្លាប់ហើយ! គាត់នៅឯខេត្តស្វាយរៀងហ្នឹងដែរ។

ក៖ ចាស! គាត់បានស្លាប់ដោយសារអីដែរ ដូចជា...?

ខ៖ ចាស! អូ...ប្ដីរបស់ខ្ញុំគាត់បានស្លាប់ដោយសារតែជម្ងឺ គាត់បានឈឺទឹកនោមផ្អែម។

ក៖ ចាស! ខ្ញុំសុំទោសផងអ៊ុំដែរបានលឺចឹង។ ហើយគាត់ស្លាប់ទៅហ្នឹងយូរហើយអ៊ុំ?

ខ៖ ចាស! គាត់បានស្លាប់ទៅនឹងបាន៣ឆ្នាំហើយ។

ក៖ ចុះអ៊ុំបានរៀបការនៅក្នុងឆ្នាំណាដែរ តើអ៊ុំមានបាននៅចាំដែរឬទេ?

ខ៖ នៅក្នុងឆ្នាំ១៩៧០ នៅអាយុ២០។

ក៖ ចំពោះថ្ងៃខែណាអ៊ុំ?

ខ៖ អូ... ថ្ងៃខែហ្នឹងវាមិនសូវជាបានចាំអីនោះទេ ដឹងត្រឹមតែនៅក្នុងឆ្នាំ១៩៧០។

ក៖ ចាស!

ខ៖ ចាស!

ក៖ ចុះអ៊ុំមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ខ្ញុំមានកូន៥នាក់។

ក៖ គាត់...

ខ៖ ស្លាប់នៅក្នុងសង្គ្រាមកាលនៅសម័យប៉ុលពតហ្នឹងម្នាក់។ កើតមកឈឺស្លាប់។ ចាស!

ក៖ ចាសអ៊ុំ!

ខ៖ ហើយនៅសល់៤នាក់ បច្ចុប្បន្ននៅសល់កូន៤នាក់។

ក៖ គាត់មានឈ្មោះអ្វីខ្លះទៅអ៊ុំ?

ខ៖ អូ! កូនខ្ញុំឈ្មោះ...កូនដំបូងកូនស្រីឈ្មោះ អិន ម៉ារ៉ាន់ កូនទី២ អិនសុដានី កូនទី៣ឈ្មោះ អិន រិទ្ធី ប៉ាវាហ្នឹង ចាស! បន្ទាប់មក អិន ដារ៉ារិទ្ធ។ ចាស!

ក៖ ចាស! ហើយចុះ....

(មានសម្លេងនៅលេងស្រែកនៅក្នុងផ្ទះ ហើយគាត់ក៏បានស្រែអោយថា នែស)

ក៖ ហឺ..ចៅៗរបស់អ៊ុំគាត់គួរឱ្យស្រលាញ់ណាស់..ហើយទៅហឺ...

ខ៖ អិន ដារ៉ារិទ្ធ។

ក៖ ហើយចឹងកូនរបស់អ៊ុំមានស្រីប៉ុន្មាននាក់ ហើយកូនប្រុសប៉ុន្មាននាក់ដែរ?

ខ៖ ចាស! ប្រុស២ ស្រី២។ (មានចៅៗនៅជិតហើយគាត់ប្រាប់អោយទៅលេងនៅឯខាងក្រៅ)

ក៖ ចុះគាត់បានរៀបការអស់ហើយចឹងអ៊ុំណ៎?

ខ៖ ចាស! គេបានការអស់ហើយ។

ក៖ ចាស! ហើយចឹងបានជាអ៊ុំមានចៅៗច្រើន។

ខ៖ អូ! ចៅៗហ្នឹងច្រើនណាស់។ កូនប្រុសស្រីហ្នឹងវាបានចេញទៅធ្វើការងារអស់ទៅហើយ... (ថាអោយចៅថានែលអាស៊ីចេញទៅខាងក្រៅ)

ក៖ ចឹងកូនរបស់អ៊ុំគាត់បានរៀបការអស់គ្នាហើយមានកូនអស់ហើយអ៊ុំណោស?

ខ៖ ចាស! គេបានការអស់គ្នាហើយ មានកូនហើយខ្ញុំមានចៅអស់គ្នាហើយ។

ក៖ ចាស! ហើយទៅសព្វថ្ងៃគាត់នៅឯជាមួយអ៊ុំដែរឬក៏គាត់បែកទៅនៅឯផ្ទះផ្សេងអ៊ុំ?

ខ៖ គេបានបែកទៅហើយ កូនគេបានការ ហើយគេបានទៅនៅឯផ្ទះរបស់គេអស់ហើយអូន។ ចាស! នៅសល់តែកូនពៅដែលខ្ញុំនៅជាមួយ ឈ្មោះអិន ដារ៉ាវិទ្ធហ្នឹង។

ក៖ ចាស! ចុះសព្វថ្ងៃអ៊ុំមានសមាជិកគ្រួសារនៅជាមួយប៉ុន្មាននាក់ដែរ?

**ខ៖ អូ! ខ្ញុំមាននៅតែខ្ញុំ និងកូនប្រសារ ហើយនិងចៅមួយ ហើយនិងអ្នកនៅជាមួយ។**

ក៖ ចាស!

ខ៖ កូនខ្ញុំទៅធ្វើជាទាហានហើយ។

ក៖ ចាសអ៊ុំ! ហើយទៅអ៊ុំមានដូចជាអឺ..បងប្អូនឬក៏សាច់ញាតិអីដែលគាត់នៅក្រៅប្រទេសដែរឬទេ?

ខ៖ អត់មានទេ! ដូចអត់មានទេ។

ក៖ ចាស! ចុះអ៊ុំកាលពីមុនអ៊ុំបានរៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរ?

ខ៖ អ៊ុំរៀនបានត្រឹមថ្នាក់ទី៧ហ្នឹងហ្ន៎។ ទី៧ពីដើម។

ក៖ ចាស! កាលហ្នឹងអ៊ុំអាចចេះសរសេរ ចេះអានបានដែរឬទេអ៊ុំ?

ខ៖ ហ៊ឹស! ចេះបានតើ។ សរសេរបាន មើលបាន។

ក៖ ចុះភាសាវិញតើអ៊ុំរៀនបានប៉ុន្មានភាសា?

ខ៖ អូ! ភាសាអ៊ុំមិនសូវចេះទេ។ កាលណុងរៀនបានភាសាបារាំងបាន២ឆ្នាំដែរ តែឥឡូវអ៊ុំភ្លេចអស់ហើយអាអូនអើយ ព្រោះអីអាយុច្រើនហើយ អ៊ុំឈឺផង។ ហឺ...វាមានជម្ងឺទឹកនោមផ្អែមទៀត។

ក៖ ចុះកាលហ្នឹងអ៊ុំរៀននៅសាលាឯណាដែរអ៊ុំ?

ខ៖ អូ! នៅឯព្រៃគគីឯណោះ នៅឯស្រុកកំណើត។

ក៖ ឈ្មោះអីអ៊ុំចាំដែរឬទេ?

ខ៖ នៅឯសាលាឃុំព្រៃកគគី ស្រុកស្វាយទាប ខេត្តស្វាយរៀងហ្នឹង។

ក៖ ចាស!

ខ៖ ខ្ញុំរៀននៅហ្នឹង។

ក៖ ចាស! ចឹងកាលហ្នឹងវាជាសាលាមិនមែនជាវត្តទេអ៊ុំ?

ខ៖ ចាស! ជាសាលាប៉ុន្តែនៅជិតវត្តនៅឯក្បែរវត្តព្រែកគគីហ្នឹងនៅឯខេត្ត។ នៅឯជនបទដែរ។

ក៖ ចាស! ហើយកាលអីពីមុនឡើយហ្នឹង ការរៀនសូត្រអី វាខុសនឹងសម័យឥឡូវហ្នឹងយ៉ាងម៉េចដែរទៅ?

ខ៖ ចាស! ពីសម័យឥឡូវហ្នឹងមើល កាលហ្នឹងត្រឹមថ្នាក់ទី...គេ...ត្រឹមថ្នាក់ទី៧ហ្នឹងរៀនបារាំងបាន២ឆ្នាំហើយណា៎។ ចាស! គេរៀនថ្នាក់ទី...ប៉ុន្មានទេកាលហ្នឹង។ ខ្ញុំរៀនបាន២ឆ្នាំដែរ កាលហ្នឹងគ្រាន់តែដល់ពេលសម័យឥឡូវ វាភ្លេចបាត់ទៅហើយមកដល់សម័យឥឡូវមីអូនអើយ មិនចេះអីនោះទេ វាមិនបានចាំអីនោះទេពេលឥឡូវ។

ក៖ ចាស! ចុះអ៊ុំកាលហ្នឹង ហេតុអីបានជាអ៊ុំរៀនបានត្រឹមថ្នាក់ទី៧ចឹង?

ខ៖ ចាស! រៀនត្រឹមថ្នាក់ទី៧ហ្នឹងដោយសារតែស្រុកវាកើតសង្គ្រាម ឆ្នាំ៧០ ស្រុកកើតសង្គ្រាម យើងរត់បាក់បែកគ្នាទៅ យើងក៏លែងបានរៀនបានសូត្រទៅណា៎។ ក៏ឈប់រៀនទៅ ចាស! ហើយបន្ទាប់មកខ្ញុំបានរត់មកទីក្រុង ព្រោះអីនៅទីក្រុងបងប្រុសរបស់ខ្ញុំហ្នឹង គាត់ធ្វើជាគ្រូបង្រៀនកាលហ្នឹង បងប្រុសខ្ញុំ ម៉ាសំមុត ហ្នឹងណា៎។

ក៖ ចាស!

ខ៖ គាត់ធ្វើគ្រូបង្រៀន ចឹងទៅយើងរត់ពីស្រែមកជនបទចឹង គាត់ក៏ហៅយើងមកនៅជិតគាត់ទៅណា៎។ មកនៅក្រុងស្វាយរៀងជាមួយគាត់ទៅណា៎។ បានបន្ទាប់មកខ្ញុំបានមានប្តីការនៅឆ្នាំ៧០តែម្តងហ្នឹងហ្នា៎។

ក៖ កាលអ៊ុំការហ្នឹងដោយស្រលាញ់គ្នាឬក៏ឪពុកម្តាយគាត់ជាអ្នករៀបចំទុកដាក់ឱ្យ?

ខ៖ អូ! កាលហ្នឹងមិនបានជាស្រលាញ់អីគ្នានោះទេ ឪពុកម្តាយគាត់អ្នកទុកដាក់ឱ្យហ្នឹង។

ក៖ អូ! ចឹងអត់ដែលឃើញមុនគ្នាពីមុនទេអ៊ុំណា៎?

ខ៖ ហ៊ឹស!

ក៖ ហឹសៗ!

ខ៖ អឺ...មិនដែលឃើញទេ មកនៅណុងបានប៉ុន្មានខែគេឃើញគេស្រលាញ់ខ្ញុំតែម្ដង។ ម៉ែឪគេឃើញ គេស្រលាញ់ដណ្ដឹងទុកឱ្យកូនគេ។

ក៖ អូ! កាលហ្នឹងអ៊ុំប្រុសគាត់មានមុខរបរជាអីដែរ?

ខ៖ កាលហ្នឹងគាត់គឺជានិស្សិត។ រៀនថ្នាក់ទី៣ចឹងណា៎ ថ្នាក់ទី៣ទំនើបជាតិកាលណុងណា៎ ថ្នាក់ទី៣ យើងរៀនដូចថាឡើងឋានៈហើយណា៎ វាឡើងពីក្រោមឡើងលើហើយ។ ចាស! គាត់រៀន...កាលហ្នឹងគេហៅថារៀនអឺ...មហាវិទ្យាល័យអីចឹងណា៎។

ក៖ ចាស!

ខ៖ ចាស!

ក៖ ចុះកម្រិតថ្នាក់ទី៧របស់អ៊ុំ កាលណុងគេហៅអីគេដែរអ៊ុំ?

ខ៖ ចាស?

ក៖ អឺ! កម្រិតថ្នាក់ទី៧របស់អ៊ុំកាលណុងហៅអីគេដែរ? អ៊ុំប្រុសថ្នាក់ទី៣ចឹង វិទ្យាល័យ អ៊ុំថ្នាក់ទី៧ អនុវិទ្យាល័យ?

ខ៖ ខ្ញុំមិនអនុវិទ្យាល័យនោះទេ កាលណុងបឋមសិក្សា។

ក៖ ថ្នាក់ទី៧នៅបឋមទេអ៊ុំ?

ខ៖ ចាស។! នៅឯបឋមនៅឡើយទេ មិនទាន់បានឡើងវិទ្យាល័យអីនឹងគេទេ។ កាលហ្នឹងទោះប្រលងថ្នាក់ទី៧ បានឡើងវិទ្យាល័យ។

ក៖ អូ៎!

ខ៖ ចាស!

ក៖ អញ្ចឹងសាលាវិទ្យាល័យ អនុ បឋមអីនៅជាមួយគ្នា ឬផ្សេងពីគ្នា?

ខ៖ អត់ទេ! កាលណុងយើងជាប់ថ្នាក់ទី៧ហើយ បានយើងមករៀននៅមហាវិទ្យាល័យ ផ្សេងណា៎មករៀននៅទីក្រុង យើងនៅឯជនបទ យើងមករៀននៅឯទីក្រុង។ ចាស!

ក៖ ចាសអ៊ុំ! អញ្ចឹងវិទ្យាល័យមានតែនៅឯទីក្រុងអ៊ុំកាលណុង?

ខ៖ ចាស! កាលណុងនៅឯខេត្តៗហ្នា៎។ វាមិនបាននៅឯជនបទទេ។

កៈ ចាស! នៅឯខេត្តស្វាយរៀង?

ខៈ ចាស! នៅក្នុងខេត្តស្វាយរៀងអីចឹងទៅណាំ។ គ្មាននៅតាមស្រុកតូចតាចទេ នៅខេត្តតែម្ដង បានមាន។ ចាសៗ!

កៈ ចាស! ហើយកាលអឺ...ពេលដែលចូលដល់សម័យឆ្នាំ១៩៧០ ស្រុកចាប់ផ្ដើមកើតមាន សង្គ្រាមហ្នឹង ដែលអ៊ុំបានការហ្នឹង តើអាពាហ៍ពិពាហ៍កាលហ្នឹងយ៉ាងម៉េចដែរទៅអ៊ុំ? ដូចជា មានពិធីអីគេខ្លះដែរ?

ខៈ គ្មានអីទេ! ភ្លេងចាក់មេក្រូហ្នឹង មានហ៊ានធ្វើអីធំដុំ។ បើយើងកើតសង្គ្រាម គេរត់ជ្រួលជ្រាលៗពេញហ្នឹង។ យើងមានធ្វើអីបានអធិអធម គ្រាន់តែយើងធ្វើលេងត្រឹមតែចាក់បាស ចាក់ មេក្រូអីបន្តិចបន្តួច គម្រប់ៗហ្នឹង។

កៈ ចុះមានកម្មវិធីកាត់ចងដៃ ហែរជំនួនអី?

ខៈ ហ៊ើសមានតើ!

កៈ អូ! ចឹងមានទាំងអស់អ៊ុំណាំ?

ខៈ ហ៊ើស! មានទាំងអស់ គ្រាន់តែថាយើងមិនបានបំពងសម្លេងឱ្យវាខ្លាំងក្លាអីចឹងទៅណាំ។

កៈ ចាស! ចុះការម៉ានថ្ងៃដែរទៅអ៊ុំ?

ខៈ ចាស? ការស្វូត្រមន្តស្អែកឡើងការ។ ការ១ថ្ងៃ១យប់។

កៈ ដូចតែឥឡូវដែរតើអ៊ុំនេស់?

ខៈ ចាសៗ! ចុះយើងការស្រុកកើតសង្គ្រាម ចុះយើងមានបានធ្វើអីឱ្យក្បូះក្បាយ?

គៈ សង្គ្រាមហ្នឹង សង្គ្រាមអីគេអ៊ុំ?

ខៈ ហាំ! ឆ្នាំ៧០ហ្នឹង រដ្ឋប្រហារទម្លាក់សម្ដេចព្រះសីហនុនុ៎ះ។

កៈ ចាស! ដល់ពេលឆ្នាំ៧៥បានចូល...

ខៈ ហើយបានចឹងទៅបានស្រុកចេះតែរឹករល់ទៅចឹងទៅ។

កៈ ត្រូវហើយអ៊ុំ!

ខៈ ចាស!

កៈ កាលហ្នឹងខ្ញុំឮម៉ាក់ខ្ញុំនិយាយដែរ...

ខៈ ចាស!

កៈ គាត់ថាវាអត់ស្រួល។ ស្រុកទេសចូល រត់នៅសម័យ លន់ នល់អីណោះអ៊ុំ។

ខៈ ចាស! ហ្នឹងហើយ។ ៧០ទម្លាក់សម្ដេចហ្នឹងបាន លន់ នល់ ពួកគេបានធ្វើរដ្ឋប្រហារទម្លាក់សម្ដេច សីហនុហ្នឹង។ គេធ្វើរដ្ឋប្រហាលទម្លាក់សម្ដេចសីហនុ។ ខាងក្រុមគាត់ហ្នឹង សម្ដេចចេញទៅ បារាំងទៅ ខាងក្រុមគាត់ហ្នឹង គេធ្វើរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ព្រោះពួកខាងលោក សុខាមខូ លោកពូយ័ន លោកពូនឹម លោកអី... ស៊េរីអ៊ុនតាក់ហ្នឹងហ្នា៎ ទម្លាក់សម្ដេចទៅបាន ខាងលន់ នល់គេកាន់កាប់តាំងពីឆ្នាំ៧០រហូតដល់៧៥អីចឹងទៅណា៎មីអូន។ ចាស! ដល់៧៥ហ្នឹង។ ៧៥ហ្នឹងវា...មើលកាលហ្នឹងវា...ខ្ញុំវាដូចជាភ្លេចដែរ។ ៧៥យើងបែកនេះហើយហោស៎?

កៈ ៧៥ចូលអាពតហើយអ៊ុំ។

ខៈចូលអាពតហើយ។

កៈ ចាស!

ខៈ ចាស! ៧៥បែក លន់ នល់ ខ្ញុំក៏រត់មកនៅភ្នំពេញចោលផ្ទះនៅស្វាយរៀងហើយណា៎។ ចោលទ្រព្យសម្បត្តិនៅឯស្វាយរៀងមានឡាន មានម៉ូតូ មាន តុទូសាឡុងអីចឹងទៅណា៎ ដ៏ ហើយខ្ញុំក៏ឡើងយន្តហោះមកឯភ្នំពេញឆ្នាំចិតសិបមួយ ចិតសិបពីរហ្នឹងហ្នា៎។ ចាស! ខ្ញុំក៏ឡើង យន្តហោះទៅភ្នំពេញ។ ហ្នឹងនៅក្នុងសម័យ លន់ នល់ហ្នា៎។

កៈ ចាស!

ខៈ ដល់មកដល់...នៅហ្នឹង ខ្ញុំក៏រកស៊ីចឹងទៅ ប្ដីខ្ញុំក៏ចូលធ្វើទាហានអាកាសចរណ៍ចឹងទៅណា៎។

កៈ ហឺស..

ខៈ ចាស! ចូលធ្វើទាហានអាកាសចរណ៍ចឹងទៅ ខ្ញុំរកស៊ីលក់ផ្លែឈើនៅផ្សារពោធិ៍ចិនតុនហ្នឹង រហូតទៅដល់ឆ្នាំ៧៤ដល់៧៥បែកភ្នំពេញ។ ចាស! បែកភ្នំពេញហ្នឹង ខ្ញុំបានកូន២ហើយ។ ចាស! បានកូន២ហើយ បានឈ្មោះ អិន ម៉ារ៉ាន់១ អិន សុដានី១។ ចាស!

កៈ ហឺស..

ខ៖ ដល់យើងបែកភ្នំពេញហើយ ខ្ញុំក៏ចេញពីភ្នំពេញហើយណា៎។ យើងបែកហើយណា៎! យើងឆ្នាំ៧៥ហើយ ក៏ខ្ញុំរត់ទៅសម័យប៉ុល ពត ទៅខាងស្រុកកំណើតខាងប្តី។ ចាស! នៅខេត្តស្វាយរៀងហ្នឹង។ ទៅដល់ស្រុកហ្នឹងទៅ ក៏ប្តីខ្ញុំគេចាប់យកទៅរៀនសូត្រ។

ក៖ ហឺ....

(មានសម្លេងចៅៗគាត់កំពុងតែលេងនៅជិតហ្នឹង)

ខ៖ រៀនសូត្រហ្នា៎! គេថាប្តីយើងនៅអឺ...ក្នុងចឹង ធ្វើទាហាន ធ្វើអីចឹងទៅណា៎។ អញ្ចឹងគេយកយើងទៅរៀនសូត្រ។ នៅអឺ..កោះពិសោម (គាត់បានប្រាប់ចៅៗគាត់ថានែកចៅ) បាន៥១ថ្ងៃ។ បាន៥១ថ្ងៃបានគាត់ចេញមកវិញ។ ហ្នឹងដោយសារប្តីខ្ញុំគាត់ស្លូតត្រង់ គាត់មិនត មិនធ្វើអីគាត់សកម្មការងារហ្នា៎  ដល់ចឹងគេឱ្យឆាប់វិលត្រលប់មករកផ្ទះវិញ។ បើក្រៅពីហ្នឹង គេនៅគេទុកធ្វើទារុណកម្មរហូតដល់ទៅងាប់នៅកន្លែងរៀនសូត្រក៏មានដែរ។ ចាស!

ក៖ ចាសអ៊ុំ! ចឹងកាលហ្នឹងគេជម្លៀសអ៊ុំនិងក្រុមគ្រួសារទៅជាមួយគ្នាគាត់តែម្តង?

ខ៖ ចាស! ទៅជាមួយគ្នា។ ខ្ញុំចេញពីភ្នំពេញខ្ញុំរត់រកប្តីខ្ញុំ ប្តីខ្ញុំរត់រកខ្ញុំ។ ទៅជួបគ្នានាំគ្នាចេញទៅ។ ចេញតាមអឺ...នេះស្អីនេះទេ...តាមចំការដូងនេះ តាមចំការដូងនេះចាក់ទៅត្រាំខ្នារ ចាក់ទៅខាងនេះ ទៅយោងប្រាសាទ បានទៅខេត្តស្វាយរៀង។ ដើររហូត!

ក៖ ហឺ...

ខ៖ ដើររហូតចេញពីភ្នំពេញទៅ ប្តីខ្ញុំគាត់រុញម៉ូតូ ពោះដល់ម៉ូតូអត់សាំងខាងអាដែងខ្មែរក្រហមគេយកម៉ូតូទៅ ម៉ូតូគាត់ហ្នឹងណា៎ ហើយខ្ញុំក៏បានអាកង់គេចោលហ្នឹង។ គេយកម៉ូតូយើង គេចោលអាកង់ហ្នឹង អូសកូនឥវ៉ាន់អូសកូនប្រពន្ធទៅស្រុកកំណើត។

ក៖ អឺស...

ខ៖ ប៉ុនទៅដល់បានតែ២យប់ ប្តីខ្ញុំគេយកទៅរៀនសូត្រទៅណា៎។ ចាស!

ក៖ ចុះអ៊ុំកាលហ្នឹងដំណឹងដូចជាឪពុកម្តាយ បងប្អូនរបស់អ៊ុំ?

ខ៖ អូ៎ៗចាស! អឺឪពុកម្តាយរបស់ខ្ញុំ គាត់នៅខាងស្រុកណុង។ ចាស! គាត់នៅស្រុកណុងគាត់នៅខេត្តស្វាយរៀង។ ដល់ហើយខ្ញុំក៏រត់ទៅរកគាត់ តែចំណែកម៉ែឪខាងខ្ញុំនេះគាត់ភៀសខ្លួនចូលស្រុកវៀតណាមទាំងអស់។

គ៖ អឺស....

កៈ អឺស...

ខៈ ចាស!ម៉ែខ្ញុំគាត់នៅព្រំដែនគាត់រត់ទៅនីវៀតណាមហ្នាំ។ រត់ទៅនៅវៀតណាមទាំងអស់! ទៅនៅខាងប្ដីបែកឯភ្នំពេញទៅនៅខាងប្ដីឯហ្នឹងហើយក៏...ស្រុកគេរីករវល់ខ្លាំងហ្នាំណាស់។ដល់រីករវខ្លាំងចឹងទៅ ខ្ញុំក៏រត់នៅជាមួយនឹងគ្រួសារខាងប្ដីហ្នឹងហ្នាំ រត់ចុះរត់ឡើងចឹង...(គាត់បានប្រាប់ចៅគាត់ចៅហោស!!) ចាស!កូននេះ... ស្រាប់តែដល់ចឹងអូនឯង! ចាស! ស្រាប់តែដល់ពេលចឹងខ្ញុំនឹងក៏នៅជាមួយខាងប្ដីរត់ចុះរត់ឡើង គេក៏...យួនក៏មកចាប់ប្ដីខ្ញុំ ចាប់ប្រជាជនទាំងអស់។

គៈ មួយហ្នឹងរួច... គាត់ចេញពី...

ខៈ ពីរៀនសូត្រហើយ!

គៈ ពីរៀនសូត្រហើយយ!

ខៈ ចាសៗ! គាត់ចេញពីរៀនសូត្រហើយ ក៏រស់នៅជាមួយប្រពន្ធធ្វើការពលកម្មអីជាមួយយើងក្នុងសម័យប៉ុល ពត ហ្នឹងហ្នាំ។ ដូចថារៀនមួយវគ្គទៀតមានវៀតណាម គេចុះមកដូចថាមកចាប់ប្រជាជនហ្នាំ! ចាស! វៀតណាមគេបានចូលមកយើងចឹងខ្មែរយើងនឹងគេក៏បានថយទៅណា។អ្នកដែលថាខ្មែរយើងនឹងពេលដែលថាថយវាអត់បានទាន់នឹងក៏គេបានចាប់យកទៅរៀនសូត្រដែរ នៅស្រុកគេចាស!

កៈ ហឺ...

ខៈ ចាស!ការរៀនសូត្រនៅឯស្រុកគេនឹងវាគឺថាវាពិបាកណាស់ដែលមានខាងប្ដីរបស់ខ្ញុំនឹងមានបងប្អូនប្ដីប្រពន្ធខាងប្ដីនឹងអ្នកស្រុកអីនឹងដែលគេបានចាប់យកទៅនឹងណា។ គេថាគេបានយកទៅសំលាប់ចោលអស់ទៅហើយ!គេបានឃោសនានឹងថាបានងាប់នៅក្នុងអណ្ដូង ងាប់ឡើង១អណ្ដូងៗ! ហើយយើងនឹងចេះតែជឿហើយចឹងណា ទៅនៅជាមួយនឹងអាពពតនឹងកាលនឹងចេះតែជឿហើយព្រោះអីកាលនឹងយើងបានរស់នៅជាមួយនឹងអាពត។ ហើយចឹងតែស្ញើបខ្សួលគ្នាចឹងចាសកាលនឹងពេលដែលវៀតណាមនឹងចូលមកចាប់ប្ដីនឹង!

ចាប់ក្មេងចាប់អីនឹងទាំងអស់អោយតែថាកាលនឹងមនុស្សនឹងវាពេញវ៉ៃយចឹងណា
គេចាប់ហើយ។
ចឹងហើយកាលនឹងខ្ញុំនឹងបានមើលឃើញប្តីរបស់ខ្ញុំនឹងឡើង៧ទៅ៨នាកចឹងហើយដើរមកចឹងទៅខ្ញុំនឹងក៏បានប្រាប់អោយប្តីរបស់ខ្ញុំនឹងដេក។
ខ្ញុំនឹងក៏បានរត់ទៅសាសងជាមួយនឹងយួននឹងចឹងណា!
ជាមួយនឹងពួកវៀតណាមនឹងចឹងទៅណា!ថា
អាអើយប៉ាកូយអញកងហា!មានន័យថាប្តីរបស់ខ្ញុំនឹងមានកូន៣នាក់ហើយប្តីរបស់ខ្ញុំនឹងទាហានកម្ពុជា ចឹងណាហើយចឹងខ្ញុំនឹងក៏បានថាអត់ទេ!
ប្តីរបស់ខ្ញុំនឹងកូនប្តីគាត់បានឈឺថាស្អី១នឹងចឹងទៅ!កាលនឹងយើងនឹងចេះតែនិយាយភូតទៅណា!ហើយចឹងដល់ពេលដែលបាននិយាយភូតនឹងបានរយៈពេលបាន១ខែដែលបានតិចរត់ទៅនៅឯនេះតិចទៅតិចរត់ទៅនៅឯនោះគេនឹងបានចាប់ច្រើនពេកចឹងទៅយើងនឹងកតិចទៅព្រោះអីគេបានចាប់ច្រើនពេកចឹងហើយក៏បានតិចរត់ទៅរស់នៅកន្លែងនេះតិចទៅរត់ទៅនៅឯកន្លែងនោះ!ហើយនាំគ្នានឹងបានរែកទៅទៀតចឹងទៅណា!រហូតទៅដល់ពេលបាន១ខែ។១ខែចុងក្រោយនឹងបានគេបានចាប់ប្តីរបស់ខ្ញុំនឹងបាន។
ពេលនឹងប្តីរបស់ខ្ញុំនឹងគាត់មិនបានចង់នឹងចាក់ចេញទៅចោលប្រពន្ធនោះទេក៏ប៉ុន្តែដូចថាគេនឹងបានទៅអស់ហើយនឹងថាដូចថាកាលនឹងប្រជាជនអីនឹងគេនាំគ្នាទៅអស់ហើយនឹងកាលនឹងណា! គេបានទៅអស់ហើយ
គេបានយកចាប់គាត់នឹងទៅអស់ហើយដូចជាក្មេងនៅលូវ១ណាគេបានចាប់យកទៅអស់ហើយ!នៅឯចុងក្រោយនឹងខ្ញុំនឹងបានប្រាប់គាត់ថា បង
ឯងត្រូវតែទៅ១ព្រោះអីយើងត្រូវទៅតាមភាគច្រើនយើងមិនត្រូវនៅភាគតិចនោះទេព្រោះអីយើងនៅឯទីនេះនឹងគឺវាភាគតិចចឹងហើយយើងត្រូវទៅតាមភាគច្រើនហើយណា!នៅសល់តែយើងតែ២ទៅ៣នាក់នោះទេណាដែរ
យើងនឹងបានខំសូមគេថាពពតនឹងគេបានធ្វើបាបហើយគ្អកឡើងធ្លាក់ឈាមមកណា!ចឹងហើយបានជាគេនឹងមិនបានយកយើងនឹងទៅប៉ុន្តែគេនឹងនៅតែព្យាយាមថាប្តីរបស់យើងនឹងនៅល្អ។ ចឹងហើយគេថា តុលិនណា គេថានៅល្អហើស
ដែបហ៉ាលក៏មានន័យថានៅល្អនៅស្អាតនឹងចឹងគេនឹងនៅតែអូសប្តីរបស់យើងនឹងយកទៅ។
ហើយថ្ងៃនឹងណាគេបានចាប់ប្តីរបស់ខ្ញុំនឹងយកទៅទាំង៣នាក់បណ្តើរនឹងហើយវាបានសួរខ្ញុំថាខ្ញុំនឹងចង់ទៅដែរឬទេ?កាលនឹងខ្ញុំនឹងបានឆ្លើយឡើងថាខ្ញុំមិនបានទៅទេព្រោះអីខ្ញុំនៅមានកូន១របស់ខ្ញុំនឹងគាត់នៅវាងតូច១ច្រើនកាលនឹងបានកាន់កូនដល់ទៅ៣នាក់ណាកាលនឹង។

ហើយដល់ពេលដែលបានប្ដីរបស់ខ្ញុំនឹងទៅចឹងទៅកាលនឹងខ្ញុំក៏បានទៅឡើងនៅឯចុងឈើណាមើលប្ដីរបស់ខ្ញុំណា
កាលនឹងខ្ញុំបានឡើងដើមឈើតាមមើលគាត់នឹងរហូតដល់ពេលដែលគាត់នឹងបានចូលដល់ព្រៃព្រាក។ ហើយគេនឹងបានផ្ញើរយួន៨នាក់
វៀតណាម៨នាក់នឹងហើយមានបងប្អូនរបស់ខ្ញុំនឹងមានចំនួន៣នាក់។
ដែលបងប្អូនរបស់ខ្ញុំសព្វថ្ងៃនឹងមានឈ្មោះថា អិនស៊ីដារ៉ា ផ្កាយ២នៅឯនេះណា
អឺ....នេះណាកងពល២១នៅកងត្នោតនៅឯកំពង់ចាមនឹងណាចាស!
ប្អូនរបស់ខ្ញុំនឹងវាបានស្លាប់នៅឯទីនោះទៅចាស! វានឹងរាងថាធំដែរនឹងគឺបានផ្កាយ៣ដែរនឹងគាត់ប្រធាននៅក្នុងបក្សណាប៉ុន្តែគាត់នឹងបានស្លាប់ទៅនឹងនៅក្នុងសម័យសង្គ្រាមយើងនឹងតែនៅ១នឹងប្ដីរបស់ខ្ញុំនឹងកាលនឹងគេបានចាប់គាត់នឹងទៅដែរដល់ទៅប្រហែលជាខ្វង់បានប្រហែលជាបាន១ខែ
គេនឹងក៏បានជំលៀសយើងនឹងទៅវិញហើយក៏មានពពតនឹងថយក្រោកមកឃាំងយើងនឹងទៅវិញទៀតកាលនឹងថាអោយយើងនឹងទៅវិញទៀត។
ថាអោយយើងនឹងទៅវិញចឹងទៀតថាអោយយើងនឹងទៅលិច ទៅណាចឹង។
ហើយកាលនឹងគេបានថាអោយយើងនឹងទៅឯអង្គស
ទៅពួកខ្ញុំនឹងមិនបាននឹងទៅអង្គនោះទេកាលនឹងព្រោះអីកាលនឹងពួកខ្ញុំនឹងបានដើរវាងចេញទៅនឹងមិនបានដើរទៅតាមនឹងទេហើយក៏បានដើរវាងទៅកន្លែងផ្សេងហើយកាលនឹងបើគេនឹងប្រាប់ថាអោយទៅតាមវត្តខ្ជាយនឹងក៏ខ្ញុំមិនបាននឹងទៅដែរព្រោះអីបើទៅនឹងកាលនឹងវាបានយកទៅវ៉ៃចោលអស់ហើយដល់ចឹងទៅកាលនឹង ខ្ញុំបានដើរគេចនឹងណាចាស!

គ៖ កាលនឹងនៅក្នុងខេត្តណាដែរទៅអ៊ុំ?

ខ៖ ចាសនៅខេត្តស្វាយរៀងណាអូន!

គ៖ អូ...រត់ទៅដល់ខេត្តស្វាយរៀង!

ខ៖
ចាស!ខ្ញុំបានរត់ទៅដល់ខេត្តហើយកាលនឹងវាបានជិតទៅដល់ឯព្រំប្រទល់យួនហើយនឹងកាលនឹងតែគ្រាន់តែកាលនឹងយាយរបស់ខ្ញុំនឹងគាត់មិនបានព្រមទៅ។
យាយរបស់ខ្ញុំនឹងគាត់បានប្រាប់ថាគាត់នឹងមិនព្រមទៅព្រោះអីគាត់ថាអញមិនព្រមអោយទៅចោលឆ្អឹងនៅឯស្រុករបស់គេនោះទេ

ដល់ចឹងកាលនឹងចៅៗនឹងគេបានចាប់យកទៅអស់រលីង។
ហើយដល់ពេលចឹងទៅកាលនឹងខ្ញុំនឹងក៏បាននៅនឹងទីនោះហើយថាកាលនឹងនៅក្នុងសម័យព ពតនឹងខ្ញុំវាបានវេទនាណាស់មានកូន៣នាក់ស្រាប់តែយកគាលខ្ញុំនឹងបានឯខាងលិចចឹងទៅ ណា!ចឹងកាលនឹងមានប្រជាជនជាច្រើននាក់នឹងបានចេញមកហើយគេគាលមកខាងលិចនឹង អស់ចឹងទៅ! ដូចថាមានយុវនារីដូចជាពពួកអូនឯងចឹងណា
វាបានចាប់យកទៅធ្វើបាបចាប់យកទៅពពួកយោធាវានឹងចាប់ទៅដេក!
ចាប់យកទៅដេកហើយនឹងយកទៅសំលាប់ចោល!ចាប់ដេកហើយយកទៅសំលាប់ចោល!នៅ សល់តែអ្នកណាដែលគេបានគេចទៅចូលក្នុងព្រៃទេ ដែលគេចាប់មិនបាន។
ពួកវានឹងសាហាវណាស់ ខាងខ្មែរយើងនឹងក៏វាសាហាវដែល
ខាងខ្មែងយើងនឹងហើយដែលថាវាសាហាវនឹងខ្មែរក្រហមនឹងហើយបានជាវានឹងចាប់រំលោភនឹ ង!

ក៖ ហឺ...

គ៖ ហឺ...

ខ៖ ហើយអ្នកដែលនៅសេសសល់នឹងគេត្រូវបញ្ជូនមកហើយ
ហើយដល់តែពេលបានប៉ុន្មាននឹងចឹងទៅ គេនឹងបានបញ្ជូនខ្ញុំនឹងថាណឺល
ឥឡូវនឹងត្រូវទៅតំបន់២៥ត្រូវជូន៣០គ្រួសារៗមកតំបន់នឹងដែលគេបានហៅថាតំបន់២៥ដែល អានឹងគេបានគាស់យើងនឹងមកហើយណា!
ចាស!ហើយពេលដែលបានមកដល់នឹងគេបានជូនគ្រួសារម៉ា២៥គ្រួសារម៉ា២៥គ្រួសារនឹងយក ទៅបញ្ជូនទៅតាមទូកទៅណា
ហើយកាលនឹងគេនឹងមិនបានបញ្ជូនយើងនឹងមកតំបន់២៥នោះទេកាលនឹងគឺពួកវានឹងបានយ កយើងនឹងមកសំលាប់នៅឯបឹងត្របែកនឹងនេស!

ក៖ ហឺយ....

គ៖ ហឺ..

ខ៖
ដែលវានឹងបានជីកសំលាប់នឹងយកយើងនឹងមកសំរាប់វ៉ៃចោលនៅឯកន្លែងនឹងនេះ!ចឹង!កាល នឹងខ្ញុំនឹងក៏មានឈ្មោះនឹងនៅកន្លែងនឹងដែរ!

ក៖ ហឺ.....

ខ៖ ព្រោះអីខ្ញុំនឹងគឺជាប្រជាជនថ្មី២ជាន់
ថ្មីចេញពីភ្នំពេញយើងនឹងផងហើយថ្មីចេះពីភ្នំពេញផងនឹងថ្មីប្ដីបានចេញទៅយួនទៅនឹងចឹងចាស!

ក៖ អូ......

គ៖ អឺ....

ខ៖
ចឹងហើយកាលនឹងគេនឹងត្រូវបានវ៉ៃខ្ញុំព្រោះអីកាលនឹងខ្ញុំនឹងនៅមានឈ្មោះដែលគេត្រូវហៅទៅតំបន់២៥នឹងដែរ។ ចឹងដល់ពេលនឹងគេបានប្រាប់មកដល់ម្ដាយក្មេករបស់ខ្ញុំនឹងមកថា អ៊ុំឯងហើយនឹងបងស្រីនឹងដាក់ឥវ៉ាន់នឹងអោយហើយទៅចែកឥវ៉ាន់នឹងអោយហើយទៅបើគេនឹងមកហៅពេលយប់ បងឯងនឹងទៅអោយបានលឿនទៅកុំអោយគេនឹងចាំ
កុំអោយគេនឹងបានសំឡុតកំហែលអីនឹងចឹងទៅណា!
ហើយកាលនឹងខ្ញុំអឺ..ម្ដាយក្មេករបស់ខ្ញុំនឹងអើយគាត់បានយំឡើងស្គមខ្លួនអស់ហើយកាលនឹងព្រោះអីប្ដីរបស់គាត់នឹងក៏ត្រូវទៅដែរ។
ប្ដីរបស់គាត់នឹងក៏បានគេចាប់យកទៅដែរកាលនឹងព្រោះអីគេបានចាប់យកទៅលីគ្រាប់ទៅចឹងកាលនឹងគេបានអោយគាត់នឹងទៅលីគ្រាប់នឹងចឹងទៅបានយកទៅតែអាវនឹងសារ៉ុងសូត្រ១នោះទេកាលនឹង
យួននឹងក៏វាបានចាប់អោយវាបានចាប់នឹងបង្ខំគាត់ទៅដល់ចឹង...យូរពេកហើយទេអី?

ក៖ អត់អីទេ...

គ៖ អត់អីទេអ៊ុំ....

ខ៖
ដល់ពេលចឹងកាលនឹងប្ដីរបស់ខ្ញុំអីនឹងកាលនឹងគេបានចាប់យកគាត់ទៅទាំងអស់នឹងកាលនឹងគេថាបានយកទៅឯតំបន់ឯ២៥នឹងណាអូ!
ហើយកាលនឹងណាអូនអាយកាលនឹងខោអាវរបស់យើងនឹងពេលដែលបានជិះទូកទៅណាកាលនឹងអូ មកវិញទាំងអស់
ពេលដែលបានទៅហើយនឹងគឺបានឃើញវានឹងមកវិញទាំងអស់ខោអាវដែលយើងបានដាក់

ទៅនឹងនោះ!
ព្រោះអីកាលនឹងពួកវានឹងបានយកទៅចែកអោយគេវានឹងបានស្លៀកនោះអីនឹងចឹងបានថាខ្មែរយើងនឹងកាលនឹងវាអាក្រក់ណាស់!ចឹងហើយនឹងអូងងបានស្រាប់តែដល់ពេលនឹងចឹងទៅណាដល់តែពេលជិតបានដល់ពេលវេនរបស់ខ្ញុំនឹងហើយណា!ដល់ពេលនឹងទៅខ្ញុំនឹងបាននឹកឃើញថាខោអាវនឹងពេលដែលបានដាក់ទៅនឹងបានឃើញវានឹងមកវិញមិនបានដឹងថាវានឹងយកទៅចោលនៅឯណានោះទេ
តែចឹងដ៏ពេលថ្ងៃ១នឹងនោះអូអាយគេនឹងបានដើរប្រាប់ថាឥឡូវនឹងបងប្អូនទាំងអស់គ្នាថាបងប្អូនទាំងអស់គ្នាដល់ពេលថ្ងៃស្អែកនឹងបងប្អូនត្រូវចូលរួមនៅក្នុងការប្រជុំគឺថាការប្រជុំនឹងគឺថាវាគ្មានប្រជាជនថ្មីនឹងប្រជាជនចាស់នោះទេគឺថាប្រជាជនស្មើរគ្នានឹងទាំងអស់នឹងចឹងណា!ចឹងហើយប្រជាជនឹងទាំងចាស់ហើយនឹងទាំងថ្មីត្រូវមានសិទ្ធិស្មើគ្នាទាំងអស់នឹងចឹងវិញចឹងហើយត្រូវតែទៅតំបន់២៥នឹងទៅទាំងអស់គ្នាព្រោះអីយួននឹងមកជិតដល់ហើយ
វៀតណាមនឹងយួននឹងវាបានមករំដោះយើងយកប្តីរបស់យើងនឹងទៅធ្វើជាទ័ពហើយគេនឹងបានវៃមកតាំងពីប្រទេសវៀតណាមនឹងមកណា!គាត់មកវៃមកហើយ
គាត់បានវៃមកនឹងតាំងពីក្រចេះហើយចឹងគាត់នឹងបានមកប្រាប់ខ្ញុំនឹងថាភ្នំនឹងគឺភ្នំ៥ពាន់នឹងវៃទំរាំតែបែកខ្មែរក្រហមណាក៏វៀតណាមនឹងគេបានជួយវៃយើងនឹងដែលកាលនឹងយើងកាលនឹងគេនឹងបានជួយវៃនាំមុខដល់យើងនឹងកាលនឹងគេនឹងនៅខាងមុខហើយយើងនៅពីក្រោយកាលនឹងចាស!
ហើយដល់ពេលដែលបានមកដល់កាលនឹងពេលថ្ងៃខ្ញុំនឹងនេះ!ឥឡូវនឹងនិយាយពីរឿងរបស់ខ្ញុំនឹងវិញ។កាលនឹងខ្ញុំនេះនឹងគេបានបញ្ជូនមកដល់តំបន់២៥កាលនឹង។(គាត់ប្រាប់ចៅគាត់ថាទី)ខ្ញុំនឹងបានមកតំបន់២៥នឹងណាកាលនឹងព្រោះអីកាលនឹងគេលែងបានមកបញ្ជូនមកតំបន់នឹងចំនួនមនុស្ស២៥គ្រួសារនឹងហើយគេបានម្តងនឹងបញ្ជូលទាំងអស់តែម្តង។
គេបានបញ្ជូននឹងគេបានដាក់ជាកាប៉ាល់អូសនឹងកាលនឹងមានកប៉ាល់នឹងចំនួន៣កាលនឹង។

គ៖ កាប៉ាលនឹងកាលនឹងវាមានទំហំនឹងប៉ុណ្ណាដែលទៅអ៊ុំ?

ខ៖ ហ្វ...កាលនឹងកាប៉ាលដឹករបស់ខ្ញុំនឹងកាលនឹងវាធំៗជាងផ្ទះនេះទៅទៀតនឹង
វាធំណាស់សំរាប់នឹងដាក់មនុស្សនឹងប្រជាជននៅក្នុងតំបន់នឹង
ព្រោះអីកាលនឹងវៀតណាមនឹងវាបានដេញមកជិតដល់ហើយ!

ក៖ ចាសអ៊ុំ!

ខ៖ ចាស!
ដល់ចឹងកាលនឹងស្រាប់តែគេនឹងបានដាក់នៅក្នុងកប៉ាលដែលខ្ញុំនឹងបានជិះដល់មកវ៉ាងមីអ្នកលឿងយើងនឹងអូន
ហើយពេលដែលមកដលល់នឹងកាលនឹងខ្ញុំនឹងក៏នៅតែមានឈ្មោះដែលគេនឹងបានហៅដែលគឺនៅតែមានឈ្មោះថាម៉ាធៀងនឹងដែរចាស!កាលនឹងគេនឹងបានហៅឈ្មោះនឹងទាំងអស់គ្នានឹងកាលនឹងអត់មានថាម្ដាយក្មេងរបស់ខ្ញុំនឹងគាត់បានបែកគ្នានោះទេ
ហើយស្រាប់តែដល់ពេលចឹង!
ស្រាប់តែដល់ពេលចឹងខ្ញុំនឹងក៏បានឡើងទៅលើកប៉ាលនឹងដែលមានកូននឹងវាយំព្រោះអីកាលនឹងវាក្ដៅខ្លួន កាលនឹងកូនរបស់ខ្ញុំនឹងវាបានក្ដៅខ្លួនវាបានដេកនៅលើអាស្អីគេជញ្ជាំងកប៉ាលនឹងមើលទេសភាពហើយកាលនឹងអូ អើយកប៉ាលនឹងវាមាន៣
ហើយគេបានថាកប៉ាល១ទៀតនឹងវាបានលេច ហើយកប៉ាល១នឹងទៅអមស៊ីណាល
ហើយកប៉ាល១នឹងមកងអែបនៅចំណតនៅឯភ្នំពេញឯនេស!
កប៉ាលដែលខ្ញុំបានជិះនឹងគឺវាបានមកដល់ឯខាងកាស៊ីណូលនៅឯភ្នំពេញនឹង។ហើយគ្រាន់តែបានមកដ៏កាស៊ីណូនៅឯភ្នំពេញវិញហើយនឹង
ប្រជាជននឹងវាមិនដែលបានមើលឃើញភ្នំពេញនោះណាកាលនឹងស្រាប់តែឡើងថ្លែងកប៉ាលឡើងចៀកមិនអូនអឹក..!

ក៖ អឺស....

ខ៖
ស្រាប់តែកប៉ាលនឹងបានចុះចតនៅខាងឯច្បារអំពៅហើយអូអើយកាលនឹងគេបានអោយយើងនឹងចុះហើយគេបានចែកបាយចែកអីចឹងអោយយើងនឹងបានទៅញ៉ាំអីចឹងកាលនឹងដូចថាអង្គការអីនឹងដែលបានចុះចែកហើយសំរាប់អោយដល់យើងនឹងណាដែលរួមមានដូចជាបាយចំហុយត្រីចំហុយចឹងទៅណាដែលហើយកាលនឹងគេបានចំហុយនឹងសុទ្ធតែសឹងហើយកាលនឹងគេនឹងបានចែកចាយថ្នាំពេទ្យហើយនឹងគេបានចែកដូចជាខោអាវអីចឹងទៅណា!ហើយបន្ទាប់មកទៀតនឹងគេបានចែកទៀតនៅពេលថ្ងៃរសៀល។
ដល់ពេលថ្ងៃរសៀលនឹងគេបានចែកអោយយើងហើយគេបាបដាក់ដឹកដាក់នៅក្នុងឡាននៅឯខាងមុននឹងចឹងណាកាលនឹងនៅខាងមុនរាវថទេះភ្លើងនឹងហើយ
ក៏ម៉ោង៦ទៅ៧យប់នឹងគេបានមកសំរាប់នឹងបញ្ជូនអោយយើងនឹងទៅអឺ...ខាងខេត្តពោធិសាត់នៅឯបាត់ដំបង ហើយកាលនឹងខ្ញុំនឹងបានទៅដល់ហើយនឹងនៅក្នុងខែ៩កាលនឹង!

ម្តាយរបស់ខ្ញុំនឹងពេលនឹងគាត់បានចុះពីលើរថភ្លើងនឹងដែលម្តាយរបស់ខ្ញុំនឹង! ហើយមានគេស្រែឡើងថាពីលើរថភ្លើងនឹងបានប្រាប់ចុះៗ!!សូមឪម្តាយអញ្ជើញចុះ! ហើយនឹងក៏បានស្រវេរស្រវាលកូនយើងនឹងកំពុងតែដេកនឹងវាបានឆ្វាញ់នឹង ហើយចឹងវាបានក្រោកហើយស្រែកយំនឹង ចឹងហើយខ្ញុំនឹងដើរទៅទាំងសំស្រែកយំនឹង!!

ក៖ ហឹស...

ខ៖
កាលនឹងខ្ញុំនឹងមានដៃពពរកូននឹងផងហើយចឹងនិយាយទៅនឹងកាលនឹងបានស្លាប់កូននឹងចំនួន១នាក់ហើយកាលបានស្លាប់កូន១នាក់នៅឯវត្តចេក
ដែលបានស្លាប់កូនប្រុសនឹងបាន១នាក់ហើយនៅសល់តែកូនប្រុស១នាក់នឹងស្រី២នាក់នោះទេកាលនឹង។

គ៖ ហើយកាលនឹងគាត់បានស្លាប់ដោយសារអ្វីដែរទៅកាលនឹង?

ខ៖
ចាស!កាលនឹងគេនឹងបានស្លាប់នឹងដោយសារតែគេបានមាន់ជំងឺនឹងណាកាលនឹងអូថាវា.... ឈឺនឹងដោយសារតែវានឹងពិកបាកព្រោះអីអត់មានបាយនឹងទឹកអីនឹងកាលនឹងនោះ...

គ៖ ចុះកាលនឹងគាត់នឹងបានប៉ុណ្ណានោះហើយ?

ខ៖
យើងកាលនឹងវាប៉េកប៉ាកកាលនឹងណាមីអូនសុទ្ធតែពួកនឹងគេបានរត់ចឹងទៅណាទៅណាទៅនៃចឹងទៅកាលនឹងវាអត់មានដេកបានស្រួលនោះទេកាលនឹងដូចថាវាមានតែសំរែកដំរែកស្រែកនឹងទេ! ហើយចឹងទៅស្នាក់ទៅឯនេះតិចទៅ
ទៅឯនោះបន្ទិចចឹងទៅវាក្តៅវាបានតែដេកនៅកន្លែងលំហាវានឹង!វាមិនបានស្រួលនោះទេកាលនឹងចឹងហើយគេនឹងក៏បានឈឺស្លាប់បាត់ទៅចឹងកាលនឹងនោះ។
ហើយចឹងបានឥឡូវនឹងបាននៅសល់កូន២នាក់ទេហើយចឹងកាលនឹងខ្ញុំនឹងបានរែកអោយកូនហើយអោយកូន១នឹងបានដើរហើយកូន១ទៀតនឹងដើរហើយពរវាទៅនឹងមានរែកអីផងនឹងចឹង! ពេលដែលបានចុះទៅដល់កន្លែង១នឹងគេនឹងបានថា
សូមអោយឪម៉ែនឹងសំរាកនៅកន្លែងនឹងចឹងសិនហើយចាស!
ខ្ញុំនឹងក៏ពពួកខ្ញុំនឹងកាលនឹងបាននៅនឹងតែប៉ុន្មានគ្រួសារនោះទេកាលនឹងចឹងទៅគេនឹងក៏បានអោយយើងនឹងសំរាកទៅកាលនឹងវាបានជារាបនឹងភ្លឺដែលហើយកាលនឹងនោះចឹង!!

កៈ អឹស....

ខៈ
ចាស!ដល់ពេលចឹងទៅកាលនឹងខ្ញុំនឹងក៏បានមើលឃើញតា១នាក់ដែលគាត់នឹងវាមានរាងចាស់ហើយគាត់បានដើរទៅកាប់ដីកាប់បោះៗហើយចឹងខ្ញុំនឹងក៏បានដើរទៅជិតគាត់ទៅហើយគាត់បានថាចៅអើយមានអីៗនឹងចែកហូបអោយអស់ទៅតែបន្តិចទៀតនឹងគេបានប្រមូលទៅអស់ហើយ!
គេបានប្រមូលអោយអស់ហើយចឹងទៅពេលដែលខ្ញុំនឹងបានមកវិញនឹងខ្ញុំបានចែករំលែកហើយកាលនឹងគេនឹងមានបានធ្វើជាស្បៀងនោះ
ស្បៀងនឹងអោយយើងនឹងមានអំបុកមានអង្កអីនោះតែបន្តិចបន្ទួចដើម្បីនឹងអោយយើងនឹងបានហូបអីខ្លះពេលដែលយើងនឹងបានធ្វើដំណើរទៅនោះ!

កៈ ហឹស....

ខៈ
ចាស!ថាពេលនឹងគេបានអោយយើងនឹងបានចេញចឹងទៅគេនឹងបើអោយអង្កយើងនឹងវិញចឹងណា។(គាត់បានប្រាក់ចៅគាត់អោយចេញទៅក្រៅ)

គៈ អត់អីទេអ៊ុំបើគាត់ចង់ស្ដាប់អោយគាត់នៅស្ដាប់ដែរទៅ!

ខៈ ហែសអត់ទេអោយវានឹងបានចេញទៅក្រៅទៅកុំអោយនឹងបានរញ៉េរញ៉ៃ។
ចាស!ដល់ពេលហើយចឹងទៅស្រាប់តែអូនខ្ញុំនឹងក៏បានប្រាប់
ហើយនឹងចឹងខ្ញុំនឹងបានត្រាំអង្កនឹងប្រហែលជាបាន៣០គីឡូហើយទៅកាលនឹងគេនឹងក៏បានប្រាប់មកវាណេលនាងឯងមានចឹងអោយលាក់ទុកនៅឯគុមចេកលាក់នៅកន្លែងណានឹងខ្លះទៅ!
តែបន្ទិចទៀតនឹងគេបានដើរប្រមូលយកទៅអស់ហើយគេមិនបានអោយយើងនឹងមានអង្កស្លឹកក្រៃអីនោះទេឬក៏មានអំបិលអីនឹងនៅឯក្នុងខ្លួននោះទេ!គឺគេត្រូវតែយកទៅឯសមហាភាពអស់ហើយ!

កៈ ហឺ....

ខៈ ចាស!ចឹងហើយនឹងចឹងក៏ខ្ញុំនឹងបានយកអំបិលនឹង
នឹងខ្ញុំនឹងបានត្រាំអង្កនឹងយកទៅលីងហើយយកទៅធ្វើដូចជាអង្កលីងចឹងណា!

បានតែ១សាក់កាដូនឹងចឹងហើយក៏យកទៅលាក់សំរាប់នឹងទុកអោយកូននឹងវាបានហូបដល់លពេលហើយនឹងអូអើយគេបានដើរមកប្រមូលមែនអូនអើយ
គេបានដើរមកប្រមូលយកទៅអស់ហើយមិនបានប៉ុន្មានគេនឹងក៏បានដើរទៅប្រមូលអស់រលីង។ ហើយចឹងគេពេលនឹងគេបានហៅយើងនឹងបានទៅប្រជុំគេថាមើលប្រជាជនណាមានកូនធំប្រជាជនណាដែលមានកូនធំនឹងគឺត្រូវទេទៅឯសមហាភូមិមុខចំណែកឯប្រជាជនណាដែលមានកូនតូចៗគឺត្រូវនៅសមហាភូមិក្រោយ។
ហើយដល់ពេលចឹងកាលនឹងខ្ញុំនឹងវាបានកូននឹងវារាងបានធំៗដែលហើយចឹងទៅក៏គេនឹងបានអោយខ្ញុំនឹងទៅសមហាភូមិមុខ។
ហើយពេលដែលបានទៅសមហាភូមិមុខនឹងគេបានប្រើយើងនឹងអោយច្រូតកាត់ហើយគេបានធ្វើជាជុំរុំអោយយើងនឹងណាគេបានហៅយើងនឹងអោយទៅប្រក់ជាដំបូងនឹងណាហើយចឹងទៅបានអង្កដែលមាន១សាកាដូនឹងណាដែលកាលនឹងខ្ញុំបានយកវាទៅលាក់ទុកនៅនឹងចំបើងនឹងទៀត។
ដែលកាលនឹងខ្ញុំនឹងបានលាក់វានឹងនៅឯចំបើងនៅឯក្បែរកន្លែងដែលខ្ញុំនឹងបានដេកនឹងណាចាស!ហើយចឹងស្រាប់តែ...ចាស!

ក៖ ចាសអ៊ុំ!

ខ៖ ចាស!ដល់តែពេលហើយទៅនឹងខ្ញុំក៏នេះទៅណាអូន
មានម៉ោងគេនឹងគេបានអោយយើងនឹងបានទៅច្រូតណាអូនពេលដែលគេនឹងបានវ៉ៃជាសំលេងជួន១គឺគេបានហៅអោយយើងនឹងបានឡើងក្រោកឡើងនឹងទៅរៀបចំតវ៉ាន់ចាស!
ជួង២គឺគេបានអោយយើងនឹងបានទៅឈរតំរង់ជាជួរចាស!ហើយដល់ពេលដល់ជួងទី៣គេបានអោយយើងនឹងចាប់ផ្ដើមចេញដំណើរនឹងណាចាស!
ហើយគេនឹងបានអោយយើងនឹងបានចេញដំណើរនឹងគឺគេបានអោយយើងនឹងបានចេញដំណើរនឹងទៅច្រូតនឹងណាកាលនឹងនោះហើយដល់ពេលនឹងខ្ញុំនឹងក៏ហើយដែលខ្ញុំនឹងបានចូកអាបាយក្រៀមយើងនឹងណា!
បាយក្រៀមនឹងបាន១កូនកែវៗអោយទៅដល់កូននឹងវាបានហូបនឹងណាហើយទៅកូនៗរបស់ខ្ញុំនឹងវាបានទំពាល់បាយក្រៀមនឹងដែលបានក្នុងទឹកចូលក្នុងកែវនឹងតាំងយប់នឹងណាតាំងពីម៉ោង៩យប់នឹងណាឡើងគ្រឹមៗៗនឹងណាគេបាននាំគ្នានឹងអង្គុយហូប..

ក៖ ចាស!

ខ៖ ហើយយើងនឹងបានដាស់កូនរបស់យើងនឹងកាលនឹង
ហើយណេសពេលដែលយើងមុននឹងបានចេញទៅសមហាភូមិ
យើងៗអោយបាយក្រៀមនឹងអោយដល់កូនហើយកាលនឹងខ្ញុំមានកូន២នាក់នឹងបានអោយវានឹងហូបបាយនឹងទៅកាលនឹងនោះ។
ហើយកូនពៅរបស់ខ្ញុំនឹងកាលនឹងអោយវានឹងទំពាល់ឡើងលីសូវគ្រឹមៗៗៗហើយសព្វថ្ងៃនឹងវានៅឯបន្ទាយមានជ័យឯណោះ។
ចឹងហើយកាលនឹងគេនឹងមានជួងគេហើយចឹងពេលដែលយើងនឹងមានបានលឺជួងទៅ១នឹងហើយគឺគេបានអោយយើងនឹងត្រូវរៀបចំកន្លែងសំរាប់នឹងដេក។
ជួងទី២គេបានអោយយើងនឹងឈរត្រង់ជួរហើយបើជួងទី៣គេបានអោយយើងនឹងចេញដំណើរនឹងទៅចាស! ចាសនឹងគឺគេបានកំណត់មកអោយយើងនឹងចឹងឯងចាស!
ចឹងទៅគេនឹងបានអោយយើងនឹងទៅច្រូតកាត់នឹងចឹងទៅពេលដែលបានទៅច្រូតស្រូវហើយនឹងហើយគេបានអោយយើងនឹងបានមកបោកស្រូវទៀតនឹងចាស!ដល់ពេលថ្ងៃច្រូតហើយដល់ពេលយប់ឡើងនឹងបោក!

គ៖ ចឹងអ៊ុំ!

ខ៖
ចឹងនឹងហើយកាលនឹងគេបានប្រើយើងនឹងណាកាលនឹងគេនឹងមិនបាននឹងអោយបាយអោយយើងនឹងសំរាប់នឹងបានហូបឆ្អែកនោះទេគេប្រើអស់ហើយ
ហើយថាកាលនឹងពេលដែលគេនឹងបានអោយយើងនឹងហូបវាមិនបានឆ្អែកនឹងហើយព្រោះអីបើថាគេនឹងបានអោយបាយនឹងមកយើងហូបចឹងកាលនឹងបានតែ២វែកនោះទេហើយ១វែកៗនឹងគេចូកអោយយើងនឹងមិនបានណែងទៀតន៎ណា! ហើយស្រូវនឹងសុខចិត្តទុកចោលណារបបនឹងអោយយើងនឹងបានតែ២វែងនឹងហើយនឹងស្រាប់តែវាជ្រួយបាយនឹងមិនអោយបានណែងនោះទេកាលនឹងវាអោយយើងនឹងបានស៊ីតែតិចៗនឹងតែវានឹងបានប្រើយើងនឹងដូចជាក្របីនឹងសត្វគោខ្ញុំប្រាប់!
បានខ្ញុំនឹងចង់ចាំនឹងវាមិនបានភ្លេចនោះទេទោះបីជាខ្ញុំនឹងបានស្លាប់ទៅ៥ជាតិនឹងក៏ខ្ញុំនៅតែចង់ចាំដែរ!មិនភ្លេចជាដាច់ខាតនៅឯសម័យពពតនឹងវាសាហាវណាស់។

គ៖ ចុះអ៊ុំបានធ្វើការងារនឹងទាំងថ្ងៃនឹងទាំងយប់នឹងចឹងតើ.....

ខ៖ ចាស!

គ៖ ចឹងអ៊ុំបានដេកបានប៉ុន្មានម៉ោងទៅក្នុង១យប់?

ខ៖ ហាល
ដល់ពេលយប់ឡើងនឹងទៅដល់ពេលម៉ោងបាន៩អីនឹងគេបានអោយយើងនឹងបានចប់ពីការងារហើយអោយយើងនឹងបានដេកទៅកាលនឹងគេនឹងមិនបានទៅយើងនឹងបានដេកស្រួលនោះទេកាលនឹងនោះ
គេមិនបានគិតថាការដេករបស់យើងនោះទេកាលនឹងនោះព្រោះអីគេមានពាក្យគេនឹងនិយាយថាមហាលោភផ្លោះនឹងមហាស្អីគេន់ មហាលោភផ្លោះនឹងមហា....

ក៖ មហាលោភផ្លោះមហាអស្ចារ្យ!

ខ៖ គេថាមហាហោភផ្លោះមហាលោភផ្លាញអីគេនោះណ់!

ក៖ ហេសៗៗពាក្យស្លោក!

ខ៖ អឺចឹងទៅណ់!ចាស!ហើយគេនឹងបានថាត្រូវធ្វើស្រូវនឹងអោយបាន៦ទៅ៧តោនអីន់។ ចាស!ហើយខ្ញុំបានច្រូតនឹងបានកាត់អីចឹងហើយនឹងកាលនឹងហើយចឹងកាលនឹងបានប្រាប់ថាវានឹងបានវេទនាហើយថ្ងៃមួយនឹងណានឹងប្តីរបស់ខ្ញុំនឹងគេបានយកទៅវៀតណាមនឹងហើយនឹងណា!ខ្ញុំនឹងបានទៅច្រូតណា ហើយគេនឹងបានមកស្នើរដល់ខ្ញុំថាអោយបងឯងនឹងអោយទៅមេកងព្រោះអីកាលនឹងមេកងគេនឹងគេបានស្រលាញ់ដល់ខ្ញុំហើយកាលនឹងខ្ញុំនឹងមានអាយុបាន៣០ឆ្នាំ។ខ្ញុំនឹងបានថាហឹមកស្នើខ្ញុំម៉េចបងយ៉ាន!ខ្ញុំមិននៅទំនេរនោះទេខ្ញុំមានប្តីហើយ! ហើយចុះប្តីរបស់បងឯងនឹងទៅណា?
ហើយខ្ញុំនឹងក៏បានឆ្លើយឡើងថាប្តីរបស់ខ្ញុំនឹងគាត់ពួកយួននឹងគេបានចាប់គាត់នឹងបានទៅបាត់ហើយ។ ដល់ចឹងកាលនឹងចឹងទៅគេនឹងបានថាប្តីរបស់បងឯងនឹងមិនស្លាប់នោះទេប្តីបងឯងនឹងមិនស្លាប់នោះទេខ្ញុំអាណិតណាស់!
ពេលដែលបានយប់ឡើងនឹងគាត់បានស្ងោរជំឡូងចឹងណា
ហើយគាត់បានដឹងថាខ្ញុំនឹងមានកូន២នាក់នឹងខ្ញុំមាន១ទៀតនឹងមានដល់ចឹងហើយទៅកាលនឹងគាត់នឹងបានយកមកអោយខ្ញុំនឹងបាន១នាក់១ដុំអោយណាកាលនឹងគាត់បានយក៣មកអោយ។
ចាស!យប់ឡើងនឹងខ្ញុំនឹងបានជំឡូងនឹងបានមកអោយកូនរបសខ្ញុំនឹងបានមកញ៉ាំទៀតនឹង!អើយ!វាវេទនាណាស់មីអូន! ក្រោយមកនឹងនិយាយពីរឿងរបស់ខ្ញុំនឹងបានទៅនៅឯស្រុកគេនឹងពីព្រៃស្រែអូនមកឯព្រៃព្រៃលណា

គេបានលើប្រពន្ធព្រៃស្រែដែលជាប្រពន្ធរបស់ពួកយើងនឹងបានធ្វើនឹងទាំងអស់។ ចាស!ដល់ពេលថ្ងៃក្រោយមកនឹងខ្ញុំនឹងបានទៅស្នើរគេថាខ្ញុំនឹងអត់យកទទួលគេចឹងទៅណា ថាអត់ទទួលទេ...(និយាយប្រាប់ថៅគាត់ថា ស៊ីទៅបើភ្លើងណាថៅ ទៅបើភ្លើង) ហើយដល់គេបាស្នើខ្ញុំចឹងហើយអត់បានយកគេចឹងទៅណា កាលនឹងខ្ញុំអត់បានយកគេចឹង។ ស្រាប់តែអូនឯពេលនឹងយួននឹងវាមកជិតដល់ហើយ!

ក៖ ហឺ!

ខ៖ វៀតណាមនឹងវាបានស្រាប់តែសំរុកមកនឹងមកតាមផ្លូវនឹងវានៅតាមផ្លូវរត់មកចឹងណា!

គ៖ ហើយអានឹងវាជិតដាច់ហើយណេសអ៊ុំ?

ខ៖ ចាសៗជិតបានបែកហើយ!
ស្រាប់ដល់ពេលចឹងទៅគេនឹងបានថាអឺ....អោយខ្ញុំនឹងបានទៅរែកទឹក
រែកទឹកនឹងសំរាប់នឹងបំរើដល់អង្គភាព
ដូចថាគេមានធ្វើប្រពន្ធនឹងធ្វើស្រែចឹងទៅគេនឹងបានអោយយើងនឹងបានរៀបចំបាយទឹកអីសំរាប់ដល់គេចឹងទៅណា។ ចាស!ហើយខ្ញុំនឹងមានឧកាសបានទៅដល់ឯព្រៃស្ពឺ
ព្រៃស្វាយនៅឯយើងនឹងនៅឯបាត់ដំបងនឹងណា
នៅឯអាងព្រៃស្វាយនឹងខ្ញុំបានទៅរែកទឹកនៅឯទីនុង។
ដល់ពេលបានទៅរែកទឹកនៅនុងគឺខ្ញុំបានរែកទឹកនឹងពេលព្រឹកឡើង២ជើងនឹងដល់ពេលថ្ងៃឡើងនឹង២ជើង។

ក៖ ហឺស!

ខ៖ តែខ្ញុំនឹងមានសិទ្ធិ! ដូចថាបានចូលទៅឯកសិដ្ឋានណាអូន!
ដូចថាពេលនឹងអានឹងគេបានហៅថាកសិដ្ឋានណា!ចាស!ហើយពេលនឹងបានទៅចូលនៅឯកសិដ្ឋាននឹងពេលនឹងខ្ញុំនឹងបានទៅចូលទៅប៉េះបន្លែអីនឹងសំរាប់ដាក់នៅក្នុងថុងមកទុកហើយទៅអាខ្លះចឹងទៅខ្ញុំបានយកវាទៅស្ងោរអោយឆ្អិនចឹងទៅហើយអាខ្លះនឹងនៅស្រស់ហើយចឹងខ្ញុំក៏បានយកទៅដាក់នៅឯក្នុងថុងឡើងលឺឋិកងក់ៗ!ចឹងតែខ្ញុំ
បានបាយនឹងបានពេញចាននោះទេ!

ក៖ ហឺស....

ខ៖ ចាស!ខ្ញុំនឹងកាលនឹងបានបាយហូបនឹងបានពេញចានស្មើនឹងប្រជាជនរបស់គេ។ ចាស!ប្រជាជនរបស់គេនឹងកាលនឹងបានបាយតែ១ចានទេតែចំណែកឯយើងដែលមិនមែនជាប្រជាជនរបស់គេវិញដែលជាអ្នកដែលត្រូវជំលៀសមកនឹងគេបានអោយបាយដល់យើងតែ២វែកនោះទេ។ ក៏ប៉ុន្តែបើសិនជាកុមារនឹងគេបានអោយតែ១វែកនោះទេ....

ក៖ ហឹស....

ខ៖
ហើយទៅចាស់ដែលថាបានមើលកូនរបស់ខ្ញុំនឹងក៏បានតែ២វែកដែល!(គាត់បាននិយាយប្រាប់ចៅរបស់គាត់ថាចៅ ចៅឯទៅទិញនំប៉ុងអោយ២មក
មានសំលេងគេអ្នកលក់នំប៉ុងនំប៉ុងៗ)ចាស!ខ្ញុំប្រាប់ដល់អូនឯងចាស!

(សំលេងចៅគាត់ថាយាយទិញនំប៉ុង) កាលនឹងម៉ែបានមើល
ហើយម៉ែបានមើលម្ដាយក្មេងរបស់ខ្ញុំដែលបានមើលកូនអោយខ្ញុំនឹងគាត់បានបាយតែ២វែកនោះទេកាលនឹងហើយវារាងជ្រួយៗនឹងណា ហើយកូនពៅ
ហើយកូនៗរបស់ខ្ញុំនឹងគេបានម្នាក់តែ១វែកនោះទេ
ហើយចំណែកឯអ្នកដែលបានធ្វើការងារពេញសិទ្ធិនឹងបានតែ២វែកនោះទេបានតែគេទៅកាប់ដីអីនឹងគេបានតែ២វែកនោះទេ! ហើយសំរាប់ឯខ្ញុំនេះវិញដែលខ្ញុំបានទៅវែកទឹកណា
វាបានប្រៀបបីដូចជាប្រជាជនចាស់ចឹងដែលគេបានមើលឃើញណា!ចាស!
ចាសគេបានថាយើងនឹងវារាងសកម្មនឹងការងារដល់ចឹងទៅគេនឹងបានអោយយើងនឹងបានបាយនឹងទឹក បានបាយ១ចាន ចាស!

ក៖ ហឹស...

ខ៖
ចាស!កាលនឹងខ្ញុំបានបាយ១ចានកាលនឹងហើយកាលនឹងអូនអើយខ្ញុំនឹងវាមិនបានហ៊ាននឹងហូបអស់នោះទេអូនអើយ! ខ្ញុំវាមិនហ៊ាននឹងហូបអស់នោះទេហូបបានតែលុមៗតិចទេ
យកបាយនឹងមកបបរជាមួយនឹងបន្លែកប៉ុង!

ក៖ ហឹស!

ខ៖ បន្លែកប៉ុងដែលយើងនឹងបានប៉េះមកពីព្រៃស្វាយនឹងណាហឺស! យកមកបបរមកជាមួយនឹងឆ្នាំងតែដូចជាយើងនឹងស្លចឹងណាដាក់អំបិលប្រែៗទៅណាហើយបានយកអោយកូននឹងវាហូបទៅអូនអើយ!

ក៖ អូស....

ខ៖ ដល់ពេលថ្ងៃឡើង យើងបានទៅងូតទឹកណា! ពេលដែលយើងនឹងបានទៅងូតទឹកចឹងទៅយើងបានទៅចាប់ឯខ្ទៅណាដែលខ្ទៅនឹងវាបានទៅទុំនៅនឹងអាសំបកស្លឹកឈើចឹងណា!ហើយកាលនឹងបានរើសបានខ្ទៅ១យកមកល្បៀងនឹងយកវាមកសំរាប់ស្ល
ហើយពេលស្លនឹងយកវាមកធ្វើនឹងបង់ជាមួយនឹងស្លឹកផ្លី!កាលនឹងណាមានតែអុំនឹងទេដែលមានតែស្លឹកផ្លីនឹងណា!មានតែអុំនឹងទេដែលមានស្លឹកផ្លីនឹងសំរាប់នឹងហូបចាស!
ចឹងកាលនឹងមានតែអុំនឹងទេដែលបានទៅចូលដល់កសិដ្ឋានយកវាបានហូបនឹងណា
ហើយក្រៅពីនឹងគេអត់បាននោះទេ!(និយាយប្រាប់ដល់ចៅថាអោយយកទៅបងស៊ីចៅ
យកទៅអោយបងស៊ីចៅ!) ខ្ញុំប្រាប់អូនឯកាលនឹងវាមិនស្រួលនោះទេ!

ក៖ ហឺស...

ខ៖ កាលនឹងមានតែខ្ញុំនឹងទេដែលមានបាយបានច្រើនចាស!
ចាសកាលនឹងវាបានបាយចឹងនឹងបានច្រើនៗ(មានចៅមកជិតហើយគាត់ប្រាប់ចៅចាសមកយកវាទៅទិញ៣ដើមមក ទិញ៣ដើមយកទៅទិញ៣ដើមមកអាអូន
នាងនេះទិញនំប៉័ងនេះនឹងណានេះយកទៅទិញបើសិនជាវាបាន១ដើមនឹងតំលៃ៣០០០រៀល
យកទៅទិញ៣ដើមមក
អោយគេចឹងទៅ)ចាស!អូនឯដឹងទេកាលនឹងបានបាយឆ្អែកនឹងគឺបានដោយសារតែខ្ញុំនឹងទេកាលនឹងព្រោះអីកាលនឹងខ្ញុំនឹងបានរែកទឹកនឹងដាក់នៅក្នុងអង្គភាពនឹងណាចាស!
បន្ទាប់មកទៀតនឹងគេបានថាហូស!.....!ឥឡូវនឹងឈប់!
ឈប់នៅឯទួលសង្គនឹងហើយ!យើងត្រូវទៅមុន!យើងត្រូវឡើងទៅលើនឹងអោយអស់!
នៃលកាលនឹងអ្នកដែលមានកូនតូចៗនឹងគឺគេបានអោយទៅលើចំណែកឯអ្នកដែលមានកូននឹងវារាងបានតូចៗនឹងវិញនឹងគេបានអោយនៅខាងក្រោមចឹងណា។
ហើយចឹងទៅកាលនឹងស្រាប់តែមានអីអូនអើយ!កាលនឹងគេបានអោយយើងនឹងទៅបញ្ជូនយើងនឹងទៅតាមផ្លូវនឹងទៅ២ថ្ងៃហើយនឹងនៅវាមិនទាន់បានទៅដល់នៅក្នុងព្រៃនោះទេ!មិនទាន់

បានទៅដល់ក្នុងព្រៃនោះទេកាលនឹងគេនឹងបានបញ្ជូនយើងនឹងទៅហើយ។ គេបានថាអោយយើងនឹងបានចេញឆ្ងាយពីផ្លូវជាតិនឹងចំនួន៥គីឡូ។ ដើម្បីអីកាលនឹងដោយសារដើម្បីអោយឡានគេនឹងបានបើកចូលទៅក្នុងឯភ្នំពេញនឹងណា។ ចាស!ឡានកាលនឹងបានបើកចូលនៅឯទីក្រុងភ្នំពេញនឹងប្រហែលជាបានប្រហែលជា២០០ឡានអូន!.

ក៖ ហឺ....

ខ៖ កាលនឹងឡានសីបគេរាងពណ៌សៗណាហើយចឹងកាលនឹងខ្ញុំនឹងវាចេះតែឆ្ងល់ថាគេនឹងចេះតែផ្លោងគ្រាប់នឹងឡើងលីស្វរគ្គុងគ្គាំងៗចឹងទៅកាលនឹងព្រោះអីគេចឹងចង់បើកផ្លូវក្នុងការបើកឡាននឹងចូលទៅទីក្រុងភ្នំពេញនឹងចឹងណាអូន! តែកាលនឹងយើងកាលនឹងវាមិនបាននឹងដឹងថាវាឡាននឹងគេនឹងបើកទៅណាហើយគេធ្វើអីនោះទេកាលនឹងព្រោះអីពេលនឹងយើងបាននៅជា១នឹងពួកអាពពត។ ចឹងកាលនឹងយើងនឹងមិនបាននឹងបានដឹងអីគេទាំងអស់ហើយចឹងទៅកាលនឹងយើងមិនបានដឹងអីស្អីនោះទេព្រោះគេមិនអោយយើងនឹងបានដឹងអីទាំងអស់ ហើយចឹងកាលនឹងគេនឹងមិនបាននឹងអោយជាដំណឹងនឹងអោយយើងនឹងតែបន្តិចនោះទេ!ចាស!ដល់ទៅពេលនេះនឹងណា!ចាស! ដល់ចឹងទៅពេលនឹងគេនឹងបានថាអោយយើងនឹងបានទៅលើ អោយពួកយើងនឹងបានចូលទៅឯភ្នំចាស! ឡើងទៅលើ ចាស!ហើយពេលនឹងបានឡើងទៅនឹងស្រាប់តែនាំគ្នានឹងបានឡើងទៅលើនឹងទៅកាលនឹងស្រាប់តែអូនអើយបានដេកនៅឯផ្លូវនឹងចំនួន២យប់ នៅខាងលើគេនឹងណាចាស!

ក៖ ហឺ....

ខ៖ ចាស! ទៅនឹងវាបានវេទនាណាស់កាលនឹង។(ថៅៗបានប្រាប់ដល់យាយគេថាយកលុយទៅទិញគេនឹងបានទៅដល់ឯ២៥០០រៀលចឹងហើយពេលនឹងអ៊ុំក៏បានប្រាប់ដល់ថៅៗរបស់គាត់វិញថាអឺៗទៅទិញក៏ទិញចុះ ហឺ....)

កាលនឹងនៅក្នុងនឹងពេលនឹងជីវិតរបស់ខ្ញុំនឹងវាកំសត់ណាស់កាលនឹងនោះ វាកំសត់ណាស់ថៅអើយកាលនឹងនោះ។ តើវាបានកំសត់នឹងវាយ៉ាងម៉េចបើកាលនឹងយើងនឹងបានឡើងទៅលើនឹងចឹងកាលនឹងនោះ

ហើយខ្ញុំនឹងណាកាលនឹងនោះខ្ញុំមានខោអាវនឹងវាបាននៅល្អៗនឹងសំរាប់យកទៅដូរដល់ប្រជាជននៅពេលនឹងនោះ ខ្ញុំបានយកទៅដូរដល់ពួកប្រជាជនចាស់ៗនៅទីនោះដូរតាំងពីក្រមាហើយដូរបានជាអង្ករដូរបានជាបាយ
ហើយពេលនឹងគេនឹងបានអោយខ្ញុំនឹងនៅកន្លែងនឹងតែខ្ញុំនឹងកាលនឹងខ្ញុំមិនបាននៅឯទីនោះទេកាលនឹងខ្ញុំបានទៅឆ្ងាយពីគេដើម្បីអោយខ្ញុំនឹងបានដាំបាយយកទៅអោយកូនៗរបស់ខ្ញុំនឹងវាបានហូបឆ្អែក!!

កៈ ហឺ.....

ខៈ
ចាស!ខ្ញុំនឹងបានយកទៅអោយកូនរបស់ខ្ញុំនឹងវាបានហូបឆ្អែកហើយដល់ពេលដែលបានដល់យប់ឡើងនឹងណាខ្ញុំបានដាក់ដាំបាយហើយនឹងដល់ពេលដែលបាយវាបាននៅសល់នឹងអូនឯងបានដឹងដែរឬទេថាវាយ៉ាងម៉េចខ្លះ! ខ្ញុំនឹងបានយកទៅដាក់នៅក្នុងថុងណានៅក្នុងឯថុងទឹក!

កៈ ចាសអ៊ុំ!

ខៈ ហើយពេលនឹងយើងនឹងបានទៅរែកទឹកអាថុងនឹងហើយយើងនឹងបានដាំនឹងដាក់ភ្លើងនឹងទៅហើយយើងនឹងបានដាក់ដាំបាយនឹងហើយបានលីងនៅឯនឹងទៅណាកាលនឹងយើងបានដាក់វាសំរាប់នឹងលីងនៅឯនោះចឹងទៅណាលីងអោយវានឹងបានឡើងរាងស្ងួត!

(មានសំលេងចៅរបស់គាត់យំ!)

យើងលីងវាងនឹងទុកវាដល់ទៅអោយស្ងួតចឹងទៅនឹងកាលនឹងមានបាយអីចឹង!
ហើយកាលនឹងបាយនឹងខ្ញុំបានដាក់នៅក្នុងថុងនឹងចឹងហើយពេលដែលមានគេនឹងបានដើរមកឃើញចឹងហើយគេនឹងបានមកសួរថានោះ បាយអីនឹងមានភ្លើងអីចឹង? ខ្ញុំថាទៅគេវិញថាពុកៗអើយពុកថុងរបស់កូននឹងវាបានលេចហើយចឹងទៅឆ្អើរបិតជ័រកុំអោយវានឹងបានលេច!
តាមការពិតទៅកាលនឹងខ្ញុំនឹងបានដាក់លីងបាយទេ!

កៈ ហឺ.....

ខៈ ស្រពាំមៗទៅកាលនឹងសំរាប់អោយយើងនឹងបានយកទៅស៊ីនៅតាមផ្លូវនឹងណាចាស!
ខ្ញុំនឹងកាលនឹងវាមានដំរិះណាស់កាលនឹងបើនិយាយឡើង!ហើយអូនអើយកាលនឹងពេលដែលបានទៅដល់ឯនោះហើយកាលនឹងស្រាប់តែ....ស្រាប់តែបានទៅដល់នៅឯនៅខាងលើនឹង

ណាបានស្រាប់តែដល់ក្នុងព្រៃនឹងវាជាស្ថានដ្ឋានដែលថាស្ងាត់ណាអូនអើយ!
ហើយពួកវានឹងនឹងមានពួកយើងនឹងដែលបានចូលទៅដល់ប្រហែលជាបាន៥០០គ្រួសារចឹង
ហើយវាឡើងរង្គើលព្រៃឡើងរង្គើលព្រៃកាលនឹងហើយអីអូនអើយកាលនឹងគេបានយកយើងនឹងទៅលួចលាក់ព្រោះអីកាលនឹងពួកវៀតណាមនឹងវាបានមកជិតដល់ហើយ!

ក៖ អូ.....

ខ៖
ហើយកាលនឹងភ្នំពេញនឹងវាបានបែកហើយ!ចាស!ហើយស្រាប់តែដល់ចឹងទៅណាយ៉ាងរំពើមរង្គើលនៅក្នុងព្រៃនឹងហើយគេពេលនឹងបានបើសិទ្ធិសំរាប់ទៅយើងនឹងទៅដងទឹកនៅក្នុងព្រៃឡើង១ថ្ងៃកាលនឹងគ្រាន់តែទៅដងទឹកនឹង។
ហើយអូនឯកាលនឹងអូនឯមានបានដឹងអត់ថាកាលនឹងគ្រាន់តែបានទៅដងទឹកនឹងគ្រាន់តែគេនឹងអោយយើងនឹងទៅធ្វើជាជំរុំនឹងកាលនឹងខ្ញុំបានទៅរកនឹងយកអាសំបកឈើនឹងមកធ្វើជាកន្លែងសំរាប់ក្រាលដេក
ហើយមានធ្វើជាដំបូងហើយនឹងជញ្ជាំងអីចឹងទៅកាលនឹងព្រោះអីកាលនឹងគេបានអោយយើងនឹងធ្វើផ្ទះអីសំរាប់នឹងដាក់កន្លែងអោយយើងបានរស់នៅនឹងដោយខ្លួនឯងចឹងទៅកាលនឹង។
ដែលកាលនឹងវាមានរាងនឹងដូចជាខ្ទប់នឹងចឹងសំរាប់ដេកដល់ចឹងគ្រាន់តែទៅដងទឹកនឹងធ្វើខ្ទប់នឹងគេបានយកច្បាប់ដល់យើងនឹងបាន១ថ្ងៃសំរាប់នឹងធ្វើវាឡើងចឹងណាចាស!
ហើយគេបានអោយច្បាប់ដល់យើងនឹងចំនួន១ថ្ងៃទៀតសំរាប់នឹងទៅរកដងទឹកសំរាប់យកមកនឹង ហើយអូនអាយកាលនឹងគ្រាន់តែទៅដងទឹកនឹង!
គេបានអោយយើងនឹងទៅដងទឹកនឹងចំនួនបាន១ថ្ងៃទៀតនឹងអូនកាលនឹងខ្ញុំនឹងបានទៅដងនឹងជាមួយនឹងគេតែពេលមកវិញនឹងខ្ញុំនឹងវាបានវង្វេងផ្លូវទៅរកកូនអីណាមិនបានឃើញនោះទេអូនអើយ វង្វេងកូននឹងឡើងអស់រលីងអូន!ហើយកាលនឹងទឹកនឹងចំនួនបាន១ថុងនឹង
ថាទឹកក្នុង១ថុងនឹងកាលនឹងវាបាននៅសល់តែកន្លះនោះទេហើយទៅកូនរបស់ខ្ញុំនឹងកាលនឹងវាចឹង!កាលនឹងដោយសារតែយើងនឹងដើរទៅវាបានវង្វេងនៅឯកណ្តាលព្រៃហើយយើងបាននៅសល់តែទឹកកន្លះថុងដែលពេលមុននឹងបានដង់សំរាប់ពេញ១ថុងហើយក្រោយដែលខ្ញុំបានវង្វេងនឹងវាបាននៅសល់តែកន្លះថុងទេ។
កូនអើយណានឹងដល់ចឹងកាលនឹងខ្ញុំនឹងវាមិនបានដឹងធ្វើយ៉ាងម៉េចនោះទេ២នាក់ម្តាយនឹងកូននោះព្រោះអីវាបានវង្វេងនៅ
ឯកណ្តាលផ្លូវនៅឯក្នុងព្រៃនឹងចឹងទៅណាហើយអូនអើយកាលនឹងវាកាលនឹងចេះខ្ញុំនឹងបាន

ឡើងទៅលើដើមឈើហើយកាលនឹងបើថាពេលមើលឃើញថានៅកន្លែងណាវាមានផ្សែង ហើយចេះអីពេលនឹងខ្ញុំនឹងបានមើលឃើញផ្សែងនឹងចឹងខ្ញុំនឹងក៏បាននាំកូនរបស់ខ្ញុំនឹងបានដើរទៅ!

ពេលនឹងបានដើរទៅបនឹងបានដើរកាត់ព្រៃនឹងកាត់ផ្សែងទៅអូនអើយហើយក៏បានទៅសួរគេថា កន្លែងណាដែលជាកន្លែងពួកអ្នកជំរុំដែលគេទើបតែនឹងមកថ្មី

ដែលកន្លែងស្អីគេនឹងណាដែលមានជាកន្លែងត្បាលកិនកន្លែងស្អីចឹងទៅណា!

ចឹងហើយគេនឹងបានប្រាប់ថាហ្ហយ......!

បានដើរទៅនឹងវាហួសហើយវានៅឯខាងក្រោយឯនោះទេ!ដល់ពេលនឹងទៅកាលនឹងក៏បាននាំកូននឹងបានដើរបកក្រោយវិញទៅ។

ពេលនឹងបានដើរទៅដល់នឹងបានឃើញម្តាយក្មេកនឹងគាត់នឹងមកស្ទុះឡើងរឹងកាលនឹងព្រោះអីកាលនឹងគាត់បានអានិតកូននឹងវាបានបែកទៅនឹងកាលនឹងព្រោះអីនឹងកលានឹងថាវាបានបាត់កូនៗនឹងអស់ហើយមានកូនៗនឹងចាស!ហើយដល់ពេលចឹងទៅក៏បានមកចឹងទៅនឹងក៏បាននៅចឹងទៅណា!

ហើយដល់ពេលស្អែកឡើងអូនឯងបានដឹងឬក៏អត់ថា!កាលនឹងផលបុណ្យរបស់ខ្ញុំដែលខ្ញុំបានធ្វើកាលពីមុននឹងមកណាបានជួបតែល្អ

នៅឯសមហាភូមិមុខនឹងខ្ញុំបានជីកទឹកបាយបានឆ្អែកណា

ផលអកុសលនឹងផលបុណ្យរបស់ខ្ញុំកាលនឹងទោះបីជាខ្ញុំនឹងវាបានទៅដល់ឯក្នុងព្រៃខ្ញុំមានភូមិឋាននឹងស្ងាត់ក៏គេនឹងបានមើលឃើញខ្ញុំទៀតកាលនឹង

ពេលដែលបានមកដល់នឹងគេបានថាបងស្រីៗបងស្រីឯមកប៉េះបន្លែសំរាប់យកទុកសំរាប់នឹងហូបបាយនឹងបានអត់? (ចៅៗគាត់បានយំ

ហើយគេបានសួរទៅចៅៗគាត់ថាធ្វើអីចៅៗហើយចៅគាត់នឹងក៏បានប្រាប់មកវិញនឹងមកថាអត់មានធ្វើអីនឹងផង)ហើយក៏ពេលនឹងបានស្រាប់តែកាលនឹងមានដល់ពេលដែលបានទៅដល់ឯភ្នំនៅឯលើភ្នំនឹងចឹងណាកាលនឹងគេនឹងក៏បានប្រាប់ថាបងស្រីៗបងស្រីឯនឹងអាចនឹងប៉េះបន្លែសំរាប់នឹងស្លបានឬក៏អត់? ខ្ញុំនឹងក៏ថាបងអើយ

ខ្លួនរបស់ខ្ញុំ១ណាបងលើកលែងតែនៅឯរន្ធក្តាមដែលខ្ញុំនឹងវាបានរត់ចូលទៅនឹងវាមិនរចុះបើថាបងស្នើអ្វីក៏បានបើខ្ញុំនឹងធ្វើអោយបានខ្ញុំនឹងធ្វើជូនបងទាំងអស់ស្អីក៏ខ្ញុំនឹងធ្វើជូនបងទាំងអស់!

កៈ ហឺ...

ខ៖ ខ្លួនរបស់ខ្ញុំនឹងគឺខ្ញុំបានបូជាជូនទៅគណបក្សនឹងទាំងអស់!
ជូនដល់លអ្នកឯងនឹងទាំងអស់ព្រោះអីកាលនឹងយើងនឹងចង់សំដែងថាយើងនឹងវាស្មោះត្រង់ហើយអូនឯងកាលនឹងគេបានរើសបានគ្នាចំនួនបាន៣នាក់ទៅប៉េះបន្លែហើយកាលនឹងគេបានអោយយើងប៉េះបន្លែនឹងទៅដល់ឯនៅជើងភ្នំឯណោះកាលនឹងព្រោះអីបន្លែផ្អែមជួយជើងព្រិចអីគេនឹង!បន្លែផ្អែមនឹងពេលដែលបានប៉េះបានហើយចឹងនឹងអូនអើយខ្ញុំបានយកវានឹងទៅដាក់នៅឯនុងហើយបានជួបអ្នកនៅជិតស្ទឹងណាហើយកាលនឹងអូនអើយអាជ្រោះគេនឹងកាលនឹងមានស្ទឹងនឹងតែវាឡើងគោកឆឹង។អូនអើយ!

ក៖ អឺស....

ខ៖
ជ្រោះមានតែវាអត់មានទឹកនោះទេកាលនឹងហើយដល់ចឹងទៅកាលនឹងគេបានជីកជ្រោះនឹងដាក់ក្តារនឹងប្រវែងនឹងចឹងទៅហើយដើម្បីអោយវានឹងបានចេញទឹកនឹងមកបានតែបន្តិចៗនោះទេកាលនឹងហើយដល់ពេលចឹងទៅ!ខ្ញុំពេលនឹងបានមើលឃើញដូចថាពួកអ្នកដែលគេនឹងបានបបររទេះគោអីចឹងណាដែលគេនឹងបានសំរាកនឹងហើយខ្ញុំនឹងក៏បានសួមគេថាអើយ..បងឯងនឹងនៅប៉េះបន្លែទៅទុកអោយខ្ញុំនឹងទៅសុំបាយអោយគេអោយខ្ញុំនឹងបានទៅសុំបាយគេសំរាប់យកមកហូប។
ហើយពេលដែលខ្ញុំនឹងបានទៅដល់នឹងខ្ញុំនឹងក៏បានសូមគេថាពូអើយៗពូបាយក្តាងដែលនៅសល់នឹងពូហូបឬក៏អត់?ហើយគាត់បានឆ្លើយវិញថាគាត់អត់ហូបទៀតផងចឹងបងឯងនឹងយកទៅ!ដល់ពេលចឹងខ្ញុំនឹងក៏បានទៅខ្វេសបាយនឹងមកដាក់ញ៉ូតមកបាន១ស្បោងនឹងបាន១ថ្នក់ក្រមាយើងនឹងណាមកចឹងទៅណា!ដើម្បីអីសំរាប់នឹងបានសំនេញនៅក្នុងខ្លួនយើងដើម្បីអោយវានឹងបានជាសមហាភាពនៅក្នុងខ្លួនដែលថាយើងនឹងបានទៅជា១នឹងគ្នានឹងណាចាស!ដល់ពេលនឹងអូនឯងនឹងបានដឹងដែរឬទេថា
កាលនឹងអូនខ្ញុំនឹងក៏បានបាយនឹងយកមកនឹងបានចែកគ្នាចឹងទៅណាយកមកចែកអ្នកនេះផងហើយអ្នកនេះផងចឹងទៅណា!!ចឹងផងនឹងពេលនឹងខ្ញុំបានថាចំណែកឯចំណែករបស់ខ្ញុំវិញនឹងខ្ញុំបានទុកសំរាប់នឹងអោយកូនរបស់ខ្ញុំ!ហើយគេពេលនឹងថាអត់ទេ ម៉ែរ៉ាន
អើយកុំព្រោះអីបើកាលនឹងយើងនឹងមានបាយអីចឹងខ្លាចគេនឹងថាយើងនឹងដើរសុំគេនៅតាមអង្គភាពអីចឹងណាចឹងគេវ៉ៃយើងនឹងចោលចឹងមិនបាននោះទេ!
ដល់ពេលនឹងទៅខ្ញុំនឹងក៏បានខំហូបបាយនឹងអស់ចឹងទៅណា
ដល់ពេលដែលបានទៅដល់នឹងអូនអើយគេបានបើរបបបាយអោយយើងនឹងបាន៧វែកណាអូ

នអើយណា!សំរាប់អ្នកដែលបានទៅប៉េះបន្លែនឹង
គេមានចែកបាយអោយយើងបាន៧វែកហើយសំរាប់អ្នកដែលគេបានទៅកាប់ឆ្ការព្រៃនឹងគេបានតែ២វែកទេបាយនឹងកាលនឹងអូន!ស្តាប់ទៅណាស់
កាលនឹងខ្ញុំនឹងវាបានមានផលបុណ្យណាស់កាលនឹងគេបានអោយបាយខ្ញុំបាន៧វែកគេនឹងបានចូកដាក់អោយឡើងចឹបៗអោយខ្ញុំនឹង
ហើយខ្ញុំកាលនឹងមានបាយក្តាងនឹងហើយនឹងកាលនឹងចឹងហើយបាយដែលបានមកក្រោយនឹងក៏បានយកទៅអោយដល់កូន
ប្អូនរបស់ខ្ញុំអោយម្តាយក្មេករបស់ខ្ញុំនឹងមានបងប្អូនដែលបាននៅឯជុំរុំនឹងជា១នឹងខ្ញុំដែលនោះ!

ក៖ អឺស...

ខ៖
ចាស!ចែកគ្នាបានហូបនឹងបានតិចៗចឹងទៅកាលនឹងហើយពេលនឹងយើងនឹងបានបែកនៅក្នុងថ្ងៃទី១
នៅថ្ងៃខែ៧មករានឹងណាតែខ្ញុំនឹងបានពេលនឹងបាននៅដល់ខែ៤ណាអូនអើយបានចូលឆ្នាំហើយនឹងក៏មិនទាន់បានបែកដែល កាលនឹងចូលឆ្នាំនឹងនៅឯក្នុងព្រៃណាកាលនឹងខ្ញុំនឹង!

គ៖ចាស!ចឹងកាលនឹងពេលដែលគេបានបែកហើយនឹងអ៊ុំនៅមិនទាន់នេះទៀត!

ខ៖ អាយ....!

គ៖ អូ.....

ខ៖
ពេលដែលគេនឹងបានបែកនៅឯភ្នំពេញនឹងហើយចឹងនឹងកាលនឹងខ្ញុំបាននៅឯក្នុងព្រៃនៅឡើយទេអូនកាលនឹងនោះ!

ក៖ អូ....

ខ៖
កាលនឹងគេបានអោយចូលឆ្នាំនឹងនៅក្នុងព្រៃណោះឯកាលនឹងគេបានអោយខ្ញុំនឹងទៅធ្វើការងារជួយកិនម្សៅអោយគេកាលនឹងព្រោះអីគេយកទៅធ្វើនំអើយ....អឹមដូចជានំពូនសសអីដែលគេធ្វើសំរាប់នឹងយកមកហូបនៅឯពេលបុណ្យចូលឆ្នាំនឹងចឹងណាកាលនឹងហើយកាលនឹងគេបានធ្វើនឹងយកទៅខជាមួយនឹងអំពៅអីចឹងទៅណាអូន!ពេលដែលគេនឹងយកទៅសំរាប់នឹង

ខអំពៅអីនឹងកាលនឹងខ្ញុំនឹងបានមើលគេទេកាលនឹងហើយពេលដែលថាគេធ្វើនឹងវានៅសល់ខ្ញុំនឹងដើរប្រមូល។ ខ្ញុំបានដើរប្រមូលនឹង
ហើយប្រាប់គាត់ថាម៉ែៗឡើងម៉ែ!ហើយម៉ែក្មេករបស់ខ្ញុំនឹងបានសួរដល់ខ្ញុំនឹងថាស្អី!កូន
ម៉ែអើយបបរល្ពៅបបរល្ពៅគេបបរល្ពៅអោយយើងនឹងបានហូប!ពេលនឹងគេបានធ្វើហើយនឹងបានថានៅសល់តិចៗចឹងណាហើយនឹងបានដើរទៅប្រមូលអាគេបាននៅសល់បន្តិចៗនឹងយកមកសំរាប់នឹងយកមកអោយម៉ែកូនៗនឹងបងប្អូនអីនឹងបានតិចៗម្នាក់ចឹងទៅកាលនឹង។
សូម្បីតែម្សៅកិនណាមីអូដែលគេកិនហើយវាបាននៅសល់អាក្អែរអង្កដែលវាបាននៅជាប់នឹងថ្មត្បាល់នឹងណាមីអូន ក៏អ៊ុំនឹងបានលាងវាដែរកាលនឹង!

កះ អឺសហឺ.....

ខះ
អ៊ុំបានលាងវានឹងសំរាប់នឹងទុកអោយវានឹងបានរងហើយពេលដែលវានឹងបានរងហើយនឹងអ៊ុំបានយកវានឹងទៅចាក់អាទឹកថ្លាៗនឹងចោលទៅនឹងណាហើយពេលនឹងអ៊ុំនឹងបានយកវាដែលបានទុកអោយរងនឹងហើយយកវានឹងទៅកូនដាក់ជា១នឹងស្លរយកទៅអោយកូននឹងបានហូបអោយវានឹងបានលិចចឹងទៅណាកាលនឹង!

កះ ហឺ...

ខះ
កាលនឹងអ៊ុំនឹងវាកំសត់ណាស់កាលនឹងអូនអើយ!ទៅដល់ពេលដែលបានទៅនៅឯក្នុងព្រៃនឹងហើយនឹងខ្ញុំបានបាយ៧វែកសំរាប់យកមកអោយកូនៗនឹងវាបានហូបអូនឯជួយគិតនឹងជួយពិចារណាគិតមើល!
កាលនឹងខ្ញុំនឹងបានយកអោយកូនៗរបស់ខ្ញុំនឹងបានអោយម៉ែក្មេកនឹងគាត់បានពិសារកាលនឹងចឹងកាលនឹងបាន៣នាក់នឹងដែលសំរាប់យកមកអោយកូនយើងបានហូប!ហើយពេលនឹងយើងបានទៅប៉េះបន្លែនឹងសំរាប់យកមកអោយ
ហើយគេនឹងបានអោយបានយើង៧វែកដែលព្រោះអីពេលនឹងគេបានថាយើងនឹងវាបាននឹងជិតដិតនឹងឯចង្រានបាយនឹងនា
ហើយដល់ពេលព្រឹលឹមឡើងនឹងគេបានអោយទឹកប្រហុកអោយយើងនឹងបានហូប
គេបានអោយសំរាប់នឹងគួរៗអោយជាមួយនឹងទឹកនឹងកាលនឹងហើយអោយបានគួរហើយយកវានឹងជ្រក់នឹងជាមួយនឹងបាយនឹងយកមកហូបទៅកាលនឹងហើយកាលនឹងវាឆ្ងាញ់ចង់នឹងងាប់

ហើយកាលនឹងអានឹងវាបានជាម្ហូបដែលពិសេសហើយសំរាប់នឹងយើងកាលនឹងហើយគេបាន អោយដើរទៅប៉េះបន្លែទៅជារាងរាល់ថ្ងៃដល់ពេលហើយនឹងពពួកគេនឹងចូលជិតមកដល់ហើយកាលនឹងហើយទៅចឹងវានឹងបានតិចនាំយើងនឹងទៅឯនេសតិចនាំយើងនឹងទៅឯណោះបានតិចចឹងទៅកាលនឹង!

កៈ ហឺ.....

ខៈ អូនអាយដឹងណែសតិចនាំយើងនឹងទៅខាងនេះតិចនាំយើងនឹងទៅខាងនោះ។ ចឹងទៅខ្ញុំនឹងក៏អើត រត់គេតៗនឹងពីគេចឹងទៅដើម្បីនឹងបានហូប។ ថ្ងៃមួយនឹងគេបានថាអោយខ្ញុំនឹងមិនបាច់នឹងដើរប៉េះឆ្ងាយនោះទេប៉េះអាដើមណែកស្លឹកជំឡូងមីនឹងយកមកអោយអង្គភាពហូបមក !

កៈ ហឺ.....

ខៈ ចឹងទៅអូនអើយពុលអស់មួយអង្គភាពនឹងបានពុលទាំងអស់មានបានពុលទាំងកូនរបស់ខ្ញុំទាំងកូនគេនឹងកាលនឹងហើយបានយកយើងនឹងទៅដេកឯក្នុងពេទ្រនឹងឡើងថ្លូរៗហើយគេបាននាំយើងនឹងទៅដេកឯពេទ្យគេនឹងគ្មានអីសំរាប់អោយយើងនឹងទេកាលនឹងមានតែយកទឹកមកកូរហើយដាក់ស្ករត្នោតយកមកអោយយើងនឹងលិច។

កៈ អូ!

ខៈ ចាស!កាលនឹងដូចថាគេបានយកស្ករត្នោតនឹងទៅកូរហើយអោយយើងនឹងមកលិចដូចថាស្ករនឹងគេបានយកវានឹងយកទៅកំលោចវាសិន កាលនឹង!ហើយគេបានអោយកូនខ្ញុំនឹង២នាក់យកទៅដេកឯពេទ្យហើយខ្ញុំនឹងនៅមើល។ ហើយបានឃើញប្រជាជនចាស់គេមានបាយសំលនឹងច្រើននឹងចឹងទៅណាហើយក៏ខ្ញុំនឹងក៏បានយកសំលៀកបំពាក់នឹងខ្លះៗយកទៅដូរ កាលនឹងបានយកទៅដូរគេដើម្បីអោយកូនរបស់ខ្ញុំនឹងវាបានហូបឆ្អែត។ កាលនឹងបានដូរគេនឹងព្រោះអីកាលនឹងទុកធ្វើអីកាលនឹងខ្ញុំបានដាក់ខោអាវនឹងទៅហើយខ្ញុំបានរៀបចំយ៉ាងស្អាត់បតដាក់នៅឯចានស្រាក់ចាស!

កៈ អឹស!

ខ៖ ចាស!

បតដាក់ចានស្រាកនឹងចឹងទៅហើយក៏បានខ្វេសដាក់ពីចានស្រាក់នឹងយកទៅដូរគេចឹងទៅកាលនឹង!កាលនឹងពេលដែលបានទៅដេកពេទ្យនឹងមែនតែកាលនឹងខ្ញុំនឹងវាជំរិះកាលនឹងបានយកខោអាវនឹងយកទៅដូរគេដើម្បីនឹងធ្វើយ៉ាងណាអោយកូនរបស់ខ្ញុំនឹងវាបានហូបឆ្អែកចាស! បន្ទាប់មកទៀតនឹងអូនអើយវាបានរឹករវល់ណា វាបានរឹករវនឹងកាន់តែខ្លាំងចឹងណា!អឺស! ដល់ពេលយប់ឡើងនឹងគេបានអោយយើងនឹងយាមណាកាលនឹងមាន៤នាក់ណាសុទ្ធតែស្រីៗដែរគេអោយយាមនឹង

ហើយស្រីៗពេលដែលបានដេកហើយគេអោយយាមនឹងបានដេកខ្នងនឹងទល់គ្នាចៀកចាស!

ក៖អូ!...

ខ៖

ចាស!កាលនឹងនៅក្នុងព្រៃណា!ហើយពេលដែលយើងនឹងអង្គុយបែកខ្នងចឹងគេមិនអោយយើងនឹងអង្គុយមុខគេនោះទេ

គេមិនអោយយើងនឹងបានអង្គុយទល់មុនគេនោះទេគេអោយយើងនឹងបានអង្គុយបែរខ្នងដាក់គ្នា

ហើយបើថាគេលឺយើងនឹងនិយាយគ្នាមិនបានទេហើយបើមាននរណាគេសួររកប្រធានកងអីនឹងកុំប្រាប់គេអោយ

សោះ!

ក៖ ហឺស....

ខ៖

ព្រោះអីកាលនឹងគេនៅឈរមុខនឹងដើម្បីនឹងដោះស្រាយបាយទឹករបស់យើងហើយបើថាបើគេនឹងរត់ចោលយើងទៅ

យើងនឹងមិនបានដឹងបាយទឹកឯណាមកហូបនោះទេ់!ចឹងហើយយើងកុំប្រាប់គេចឹងណាគេបានប្រាប់ណា!ហើយចឹងទៅអូនឯដល់ពេលនឹងកាលនឹងបើប្រាប់ទៅកាលនឹងវាភ័យហើយរត់ចោលយើងណាកាលនឹង

ហើយពេលចឹងកាលនឹងវានឹងបានភ័យហើយបានរត់ចោលយើងនឹងអស់ទៅអស់ចឹងណា!ចាស!

ក៖ ហឺស!

ខ៖ ចាស!ហើយពេលនឹងយើងនឹងក៏បានរត់មកគ្នាយើងនឹងអស់ទៅវិញចឹងទៅណា កាលនឹងយើងបានរត់មកឯអាយហើយ ពេលនឹងពួកវានឹងបានរត់ចូលទៅក្នុងព្រៃ។

ក៖ ហឺស!

ខ៖ ហើយចឹងកាលនឹងយើងមានទៅរត់ទៅតាមវាអីកាលនឹងយើងនឹងបានរត់មកនេះ!

គ៖ រត់មកនៃសវិញ!

ខ៖
អូនឯងកាលនឹងបានរត់មកឯអាយនេសវិញណា!ហើយពេលដែលរត់នឹងមកអូនឯងអើយស្រាប់តែរត់មកនឹងមិនមែនតិចប្រជាជននោះទេកាលនឹងប្រជាជននឹងវាមានឡើងកកព្រៃណា! ស្រាប់តែមានជួបនឹងយោងថាគេនឹងគេបានស្រែថាទៅឯណា? គេបានស្រែថាចឹងណា ថាទៅឯណា?
ហើយទៅកាលនឹងខ្ញុំនឹងបានប្រាប់បងអើយខ្ញុំ!នឹងវាបានវង្វេងហើយខ្ញុំវាមិនបានដឹងថាទៅណាមកឯណានោះទេបងអើយមិនដឹងថាទៅឯណានោះទេបង!
តែតាមពិតនឹងយើងមកឯជើងឯនេះទេណា! តែយើងនឹងប្រាប់ថាមកតាមត្បូង ហើយប្រាប់ថាមិនដឹងថាឯណាជើងត្បូងនោះទេ ហើយយើងបានចេញមករកឯព្រៃស្វាយ ហើយបានមកព្រៃស្វាយនឹងមករកអាស្អីនេះខាងជើងនេះផ្លូវ១ទៀតនឹងចាស!ស្រាប់តែ គេនឹងបានប្រាប់យើងនឹងវិញថា ទៅៗឯនោះន៎គេបានចង្អុល
គេបានចង្អុលអោយយើងនឹងបានទៅឯខាងកើត!
អីកាលនឹងគេបានចង្អុលអោយយើងនឹងបានទៅឯខាងកើតហើយពេលនឹងយើងនឹងចេះតែបានទៅឯខាងកើតនឹងទៅតាមគេចឹងទៅណា!ហើយដ៏ពេលដែលវានឹងបានទៅបាត់ចឹងទៅកាលនឹង

ចឹងបានមករកឯនេះវិញមកចឹងទៀត។ដល់ពេលចឹងទៅកាលនឹងអូនឯងបានដឹងដែរទេថាកាលនឹងមានអ្នកខ្លះទៅមានកូនស្លាប់!

ក៖ អូ....

ខ៖ កូនស្លាប់កូនជាប់បីនឹងខ្លួននឹងស្លាប់ហើយនូវតែរត់
ចេះតែរត់ទៅហើយពេលនឹងគ្មានអីសំរាប់ស៊ីផងហើយអត់មានថ្នាំសង្កូវអីមានពីកាលនឹងនោះ
។

ចឹងពេលនឹងកូននឹងវាបានងាប់ចឹងទៅក៏បានរុំវានឹងទៅដាក់នៅក្បែរនៅឯគល់ឈើចឹងទៅកាលនឹង។

ក៖ អូ.....

ខ៖
ចឹងទៅណាហើយកាលនឹងមីអូនអើយកាលនឹងនៅក្នុងព្រៃនឹងមិនអាសូរថាវាផ្លូវនឹងវាធំអីប៉ុណ្ណាកាលនឹងវាមានតែផ្លូវនឹងវាតូចចឹងនេស! តូចចឹងណានាំគ្នាដើរនឹងនៅ
ឯក្នុងព្រៃនឹងកាលនឹងវាមិនមានបានដើរកើតនោះទេកាលនឹងព្រោះអីកាលនឹងព្រៃនឹងវាចង្អៀតព្រៃនឹងវា....

គ៖ ព្រៃនឹងវាក្រាស់ណេសអ៊ុំ?

ខ៖ ចាស!ព្រៃនឹងវាស្អិតណា
មានកូនត្រែងអីចឹងទៅណាហើយចំណែកឯដើមឈើវិញនឹងមានអាណាទៅវាធំៗទៅហើយអាណាទៅវាតូចៗទៅកាលនឹងអើ
ហើយពេលស្រាប់តែចឹងអូនឯងពេលនឹងយើងបាននាំគ្នានឹងបានរត់ចេញមកហើយណាកាលនឹងស្រាប់តែយើងនឹងបានរត់ចេញមក។
ពេលដែលបានរត់ចេញមកដល់.....ខ្ញុំនឹងបានរត់ចេញមកដល់អាយ
ហើយក៏បានបាត់ម៉ែបាត់ឪអស់ហើយខ្ញុំបានបាត់ម៉ែក្មេករបស់ខ្ញុំ!

ក៖ ហឹស...

ខ៖
ពេលនឹងបានបាត់គាត់អីចឹងអស់ហើយណា!ដល់ចឹងទៅកាលនឹងម្ដាយនឹងគាត់បានយំអើយយំព្រោះអីបានបាត់កូននឹងទៅអស់បាត់នឹងវល់ល្ងាចចាស!
ស្រាប់តែដល់ពេលល្ងាចចាស!ពេលដែលបានយប់ទៅខ្ញុំនឹងបានមកដេកនៅឯសហាករងឬស្សីក្រាំងដែលខ្ញុំបានចាំណាមីអូន
ហើយកាលនឹងបានមកជួបជុំគ្នាវិញនឹងនៅឯសហាករនៅឯសហាករឬស្សីក្រាំងនឹងកូនឯង។
ម្ដងនឹងណាយើងបាននិយាយគ្នារួចហើយថាមានមេគេនឹងគេបាននាំមេគេនឹងគេបាននៅឯខេត្តព្រៃវែងណាអូនដែលគេបានមកនាំណា!ដែលកាលនឹងនៅឯខេត្តព្រៃវែងកំលោះនឹងដែលគេបាននាំមកនៅឯរាងវៃយកណ្ដាលនឹងគេបាននាំមកប្រាប់ថាឥឡូវនឹងគេបានប្រជុំថានៅក្នុងពេលយប់នឹងណាយើងត្រូវតែចេញអោយរួចនៅក្នុងយប់នឹង។

កៈ ហឺស!

ខៈ ចាស!ហើយយើងត្រូវតែចេញអោយរួចក្នុងពេលយប់នឹង
ដូចជាមានស្បៀងអីនឹងបើមានទាំងប៉ុន្មានអីនឹងបើមានត្រូវចោលខ្លះនឹងចោលទៅយើងត្រូវរត់
ដើម្បីអោយរួចពីខ្មាំងអោយបានរួចពីសត្រូវណាកាលនឹងអោយបានរួចពីពពួកវាណាព្រោះអីវា
នឹងយកយើងនឹងទៅទំលាក់ឯនៅក្នុងព្រៃឯជឹងដែរទេ?
.....អូ!និយាយថាកាលនឹងខ្ញុំនឹងបានទៅប៉េះបន្លែហើយកាលនឹងខ្ញុំនឹងបានរើសបានគ្រាក់ចឹង
ណាអូន!

កៈ អឺស!

គៈអឹម!

ខៈ ចាស!
គេថាក្នុងកងនឹងគេបានជុំនុំថានរណាគេនរណាគេរើសបានគ្រាក់ត្រូវសំលាប់អ្នកនោះចោល!

កៈ អើយ!....

ខៈ
អត់អោយឃើញនោះទេកាលនឹងចឹងអូនឯនឹងបានដឹងថាគ្រាក់នឹងវាជាស្អីដែរឬទេ?គ្រាក់នឹង
កាលនឹងគេបានធ្វើប៊ិនៗបាទដៃនឹងណាគេបានសរសេរជាអក្សរហើយគេបានដាក់ថា
ភ្នំពេញបានរំដោះហើយនៅថ្ងៃទី១ ៧មករា។

កៈ ហឺ.....

ខៈ
មានប្រជាជនប៉ុណោះៗចឹងហើយមានកុមារកំព្រាជាច្រើនដែលបានចូលមករត់ចូលមករណៈ
សេសង្គ្រោះជាតិរបស់យើងចាស!ចាស!ពេលដែលខ្ញុំបានឃើញគ្រាក់នឹងភ្លមនៅឯក្នុងព្រៃនឹង
ណាខ្ញុំបានស្ទុះព្រោកហើយខ្ញុំបានមើលឯនាយមើលអាយហើយខ្ញុំបានជាន់ជាប់
ហើយខ្ញុំជាន់នឹងខ្ញុំបានមើលគ្រែនលោលគេបានឃើញនឹងណា!

កៈ ចាស!

ខៈ ខ្ញុំបានយកគ្រាក់នឹងភ្លែកហើយខ្ញុំបានមុជចូលទៅឯក្នុងព្រៃហើយខ្ញុំបានមើលភ្លែក។

កៈ ហឺ....

ខ៖
គេនឹងបានដាក់ថាភ្នំពេញនឹងមានរំដោះនៅឯថ្ងៃទី៧មករាមានប្រជាជនអីដូចដែរខ្ញុំនឹងបាននិយាយចឹងណា!

ក៖ ចាស!

ខ៖ ខ្ញុំថាអូពុធ្លោខែ៩នឹងអញនៅព្រៃចុះគេនឹងបានរំដោះ....

ក៖ ហឺ...

ខ៖
គេនឹងបានរំដោះតាំងពីខែ៩ហើយអញនឹងវាបាននៅឯក្នុងព្រៃនឹងនៅឡើយណា!ខ្ញុំនឹងក៏ទៅដល់ផ្ទះវិញនឹងខ្ញុំបានប្រាប់ទៅដល់ម្ដាយក្មេករបស់ខ្ញុំនឹងហើយពេលនឹងម្ដាយក្មេងខ្ញុំនឹងគាត់បានបាត់កូន២ប្រុសយុវានារីណាដែលជាកូនប្រុស២នាក់នឹងដែលគេយកទៅបាត់ពីខ្លួនរបស់គាត់ចឹងហើយបានជាគាត់នឹងបានសោកសៅនឹងរាល់តែថ្ងៃណាកូន១នឹងទៅយួនណា!

ក៖ ហឺ....

ខ៖ ចាសកូនដែលបានទៅឯយួននឹងមាន៣នាក់មើល ២នាក់កូនប្ដីរបស់ខ្ញុំហើយ៣នាក់នឹងឌី!

ក៖ អេម...

ខ៖
នៅក្នុងគ្រួសារនឹងណា!ហើយដល់ពេលដែលមានកូននៅនឹងតាមខ្លួននឹងមាន២នាក់ដែលកងយុវានារីគេយកទៅនឹងហើយនឹងអាអូន១នាក់នឹងបានបាត់នៅឯក្នុងព្រៃទៀត។
គាត់នឹងបានឃ្លោតផ្សារដល់ចឹងទៅខ្ញុំនឹងក៏បានមកប្រាប់ឯម្ដាយរបស់ខ្ញុំនឹងថា
ថាម៉ែអើយម្ដាយភ្នំពេញគេបានបែកហើយម៉ែចុះហេតុអី
បានយើងនឹងនៅឯក្នុងព្រៃនឹងចឹង!គាត់នឹងបានប្រាប់ថាអឺកូនមែនក៏អីកូន?
ខ្ញុំក៏ប្រាប់ថានឹងហើយម៉ែ!ស្រាប់តែអូន
ឯងនឹងបានដឹងដែរឬអីពេលដល់ចឹងទៅដូចដែរខ្ញុំនឹងថាចឹងវាស្រាប់តែរឹករល់នឹងហើយមានគេនឹងរត់មក។
រត់មកដល់សហាករឬស្សីក្រាំងនឹងណាហើយសហាករឬស្សីក្រាំងនឹងគេបានជំនុំគ្នាពេលយប់ឡើងនឹងណា!ហើយអូនឯដឹងដែរឬទេកាលនឹងគេបានអោយយើងនឹងចេញតាំងពីម៉ោង១២យប់រត់ចេញពីព្រៃណាកាលនឹង!នៅម៉ោង១២យប់កាលនឹងខ្ញុំចាំណាស់អោយយើងនឹងរត់ចេញពី

ព្រៃរត់!ហើយពេលនឹងខ្ញុំនឹងបានប្រាប់ទៅម្ដាយក្មេករបស់ខ្ញុំនឹងថាម៉ែឯងត្រូវតែរត់មកអោយទាន់ខ្ញុំណា!ហើយកាលនឹងគាត់អត់មានយកទៅទេមានតែសកាដូ១ហើយខ្ញុំនឹងមានពរកូនតូច១ដែរហើយមីធំនៅតាមក្រោយកាលនឹងហើយខ្ញុំបានប្រាប់ថាម៉ែឯងណាត្រូវរត់អោយទាន់ខ្ញុំនឹងណាហើយបើសិនជាយើងនឹងបានរត់ទៅឯខាងមុខ
គេបានខាត់នៅឯខាងមុនខាងក្រោយនឹងនឹងត្រូវជាប់ហើយខាងមុននឹងរួចខ្លួនហើយ!ចឹងហើយម្ដាយឯងនឹងត្រូវរត់អោយទាន់ខ្ញុំ!

កៈ ហឺស.....

ខៈ
ខ្ញុំរត់!ខ្ញុំរត់ទាន់អ្នកដែលគេនឹងបាននាំផ្លូវណាអូនកាលនឹងមានអ្នកនាំផ្លូវខ្ញុំប្រហែលជាបាន២០ម៉ែត្រពីខ្ញុំនឹង!ហើយកាលនឹងពេលដែលបានរត់នឹងអូនឯងដឹងដែរឬទេកាលនឹងថាវានឹងបានបាញ់នឹងដូចបែកស្វរនៅឯពីក្រោយនឹងមក!!!

កៈ អូស!.....

ខៈ ថាវាបានលឺស្វរឡើងគ្លងគ្រាំងៗៗ វាបានផ្លោកគ្រ្គាំៗៗៗនឹង!!!!

កៈ កាលនឹងចឹងស្រាវណាស់អ៊ុំ!!

ខៈ ចាស! ហើយយើងនឹងបានរត់!
ហើយយើងនឹងបានរត់ចេញទៅនឹងពីខាងក្រោយនឹងលឺវាសំលេងកាំភ្លើងនឹងឡើងគ្លងគ្រាំងៗៗៗ!!!
វាផ្លោងគ្រ្គោងគ្រាំងអោយយើងនឹងមិនអាចនឹងចេញរួចនឹងណា!!ដែលវាមិនអោយយើងនឹងបានចេញពីក្នុងព្រៃនឹងណាចាស!ដល់ពេលហើយចឹងចឹងទៅ!កាលនឹងគេបានប្រាប់ថាអោយខ្ញុំរត់ៗអោយបានរួចចេញពីក្នុងព្រៃនឹងណា រត់បានហើយនឹង
គេប្រាប់ទៀតថាអោយយើងនឹងបានរត់អោយរួចចេញពីក្នុងអាង១៧មេសាអានឹងយើងបានរស់ហើយ!ចឹងខ្ញុំនឹងបានរត់តាមគេហើយចឹងកាលនឹងស្រាប់តែអូនឯងហើយឆ្លងផុតអាង១៧មេសា!យើងនឹងចេះតែរត់ទៅហើយកាលនឹងរត់កាត់គ្រាប់នឹងចេះតែរត់ទៅកាត់គ្រាប់អីនឹងងាប់ចោលទៅកាលនឹង!

កៈ ហឺសអើយអ៊ុំ!...

ខ៖
ចាស!វែកកូនវែកចៅកាលនឹងមិនមានតែយើងឯណាកាលនឹងមានគេមានឯងទាំងពេញព្រៃនឹងណាចាស!ងាប់ណា!

ក៖ ហឺ!

គ៖ ហឺ!

ខ៖
នឹងណាអូនកាលនឹងមានអាណាចឹងទៅក៏ងាប់ចឹងទៅវាបានងាប់ចោលទៅចឹង!ចាស!ហើយពេលដែលបានដល់អាង១៧មេសានឹងមកហើយនឹងអូនអើយទឹកនឹងហូរសុទ្ធតែឈាម!!

ក៖ អូយ!អ៊ុំអើយ!

ខ៖ ចាស!
ពេលដែលទឹកនឹងវាហូរនឹងវាមានសុទ្ធតែឈាមដែលយើងនឹងបានឆ្លងកាត់ទៅណាកាលនឹងចាស!ហើយបានមកនឹងប្រហែលជាបានកន្លះគីឡូណាអូនប្រហែលជាកន្លះគីឡូវអូនមកនឹងប្រហែលជាបានកន្លះគីឡូវនឹងក៏បានលឺសូរកាំភ្លើងនឹងបាច់៣គ្រាប់នឹងឡើងទុងៗៗៗអាអ្នកនាំមុននឹងដែលបាននាំខ្ញុំនឹងដែលពីខ្ញុំនឹងបាន២០ម៉ែត្រនឹងវាបានថយក្រាកមករកខ្ញុំណា!ហើយពេលនឹងខ្ញុំបានមើលទៅឯខាងក្រោយនឹងវាបានបាត់មនុស្សអស់រលីងមើលទៅខាងក្រោយនឹងបាត់មនុស្សអស់ចឹង។(មានសំលេងចៅគាត់ស្រែហើយគាត់ក៏បានប្រាប់ថាហោសសារណា!!)
ពេលដែលខ្ញុំនឹងមើលទៅឯខាងក្រោយចឹងទៅកាលនឹងបានបាត់មនុស្សអស់ចឹងស្រាប់ពេលនឹងក៏ខ្ញុំនឹងថាអូន អូនហេតុអីបានជាកូនឯងនឹងថយវិញ! បងឯងអត់លឺសូរគេបាញ់ទេអីហឹសៗ!បងឯងអត់មានលឺសូរគេបាញ់នោះទេនៅឯមុននឹងនោះ?

ក៖ ហឺស....

ខ៖ ខ្ញុំនឹងក៏បានថានែកអូនយើងទៅមុខក៏ស្លាប់ទៅក្រោយនឹងក៏ស្លាប់!

គ៖ ទៅមុននឹងក៏ស្លាប់ហើយទៅក្រោយក៏ស្លាប់ទៀត!

ខ៖ ចាស!អូនត្រូវតែទៅមុខ ព្រោះអីទៅមុននឹងក៏ស្លាប់ទៅក្រោយនឹងក៏ស្លាប់!
ពេលដែលយើងនឹងទៅមុននឹងយើងមានសង្ឃឹមជាងចុះអូនឯងនឹងបានប្រាប់ខ្ញុំនឹងហើយថាអោយឆ្លងផុតអាង១៧មេសាគឺយើងនឹងត្រូវរស់ហើយចុះហេតុអីបានជាអូនឯងថយវិញចឹងហា

ស? ហេតុអីអូនឯងថយ? ប៉ុកនឹងថាមែនចឹងយើងត្រូវតែទៅមុន
ដល់ចឹងទៅគេបានស្រែថាទៅយើងទៅមុខ។ ពេលទៅមុខនឹងអូនអើយ!
ពេលដែលទៅមុខនឹងត្រឹបនឹងណាកាលនឹងបានមើលឃើញពួកវៀតនឹង៣នាក់ដែរគេកំពង់តែកាន់កាំភ្លើងចឹងទៅណាកាលនឹងហើយខ្ញុំនឹងក៏បានស្រែកទៅជិតគេនឹងហើយពេលនឹងបានលឺស្នូលកាំងភ្លើងនឹងទៀតហើយគេនឹងបានទ្រាប់នឹងអស់ចឹងទៀតទៅពេលនឹងចឹងតែហើយពេលនឹងខ្ញុំនឹងក៏អត់មានខ្លាច! ខ្ញុំនឹងបានរត់ទៅដល់នឹងខ្ញុំបានថាអញអើយទួយកង
កងទួយកងទួយអូនងើក!!ខ្ញុំថាបងអើយកូនរបស់ខ្ញុំនឹងគេបានស្រែកទឹក!

ក៖ ហឹស.....

ខ៖ កូនរបស់ខ្ញុំនឹងគេបានឈឺ
បងអើយកងទួយអើយអួយៗៗនឹងមកហើយគេបានអោយថ្នាំនឹងបាន១ដៃ!ហើយគេបានដោះទឹកនៅឯខាងក្រមាគេនឹងបានអោយកូនខ្ញុំនឹងបានផឹង!

ក៖ ហឹស....

ខ៖
ចាស!អោយកូនរបស់ខ្ញុំនឹងទាំង២នាក់នឹងគេបានផឹក!ចាស!ហើយចំណែកឯពួកគេផ្សេងទៀតនឹងគេមិបាននឹងហ៊ានទេគេនាំគ្នានឹងក្រាបអស់រលីង!គេមិនហ៊ាននឹងចូលជិតវៀតណាមនោះទេកាលនឹង!ហើយដល់ពេលដែលគេបានមើលឃើញខ្ញុំនឹងមកចឹងណាគេបានចោលពូថៅនឹងចោលកំប៉ិតអីចឹងអស់រលីងហើយ!ថាកាលនឹងមានស្បែកជើងកងឡាននឹងក៏គេបានយកទៅចោលអស់ដែលកាលនឹងគេបានដើរមករកឯពពួកវៀតណាម។
ហើយកាលនឹងខ្ញុំនឹងក៏បានថាអញអើយចុងទួយ ថាអញអើយឌីញ៉ាទួយ?
ខ្ញុំថាអោយខ្ញុំនឹងបានទៅឯណា?ហើយពួកវានឹងថាអោយថា ឌីមូងៗៗ!

ក៖ ហឺ....

ខ៖ ហឺពួកយួននឹងបានចាសឌីមូងៗៗ!! ហើយខ្ញុំនឹងបានទៅឯមូង
ទៅឯមូងនៅឯបាត់ដំបងនឹងណាអូន!ហើយដល់ចឹងពួកនឹងបានថាឥឡូវនឹងយើងទៅ
គេថាអោយបានអោយយើងនឹងទៅឯមូង!ចឹងហើយកាលនឹងយើងនឹងបាននៅឯក្នុងព្រៃចឹងយើងបានអរណាស់អូន!ស្រាប់តែបានមកដល់ពេលដែលបានមកដល់ឯក្បាលផ្លូវនឹងពួកវានឹងបានផ្អើរយើងនឹងបានមកដល់ចឹងក៏វាបានបាញ់កាំភ្លើងចឹងវាបានបាញ់ក្របីនឹងអោយយើងនឹងបានញុំាហើយហែក អោយយើងនឹងបានវះស៊ីអោយយើងនឹងបានវះស្លដុត!

គ៖ វះបានដែរ?

ខ៖ ហែលកាលនឹងយើងវះយើងដុតចុះកាលនឹងនៅឯក្នុងព្រៃ!

គ៖ អូ....

ខ៖
នៅឯក្នុងព្រៃចឹងណាអូចឹងហើយយើងនឹងក៏បានដុតដាក់ដាំហូបទៅ!អាខ្លះទៅក៏លីងហើយពេលដែលបានសាច់ចឹងទៅកាលនឹងក៏បានលាក់ទុកយកទៅសំរាប់ទៅដល់កន្លែងទិសដៅរបស់យើងនឹងយើងបានធ្វើវាហូបចឹងទៅណា!
ហើយពេលនឹងបានមកដល់ឯខាងទិសដៅដែលមានក្រុមជុំនុំខ្ទមៗនឹងណា!មានខ្លះទៅដេកកងទាក់ខ្លានឹងណាស្លាប់ទៅ!ហើយមានខ្លះទៅនឹងដេក ពងក្តនឹងហើមឡើងប៉ុណ្ណឹងនេស!
ហើយកាលនឹងមានខ្លះនឹងស្លាប់ច្រើនណាស់ព្រោះអីពេលនឹងយើងនឹងទៅមុខវាមិនបានរួច!
មិនដេកនៅឯក្នុងជុំរុំនៅឯក្នុងខ្ទម!ចាស!ហើយចោលទៅខ្លះទៅងាប់ទៅហើយខ្លះទៅងាប់ទៅហើយខ្លះក៏ហើម!ពងក្តឡើងប៉ុណ្ណេះចឹងទៅ!ខ្លះទៅក៏ដេកកងពាក់ខ្លាកាលនឹង!
បានមើលឃើញអស់ហើយកាលនឹងអូនអើយ!

ក៖ អូស.....

ខ៖ ចាស!ហើយពួកខ្ញុំនឹងបានប្រហែលជាប៉ុន្មានគ្រួសារនឹងអត់មានអីនោះទេអូន
យើងក៏បានរត់មករកឯខាងព្រៃស្វាយវិញ!ដល់ពេលបានទៅដល់ឯខាងព្រៃស្វាយនឹងម្តាយក្មេករបស់ខ្ញុំនឹងគាត់បានស្រែត្រហាយំ!ហើយប្រជាជនគេនឹងមកគ្រប់ហើយទៅណា!ហើយកាលនឹងម្តាយក្មេករបស់ខ្ញុំនឹងគាត់បានស្រែយំ!ថាកូនអើយកូនសំលាប់ម៉ែម៉ែរកកូនតាំងពីព្រៃរហូតមកដល់ឯវាលម៉ែរកមិនឃើញកូននោះទេកូនអើយ!
កូនអើយកូន!គាត់បានស្រែយំចឹងណា!ព្រោះអីកាលនឹងប្តីនឹងក៏បាត់ហើយកូននឹងមួយចំនួននឹងក៏បាត់ទៅនោះណាកូននៅឯនេះចឹងទៅណា!ហើយស្រាប់តែដល់ពេលចឹងគាត់នឹងក៏បានយំចឹងខ្ញុំនឹងក៏បានចូលមកប្រាប់គាត់ថាម្តាយអើយម៉ែឯកុំស្រែយំចឹងក្រែងលោពួកអាពតវាមកអាក!ហើយខ្ញុំនឹងបានបុកអង្កអីនឹងបានតិចតួចចឹងទៅណាកាលនឹង!

ក៖ ហឺ....

ខ៖ ពេលបានឃើញប្រជាជនយើងនឹងបានមកពីខាងឯភ្នំពេញវិញហែក
កាលនឹងគេបានប្រាប់ថាគេបានចូលក្នុងភ្នំពេញនឹងវិញហើយកាលនឹងចុះកាលអូនឯបានគិត

មើលកាលនឹងគេបានចូលតាំងពីខែ1នឹងហើយយើងនឹងកាលនឹងនៅបានដល់ខែ៤នឹងមានប្រជាជនគេនៅឯតាមផ្លូវខ្មលនឹងមានប្រជាជនគេអីនឹងបានអស់ហើយមានតែយើងទេតើដែលពួកវានឹងបានមកយកទៅលាក់ឯក្នុងព្រៃចាស!ហើយមានយន្តហោះគេនឹងបានទៅទំលាក់ពេញទាំងក្នុងព្រៃនឹងណាចាស!កាលនឹងយន្តហោះនឹងណាគេបានទំលាក់គ្រាក់នឹងនៅឯក្នុងព្រៃនឹងឡើងព្រៀតតែម្តងអាមីអូន!

ក៖ អូ...

ខ៖
ហើយវានឹងវាខ្លាចយើងនឹងបានដឹងសាច់រឿងចឹងណាបានជាវានឹងថាអ្នកណានឹងបានរើសបានគ្រាក់នឹងបានសំលាប់ចោលចឹងទៅណា!

ក៖ចាស!

គ៖ ហឺ....

ខ៖ ចាស!
ដល់ពេលចឹងទៅកាលនឹងខ្ញុំនឹងបានមកដល់ឯព្រៃស្វាយហើយចឹងណាហើយបានមកធ្វើអង្គអីបន្តិចបន្តួចសំរាប់នឹងធ្វើស្បៀងនឹងហើយយើងនាំគ្នាមក។ខ្ញុំបានទៅយកសារ៉ុងរបស់ខ្ញុំហើយបានយកទៅដូរអោយគេនឹងទៅអាធ្វើជាកងអាទេះគេចឹងណាដើម្បីនឹងសំរាប់យកមកអូស!អូនឯងនឹងបានដឹងដែរឬទេចាសថាកាលនឹងអាកង់រទេះគេនឹងគេបានវៃទៅខ្ញុំនឹងបានយកអាកង់រទេះរបស់គេនឹងបានយកទៅផ្ទឹម!ហើយមានឈើនឹងចង់ទទឹងចឹងណាហើយម្តាយក្មេករបស់ខ្ញុំនឹងគាត់បានអាដាក់នៅលើដៃរបស់គាត់នឹងចឹងហើយខ្ញុំក៏បានកដាក់នៅលើដៃចឹងកាលនឹងហើយនាំគ្នានឹងបានអូសទៅ
ចាស!បានអូសរទេះនឹងមកមានកូន៣នាក់កាលនឹងកូនរបស់ខ្ញុំ២នាក់នឹងមានប្អូន៧ខ្ញុំនឹង១នាក់នឹងនឹងមានប្អូនបងរបស់ខ្ញុំនឹងមួយនាក់នឹងដែលបង១ទៅ!ពេលនឹងអ្នកខ្លះទៅបានរុញទៅហើយមានខ្លះទៅក៏បានអូស
ហើយខ្លះចឹងទៅក៏បានទាញអីខ្លះទៅចឹងកាលនឹងឡើងលឺប្រូងប្រាក់ៗៗៗទៅកាលនឹងនោះចាស!ហើយបានអង្កបានអីនឹងបានបន្តិចបន្តួចចឹងទៅណា!ហើយចឹងទៅពេលដែលបានមកដល់កណ្តាលផ្លូវនឹងស្រាប់តែអូនឯងអាយ!កាលនឹងមិនមែនមកតែយើងនោះទេកាលនឹងមានប្រជាជននឹងគេបានចេះនឹងមកឯហូរហែលចឹងទៅណាកាលនឹងនឹងអាអូន!ហើយពួកវានឹងបានរត់ទៅនឹងអស់ហើយដលល់ពេលចឹងទៅកាលនឹងអូនខ្ញុំនឹងបាននៅនឹងកន្លែង១នឹងហើយក៏

ម្ដាយក្មេករបស់ខ្ញុំនឹងថាមីអូនយើងសំរាកនៅឯកន្លែងនឹងហើយ!ហើយយើងនឹងទៅជុំរុំគ្នាថានឹងទៅរកកន្លែងណាដែលអាចនឹងទៅដកដំឡូងមីណាកូនដើម្បីនឹងទៅដកដំឡូងនឹងយកមកហូប!

ក៖ហឺ.....

ខ៖
ដើម្បីយកវានឹងមកហូបនៅតាមផ្លូវហើយដល់ពេលដែលបានមកដល់កន្លែងនឹងខ្ញុំនឹងក៏បានមកដាក់ខ្លួននឹងដេក!
ដាក់ខ្លួនដេកចឹងណាមីអូនចឹងទៅកាលនឹងម្ដាយរបស់ខ្ញុំនឹងគាត់ក៏បានថាណែលម្ដាយ។
កាលនឹងមានគេនឹងមកណាគេបានមកសួរហើយគេថា
មីងអើយមីងៗមីងឯងនឹងមែនប្រពន្ធតាសាតនោះទេ!ហើយពេលនឹងខ្ញុំនឹងក៏បានឆ្លើយឡើងថា ហើយណោសដែលថាមីងឯងនឹងជាប្រពន្ធរបស់លោកតាសាតមែនទេ?
ពេលនឹងខ្ញុំនឹងបានដេកនឹងបាត់ទៅហើយតែថាកាលនឹងខ្ញុំបានលឺម្ដាយរបស់ខ្ញុំនឹងគាត់បានប្រាប់ខ្ញុំមកចឹងកាលនឹងនោះ!គាត់ថាអើយកាលនឹងចឹងហើយណាមីអូន!ចឹងហើយគាត់នឹងបានថានឹងហើយចឹងខ្ញុំនឹងវាមិនបានដឹងថានោះជាប្ដីនឹងជាកូនរបស់មីងឯងឬក៏អីនោះទេដែលកំពុងតែនៅទីនោះតឹង!ដែលពួកគាត់កំពុងតែបានរង់ចាំមីងឯងនឹងនៅឯខាងខេត្តពោធិសាត់ឯនោះ!

ក៖ អូស!

ខ៖
នៅតាមផ្លូវចឹងណា!ហើយកាលនឹងខ្ញុំនឹងបានលឺចឹងក៏បានស្ទុះឡើងនឹងក្រោកហើយព្រោះអីកាលនឹងដោយបាននឹកឃើញថាវាបាននៅឯថ្ងៃនឹងវារាងបានជារសៀលហើយនឹងណោះ!
ព្រោះអីកាលនឹងខ្ញុំនឹងបានដេកនៅតាមផ្លូវចំនួនបាន១យប់ហើយនោះ!ហើយក៏បានលឺចឹងខ្ញុំនឹងក៏បានក្រោកឡើងឡើងព្រុយតែម្ដង!មីងអូនហើយបានទៅរូសរទេះនឹងបានមកទៀតហើយចឹងកាលនឹងមីអូនអើយបាននឹងអូសរទេះនឹងមកឯនេស!
នៅខាងលិចពោធិសាត់នៅឯខាងលិចនៅខាងស្ពានឯណោះចឹងហើយកាលនឹងស្រាប់តែបានមើលឃើញប្អូនថ្លៃ
ខ្ញុំនឹងវាបាននៅឯខាងព្រោះអីកាលនឹងវាបានធ្វើជាសន្តិសុខដែលវាបានឈរនៅខាងនេះស្ពានចឹងហើយពេលកំពុងតែឈរនឹងរង់ចាំមើលទៅ

ចាំមើលផ្លូវរបស់ពួកខ្ញុំនឹងណាហើយកាលនឹងស្រាប់អីពេលនឹងខ្ញុំនឹងវាមិនបាននឹងមើលគេនឹងឃើញនោះទេ!
ហើយកាលនឹងព្រោះអីគិតតែអីវ៉ាន់នឹងតែបានលីសូរឡើងក្រោកក្រាក់នឹងមកដាក់នៅលើអាទេះនឹងមកចឹងហើយកាលនឹងយើងនឹងបានទៅហើយពេលនឹងយើងនឹងបានទៅជួយគ្នារុញចឹង!តែកាលនឹងស្រាប់អីពេលនឹងចឹងក៏ម្ដាយក្មេករបស់ខ្ញុំនឹងគាត់ក៏បាននឹងមកដាក់រទេះនឹងហើយក៏បានស្រែឡើងនឹងថាយឺយៗថាកូន!!កូន!!មាសម្ដាយ!

កៈ ចាស!!

ខៈ
ព្រោះអីកាលនឹងគាត់នឹងបានមើលឃើញគាត់របស់គាត់នោះកាលនឹងចឹងទៅកូនគាត់នឹងអាកំលោះអាផារីនោះ!អាផារីនឹងចឹងកាលនឹងគាត់បានស្រែកថាកូន!កូន!មាសម្ដាយហើយចឹងទៅកាលនឹងខ្ញុំនឹងបាននឹងនឹកស្មានថាពេលនឹងគាត់នឹងបានមករត់នឹងទៅរត់ចូលទៅក្នុងរថហើយមានឡានមានអីចឹង!ហើយកាលនឹងខ្ញុំនឹងបានភ័យហើយចឹងទៅកាលនឹងខ្ញុំនឹងក៏បានមើលទៅស្រាប់តែបានឃើញថា
គាត់នឹងបានរត់ទៅអោបកូនរបស់គាត់នឹងសោះកាលនឹងហើយចឹង!

កៈ ហឺ!....

ខៈ ហើយគាត់នឹងបានថាកូនៗកូនអើយកូនកូនម្ដាយ!!កូនអើយបានត់ប្អូនអស់ហើយ!!!
ម្ដាយបានរកកូនរហូតតាំងពីនៅក្នុងព្រៃរហូតបានមកដល់ឯមកដល់ទីវាលហើយបានរកកូននឹងវាមិនបានឃើញនឹងទេកូនអោយ!!!

កៈ ហឺ....

ខៈ
គាត់នឹងបានស្រែកយំនៅកណ្ដាលខ្ទរនឹងណា!គេបាន២នាក់នឹងគ្នាគេ!ហើយដល់ពេលនឹងទៅកាលនឹងស្រាប់តែអូនឯងគេចឹងគេបានតឹម២នាក់រទេះគេនឹងហើយយើងក៏បានដើរនៅឯក្រោយចឹងទៅហើយក៏បានដើរយំចឹងទៅណា!ហើយពេលដែលបានទៅដល់នឹងស្រាប់តែអូនឯដឹងទេ
ពេលដែលបានទៅដល់នឹងគឺបានទៅដល់នៅឯខេត្តពោធិសាត់នឹងហើយនៅឯកន្លែងរបស់គេនឹងណា!ហើយដល់ពេលយប់នឹង
យប់នឹងគេបាននិយាយរឿងគេបានទៅខ្សិតខ្សាវគ្នាចឹងទៅណាកាលនឹងគេបានខ្សឹតខ្សាវគ្នាចឹ

ងទៅណាកាលនឹងហើយគេនឹងបានប្រាប់
តែកាលនឹងគេមិនបាននឹងប្រាប់ដល់ខ្ញុំនឹងនោះទេកាលនឹងហើយកាលនឹងគេនឹងបានប្រាប់ខ្ញុំទេចឹងបានថាពេលនឹងគេថា
អ្នកដែលបានទៅវៀតណាមនឹងទាំងប៉ុន្មាននឹងគេបានអោយមកវិញទាំងអស់!
ដែលមានប្រពន្ធនឹងទាំងអស់ចឹងទៅណា!ចាស!ហើយមានគេនឹងមកលួងកូនរបស់ខ្ញុំនឹងថាអាពាន់
អានីអើយប៉ានឹងនៅឯភ្នំពេញយកបានឥវ៉ាន់នឹងបានច្រើនណាស់ហើយដល់ពេលដែលអូនឯងនឹងបានទៅនឹងបានជួបនឹងប៉ាហើយចឹងណា!ខ្ញុំនឹងបានថាអីអូនអើយគេនឹងគេបានប្រពន្ធចុងហើយនោះគេនឹងម៉េចនឹងបានគិតមកដល់យើង!!

គ៖ អឺសហឺស!!

ខ៖
គេថាចឹងណា!ហើយពេលនឹងខ្ញុំនឹងបាននិយាយស្មាននឹងម៉េចគេគិតមកដល់យើងនឹងចឹងហើយចឹងកាលនឹងគេនឹងក៏បានឆ្លើយឡើងនឹងមកវិញថាកាលនឹងចុះម៉េចបានជាអ៊ុំឯងក៏ដឹង!ខ្ញុំថាខ្ញុំដឹង!ចឹងទៅណា!ហើយពេលនឹងគាត់នឹងក៏បានប្រាប់ថាកាលនឹងគាត់នឹងមានមែន!
និយាយនឹងចឹងទៅនា!ហើយកាលនឹងប្អូនថ្លៃរបស់ខ្ញុំនឹងកាលនឹងគាតមិនបានទៅប្រាប់ដល់ខ្ញុំនោះទេកាលនឹងគេនឹងបានស្ទបប្រាប់ដល់ខ្ញុំនឹងចឹងណាកាលនឹង!ហើយម្ដាយខ្ញុំអីនឹងអត់បានប្រាប់ដល់ខ្ញុំនោះទេកាលនឹងហើយចឹងពេលដែលថាខ្ញុំនឹងបានដឹងភ្លាមនឹងណាមីអូន!

ក៖ ហឺ.....!

ខ៖ ក៏បានទាញយកក្រដាសនឹងយកមកសរសេរនឹងមកភ្លាមចឹងតែម្ដង!ថា
ខ្មោចនៅឯព្រៃភ្នំនឹងមកហើយទៅកាច់នឹងហើយណា!ទៅកាច់ហើយ!ចុះកាលនឹងគាត់នឹងអត់មានបានប្រាប់ដល់ខ្ញុំប្ដីខ្ញុំនឹងគាត់ខូចណាស់អូន!
គេនឹងជាយោធាក្រុងចឹងណា!(គាត់បានប្រាប់ទៅចៅគាត់ថាមីងអូនបិទទៅវាថ្លង់ណាស់)កាលនឹងគាត់គឺជាទាហានយោធាក្រុងនឹងណាកាលនឹងនោះចាស!
កាលនឹងគាត់នឹងណាគាត់ជាយោធាក្រុងប្ដីរបស់ខ្ញុំនឹងហើយគាត់បានធ្វើជាដេអិនណានៅឯកន្លែងឯងសាលាជាតិរាល់តែថ្ងៃនឹង!ហើយពេលនឹងដល់ពេលដែលខ្ញុំនឹងបានលឺថាចឹងកាលនឹងខ្ញុំនឹងក៏បានស្រាប់តែយំហើយយំហើយក៏ខ្ញុំនឹងបានសរសេរហើយក៏បានសរសេរសំបុត្រនឹងមកហើយដល់ចឹងទៅកាលនឹងប្អូនថ្លៃរបស់ខ្ញុំនឹងក៏បានទៅរកសំបុត្រឡាននឹងណា!

កាលនឹងឥវ៉ាន់របស់ខ្ញុំនឹងបានយកទៅចោលអស់ហើយកាលនឹងព្រោះអីពេលដែលបានលឺថាប្ដីរបស់ខ្ញុំនឹងគាត់មានប្រពន្ធចុងនឹង
កាលនឹងប្ដីមានប្រពន្ធចុងចឹងកាលនឹងខ្ញុំលែងនឹងចង់បានអីទាំងអស់ហើយ!!

គ៖
អ៊ុំសូមកាត់ដល់អ៊ុំនឹងបន្តិចថាកាលនឹងនៅក្នុងសំបុត្រនឹងអ៊ុំបានសរសេរវាបានយ៉ាងម៉េចដែរ?

ខ៖
កាលនឹងខ្ញុំនឹងបានសរសេរនឹងដាក់ថាកាលនឹងពេលនឹងពេលនេះមានខ្មោចមកពីព្រៃភ្នំមកកាច់ទាំងរស់ហើយកាលនឹងទៅកាច់នឹងមកទាំងនៅរស់នឹងហើយ!!! ចឹងហាហាសៗ

ក៖ ហឹសហេសៗ!!

ខ៖
(មានគេតេមកគាត់ហើយគាត់ថាឈប់សិនហើយគាត់បានបង្ហាញថ្នាំដែលគាត់បានលេបជាប្រចាំនឹងអោយយើងហើយថានេះជាថ្នាំរបស់ខ្ញុំសំរាប់លេបចឹងណា!)
កាលនឹងប្រវិត្តរបស់ខ្ញុំនឹងកាលនឹងវាបានកំសត់ណាស់កាលនឹងហើយចឹងខ្ញុំនឹងបាននិយាយនឹងវារាងបានយូរនឹងពេកដល់ចឹងទៅហើយចឹងកាលនឹងយើងនឹងបាននិយាយដល់ណាហើយចឹង!!

គ៖ អ៊ុំបាននិយាយនឹងដល់ពេលដែលអ៊ុំបានទៅជួបនឹងគាត់នឹងទៅជួបនឹងកូននឹង!

ក៖ ហើយនឹងអ៊ុំបានទៅជួបនឹងប្ដីហើយសរសេរសំបុត្រ!

ខ៖
នឹងហើយអើ!!កាលនឹងបានសរសេរសំបុត្រនឹងហើយក៏បានទៅជួបនឹងប្ដីហើយ១ដងនឹងហើយនឹងលែងថានៅចាំពីណាគេហើយពេលនឹងបានជិះឡាននឹងមកហើយបានមកដេកនៅឯកំពង់ឆ្នាំមក១យប់អូនឯង!ហើយកាលនឹងអាឡាននឹងវាបានបោកឯងថាកាលនឹងវាថាបានមកដល់នឹង១យប់ចឹងមកដល់ហើយតែកាលនឹងពេលបាន១យប់នឹងកាលនឹងអត់មានបានមកដល់អីគឺកាលនឹងបានមកដល់កំពង់ឆ្នាំនឹង!ហើយបានចុះកំពង់ឆ្នាំនឹងហើយកាលនឹងខ្ញុំនឹងក៏បានដេកនៅឯកំពង់ឆ្នាំនឹងបាន១យប់ដល់ពេលហើយទៅកាលនឹងទៅរកឯឡាននឹងជិះវិញនឹងអត់មានបានឃើញឯណាកាលនឹងដល់ចឹងកាលនឹងខ្ញុំនឹងបានហៅឡានផ្សេងៗនឹងដើម្បីនឹងទៅដល់ឯភ្នំពេញហើយកាលនឹងខ្ញុំនឹងបានទៅប្តូរមាសនឹង៥ជីដើម្បីនឹងអោយវាបានឆាប់ទៅដល់ឯ

ភ្នំពេញហើយចឹងកាលនឹង!ហើយកាលនឹងខ្ញុំនឹងបាន....(គាត់បានប្រាប់ថៅគាត់ថាឯងទៅប្រាប់វាថាកុំអោយវានឹងបានមាត់ពេក)ហើយខ្ញុំនឹងកាលនឹងណាកាលនឹងខ្ញុំនឹងបានទៅប្តូរយកត្រីងៀតអីនឹងដើម្បីយកទៅអោយកូននឹងប្តីរបស់ខ្ញុំនឹងបានញាំនឹងណាកាលនៅក្នុងសម័យនឹងគឺថា៣គីឡូងនឹងបាន១ជី

ចាស!កាលនឹងបានតែ៣គីឡូទេបាន១ជីហើយចឹងបានជាខ្ញុំនឹងទៅប្តូសំរាប់នឹងយកទៅអោយដល់កូនរបស់ខ្ញុំនឹងវាបានហូបនឹងណាកាលនឹងនោះចឹង!!ចាស!

កាលនឹងចំពោះសារ៉ុងរបស់ខ្ញុំនឹងណាកាលនឹងបានតែថា១ម៉ែត្រនឹងបានតែកង់១នឹងមាស១ជំឡឹងនោះទេកាលនឹងកង់!ចាស!

ដល់ពេលចឹងកាលនឹងខ្ញុំនឹងបានមកដល់ហើយចឹងកាលនឹងខ្ញុំនឹងបានប្តូរមាសនឹងបាន៨ជីទំរាំតែខ្ញុំនឹងបានមកដល់ចាចាស!ព្រោះអីកាលនឹងមានគ្នាននឹងមានចំនួនបាន៨នាក់ទាំងអស់គ្នាននឹងមានបងរបស់ខ្ញុំ ខ្ញុំ ម្តាយរបសខ្ញុំនឹងមាន

កូនរបស់ខ្ញុំនឹងទាំងអស់នឹងកាលនឹងវាមានគ្នាបាន៨នាក់នឹងចាស!

ចាស!កាលនឹងខ្ញុំនឹងបានអោយ៨ជីកាលនឹងហើយពេលនឹងបានឡើងនៅឯក្នុងឡានហើយចឹងមីអូនឯង!ស្រាប់តែគេនឹងបានអោយយើងនឹងទៅចុះវិញ!គេនឹងបានដេញខ្ញុំនឹងបានចុះវិញអោយខ្ញុំនឹងបានទៅដេកនៅឯកំពង់ឆ្នាំងនឹងបាន១យប់ហើយចឹងកាលនឹងបានចុះនឹងកំពង់ឆ្នាំងបានដេកបាន១យប់ចឹងទៅកាលនឹងខ្ញុំនឹងក៏បានប្រាប់ទៅដល់ម្តាយរបស់ខ្ញុំថាម្តាយ!(គាត់បានហៅថៅគាត់ថាអាស៊ីុងឯងនឹងទៅអោយវានឹងលេងក្លងក្រោងធ្វើអ្វី?)ហើយកាលនឹងខ្ញុំនឹងបានប្រាប់ថាអោយកូននឹងអោយនៅជាមួយនឹងយាយហើយប្រាប់ម៉ែថាម៉ែឯងមើលកូននឹងអោយខ្ញុំផងខ្ញុំនឹងទៅឯភ្នំពេញហើយ!ខ្ញុំទៅរកប្តីរបស់ខ្ញុំ ខ្ញុំនៅមិនបាននោះទេ!

ចឹងហើយគាត់នឹងក៏បានប្រាប់វិញថាចឹងកូនឯងនឹងទៅចុះហើយបើថាម្តាយ

អោយកូនឯងនឹងទៅនឹងហាក់ដូរជាបានដេញកូនឯងចឹងណាចឹងហើយឥឡូវនឹងកូនឯងនឹងទៅចុះទុកកូននឹងអោយម៉ែមើល!ហើយចឹងដល់ពេលព្រឹកឡើងចឹងខ្ញុំនឹងបានរៀបចំហើយទៅខ្ញុំរត់ទៅយកបន្ទោងខ្សែកសម្តាចនឹង១ជីណាខ្ញុំបានដេញតាមឡាននឹងណាកាលនឹងដើម្បីនឹងទៅចឹងណា!

ហើយពេលនឹងខ្ញុំនឹងបានថាអញអើយទួលឌីភ្នំពេញ!ថាកាលនឹងខ្ញុំនឹងទៅឯភ្នំពេញផងហើយខ្ញុំនឹងថាចឹង!ហើយពេលនឹងវានឹងបានលឺហើយស្តាប់បាននឹងវានឹងក៏បានទាញដៃខ្ញុំនឹងឡើងចឹងទៅកាលនឹងហើយវានឹងបានទាញដៃរបស់ខ្ញុំដើម្បីនឹងឡើងលើហើយពេលនឹងខ្ញុំមានបងជីដូនមួយរបស់ខ្ញុំនឹងក៏គាត់ជួយនាំខ្ញុំនឹងបានឡើងលើនឹងដែរ

ហើយទៅតាមខ្ញុំនឹងណាកាលនឹងហើយពេលនឹងបានទៅនឹងស្រាប់តែខ្ញុំនឹងបានឃើញឡាននឹ

ងវាពាងបានស្រលះនឹងចឹងក៏ខ្ញុំនឹងបានដាក់កូនរបស់ខ្ញុំនឹងបានទៅដែរដែលថាកាលនឹងកូនរបស់ខ្ញុំនឹងវាបាននៅរាងថាវានៅរាងតូចៗនឹងណា!ហើយចឹងខ្ញុំនឹងបានដាក់កូនរបស់ខ្ញុំនឹងបានទៅដែរចឹងណា!

ក៖ ចាស!

ខ៖
ចាស!ចឹងហើយកាលនឹងបានកូនរបស់ខ្ញុំនឹងវាបានទៅដែលនឹងហើយក៏បានទៅដល់ហើយបានជិះឡាននឹងទៅជា១នឹងគ្នាចឹងទៅណាកាលនឹង។
ពេលដែលបានមកដល់ឯនេះចឹងណាមកដល់នេះអូន....មកដល់ឯគីឡូលេខ៦នឹងគេបានមកដាក់យើងនឹងចុះហើយពេលនឹងចឹងកាលនឹងយើងនឹងបាននាំកូនរបស់យើងអោយបានងូតទឹកនឹងអោយស្អាតហើយអោយកូននឹងបានពាក់មាសពាក់អីចឹងទៅណា!
ហើយបានទូលកន្ទ្រេងពោះគោអីនឹងចឹងទៅណាហើយកាលនឹងមានបានសាប៊ូក្រអូប១ទៀតនឹងបានយកវាមកដុសអោយដែលកាលនឹងនៅកាលនឹងបានចុះឈប់ងូតទឹកនឹងបាននៅឯគីឡូលេខ៦ដើម្បីនឹងងូតទឹកនឹង!ហើយហើយក៏កាលនឹងខ្ញុំនឹងបន្ដើរកូនរបស់ខ្ញុំនឹងដើម្បីអោយគេបានមកជួបនឹងប៉ាគេចឹងណាហើយចឹងពេលដែលបានមកដល់ឯដេអិននឹងដែលប្ដីខ្ញុំនឹងបាននៅឯនឹងចឹងណា!ហើយពេលនឹងខ្ញុំបានសួរគេថាមានស្គាល់ឈ្មោះ អិនសាន ដេស?
ហើយពេលនឹងគេបានថាអត់ស្គាល់ទេខ្ញុំនឹងថ្មីអត់បានស្គាល់នោះទេ!ហើយចឹងអ៊ុំឯងទៅសួរអ្នកដែលគេនឹងថ្មីនឹងបានជាគេនឹងបានដឹងចឹងណា
ចឹងខ្ញុំនឹងសូមចូលទៅបន្តិចហើយខ្ញុំសូមផ្ញើកូននៅឯនេះហើយអោយកូនរបស់ខ្ញុំនឹងនៅឯមុខអ្នកទាមនឹងចឹងហើយកាលខ្ញុំនឹងក៏បានដើរចូលទៅ!ហើយពេលដែលបានដើរចូលទៅខ្ញុំបានក្រលេកទៅខ្ញុំបានមើលឃើញប្ដីរបស់ខ្ញុំនឹងកាលនឹងគេនឹងស្អាត់ណាស់អូនអើយ
គេបានស្លៀកពាក់ជាទាហានពណ៌ខៀវ នឹង!

ក៖ អឹស!

ខ៖ គេកំពង់តែលេងម៉ូតូគេ!ហើយចឹងស្រាប់តែខ្ញុំដើរជំរង់ទៅដល់ខ្ញុំនឹងបានស្រែហៅគាត់ថានែស!!!

ក៖ ហឹសៗៗ!!

ខ៖ ចុះបានខឹងនោះកាលនឹងព្រោះអីកាលនឹងគេនឹងមានប្រពន្ធចុងនោះ
ហើយចឹងខ្ញុំនឹងបានស្រែកថានែស!!!

កៈ ហឺសៗៗ!

ខៈ ហើយកាលនឹងស្រាប់តែគាត់នឹងភ្ញាក់ថា ហេសៗៗអែងមកពីណាហើយឯងមកពីណា!!

កៈ ហឺស!ៗ!

ខៈ
ហើយកូនយើងនឹងវានៅឯណា!ហេស!ហើយពេលនឹងខ្ញុំបានថាកូននឹងនៅឯទីណាំកូននឹងនៅឯខាងមុខឯនោះ!ដល់ចឹងទៅពេលនឹងគាត់ក៏បានរត់ទៅរកកូនឡើងគ្រុយ!!ហើយគាត់បានរត់ទៅរកឯកូនរបស់គាត់ចឹងណា!ហើយកាលនឹងបានកូននឹងតែ២នាក់នឹង!ហើយគាត់បានសួរថាកូនយើងនឹងតែ២នាក់នឹងទេហេស?ហើយចុះឯណាកូន១នាក់ទៀត?

កៈ ហឺ....

ខៈ ហើយខ្ញុំបានថាកូន១នាក់ទៀតនឹងវាបានស្លាប់បាត់ហើយ!!
ដល់ចឹងទៅកាលនឹងគាត់នឹងបានយកកូនរបស់ខ្ញុំនឹងទៅទុកខាងក្នុង!
ហើយចំណែកឯខ្ញុំវិញនឹងបានឈរនៅយំនៅឯកន្លៀតម៉ូតូនឹងចឹងទៅណាកាលនឹង!ឈរយំអើយយំ!ហើយគាត់នឹងបានហៅខ្ញុំទៅហើយគាត់បានមកដឹកដៃខ្ញុំនឹងទៅហើយអូសខ្ញុំនឹងទៅ!
ហើយអូនអើយកាលនឹងពេលដែលបានទៅដល់កន្លែងគេនឹងដឹងខ្ញុំនឹងវាយំយ៉ាងម៉េចនោះទេ!
ចុះកាលនឹងនៅឯដេអិនគេនឹងវាសុទ្ធតែម៉ាស៊ីនត្រជាក់ចឹងហើយាកាលនឹងគ្រាន់តែខ្ញុំនឹងបានអើតទៅត្រឹមកនឹងចឹងទៅស្រាប់តែវាត្រជាក់ស្រឹប!!

កៈ ហឺស!!!

ខៈ ខ្ញុំនឹងវាយំហើយខ្ញុំនឹងវាបានហូរទឹកភ្នែកព្រោះអីខ្ញុំនឹងបានមើលឃើញសាឡុងនឹងមើលឃើញកន្លែងគេនឹងវាធ្វើការណា!!

កៈ ហឺស!!

គៈ ហឺស!

ខៈ គេនឹងបានដើបហើយស្ទុះទៅបើកយកពីក្នុងទូទឹកកក
ហើយវ៉ែទឹកកកនឹងឡើងលឺភូសៗៗហើយដាក់ក្រូចឆ្មារដាក់តែទឹកកកនឹងច្របាត់ទៅអោយកូនគេផឹកហើយគេបានទៅយកនំអោយកូនគេនឹង១បាន១ស្បោងម្នាក់ៗចឹងកាលនឹងហើយគេអោ

បហើយពេលនឹងគេបានទៅយកខោអាវនឹងទៅយកមកប្តូរអោយកូនគេនឹងបានថ្មីៗ!!ចំណែកឯខ្ញុំវិញនឹងខ្ញុំគិតតែពីយំ!!

ក៖ ហឹស!

ខ៖
កាលនឹងខ្ញុំគិតតែពីយំនឹងគេបានថាម៉េចក៏ខ្ញុំនៅតែយំដែរ!ខ្ញុំនឹងវាមិនបានស្តាប់នោះទេកាលនឹងខ្ញុំនឹងគិតតែយំៗៗៗទាល់តែឪក្មេកនឹងមក
ព្រោះអីកាលនឹងគេបានប្រាប់អោយទៅយកឪក្មេកខ្ញុំនឹងមកអោយលួងខ្ញុំនឹងមក
ពូរបស់ខ្ញុំអីនឹងណាមកលួងខ្ញុំដែលគាត់នឹងនៅឯស្ទឹងមានជ័យគាត់បានមកលួងដល់ខ្ញុំនឹងថាកុំថាតែវានឹងអីកូនអើយកាលនឹងសូមប្បីតែឪនឹងក៏កាលនឹងក៏ចង់ការតែកាលនឹង!!
ព្រោះអីកាលនឹងម្តាយក្មេករបស់ខ្ញុំនឹងកាលនឹងគាត់នឹងមិននៅជាមួយនឹងខ្ញុំ!

ក៖ ហឹស....!

ខ៖ ហើយដល់ចឹងកាលនឹងឪក្មេករបស់ខ្ញុំនឹងគាត់មិននៅជាមួយនឹងប្តីរបស់ខ្ញុំនឹង
គាត់ថាកាលនឹងគេបានបូពាស់នឹងស្លាប់ទៅអស់ហើយកូនអើយកាលនឹងចឹងទៅបាន
គេថាពេលនឹងវាបានខែ៥ហើយហើយកូនឯងតឹមតែមកអើយចឹងហើយកាលនឹងគេនឹងបានចូលទាំងពីខែ១ហើយចឹងនរណាគេនឹងបានទៅចាំខ្មោច!អើយ!
អូយ!កាលនឹងគេបានរកខ្ញុំនឹងតាំងពីប្តីខ្ញុំនឹងបានទៅរកខ្ញុំនឹង!កាលនឹង!ហើយពេលនឹងណាកូន!ហើយឥឡូវនឹងប្តីរបស់ខ្ញុំនឹងគេបានធ្វើធំហើយនឹងកាលនឹងគេបានធ្វើការងារជា១នឹងលោកអូសំខាន់ ហើយឥឡូវនឹងគាត់បានជាស្នងការទឹក
ហើយឥឡូវនឹងគាត់បានផ្កាយ៣ទៅផ្កាយ៤ហើយ!គាត់បានទៅរកខ្ញុំនឹងនៅដល់ឯកំពង់ឆ្នាំកាលនឹងប្តីរបស់ខ្ញុំនឹងគាត់បានទៅរកខ្ញុំដល់តាកែវអ្នកលឿងនេស!
អានឹងប្តីរបស់តែដល់ពេលនេះចឹងទៅកាលនឹងគេនឹងបានចេះតែអែបអប់ចឹងទៅណា!!

ក៖ ហឹស!!

ខ៖
គេនឹងកាលនឹងគេបានទៅជាមួយហើយចឹងដល់ពេលឥឡូវនឹងគេនឹងបានធ្វើការងារនឹងធំៗអស់ហើយកាលនឹងមកដល់ឥឡូវនឹងគេសុទ្ធតែមានផ្កាយអស់ហើយ!
តែពួកអស់នឹងតែថាកាលនឹងពួកអស់លោកអស់នឹងគេមិនបានទៅភ្លេចខ្ញុំនឹងនោះទេទោះបីជាខ្ញុំនឹងទៅជួបគេក៏គេនៅតែសំពះដល់ខ្ញុំគេនៅតែគោរពដល់ខ្ញុំចឹងណា!

គ៖ ព្រោះអីបានកំសត់កំរល់មកនឹងជាមួយនឹងគ្នា!

ខ៖
ចាស!អ្នកដែលគេបានធំៗនឹងចាស!អ្នកដែលគេនឹងបានចូលមកពីខាង១៩៧៩នឹងដូចគ្នានឹងគេបានស្រលាញ់ខ្ញុំគ្រាប់គេចឹងណាកាលនឹងចាស!ហើយចំណែកឯប្តីរបស់ខ្ញុំនឹងគេបានប្រពន្ធចុងគេទៅចឹងកាលនឹងអូនអើយ!ដល់ពេលទទួលអីកាលនឹងគេបានទៅទទួលប្រពន្ធចុងគេនឹងនៅឯស្ទឹងមានជ័យនឹងចឹងទៅណាកាលនឹងហើយដល់ពេលនឹងចឹងកាលនឹងទទួលអីខ្ញុំនឹងវាបានរស់រានមានជីវិតមកដល់សព្វថ្ងៃនឹងមកចឹងទៅណាកាលនឹងណា!អានេះវាបានមកនឹងដោយសារតែកាលខិតខំប្រឹងប្រែងនឹងរបស់ខ្ញុំនឹងមកវាមិនមែនថា
ដូចថាដូចថាបានកំលាំងប្តីអីនឹងបានប៉ុន្មាននោះទេប្តីរបស់ខ្ញុំនឹងគាត់បានធ្វើការងារនឹងគាត់បានមានស្រីមានប្រពន្ធចុងនឹងចឹងណាចាស!ហើយចឹងខ្ញុំនឹងក៏បានខិតខំប្រឹងតស៊ូរកស៊ីទៅស្អីចឹងទៅណា!ចឹងស្អីទៅកាលនឹងក៏ខ្ញុំនឹងបានរកដែលកាលនឹងអោយតែថាកាលនឹងមានថាស្អីគេរកស៊ីបានចំណេញនឹងខ្ញុំខំទៅរកហើយកាលនឹងគឺខ្ញុំនឹងទៅរកនៅកន្លែងនឹង!!

ក៖ អូ.....

ខ៖ កាលនឹងគឺខ្ញុំនឹងបានរកទៅដឹកឥវ៉ាន់
ដឹកក្រដាសអីនឹងហើយបានយកទៅបោះនៅឯស្រុងយួននឹងមកវិញខ្ញុំទិញយកមកលក់វិញចឹងណាហើយអំពៅបានមាសអីចឹងទៅ!ហើយជូនកាលនឹងខ្ញុំបានដឹកជង្ហាក់បាន១០០ទៅវៀតណាមអីចឹងទៅហើយបានមកវិញនឹងបានមាសបានចំណេញបាន៣ជីអីចឹងទៅកាលនឹង!ខ្ញុំនឹងបានខំប្រឹងប្រែងនឹងរកស៊ីណាស់កាលនឹងហើយខ្ញុំនឹងបានខំប្រឹងប្រែងដើម្បីនឹងបានបើកជាសិប្បកម្ម ផ្សុំម៉ូតូ ទៅបោះកង់ម៉ូតូអីនឹងនៅតាមខេត្ត
ខ្ញុំបានខំហើយខ្ញុំនឹងបានទៅផ្សារអីស្អីៗនឹងហើយខ្ញុំបានបើជាសិប្បកម្មនឹងមកគឺខ្ញុំនឹងបានខំប្រឹងនឹងរកស៊ីណាស់!!អូនហើយបន្ទាប់មកនឹងខ្ញុំបានបើអាដេប៉ូរឈើអីនឹង!!

ក៖ ហឹស!...

ខ៖
ខ្ញុំបានបើកអីៗនឹងបាន១ចប់គឺថាការងាររកអីរបស់ខ្ញុំនឹងគឺថាវាបានរួចផុតពី១បានទៅ១ទៀតនឹងណាចាស!ខ្ញុំបានលាបកងអីនឹងទិញលក់អាដែកកញ្ចាស់ៗអីនឹងចាស!កាលនឹងបោះទៅឯទួលទំពុងអីនឹងណាចាស!កាលនឹងខ្ញុំនឹងខំប្រឹងរកណាស់ចាស!កាលនឹងខ្ញុំនឹងមិនមានបាននៅទំនេរនោះទេ!ចាស!ហូតទាល់តែបានដល់ពេលបានកូនរបស់ខ្ញុំនឹងគេបានមានប្តីអីអស់ហើយ

នឹងគេបានមានការងារហើយគេបានអីចឹងហើយខ្ញុំនឹងគ៏បានចែកផ្ទះសំបែងអោយម្នាក់មួយៗនឹងចឹងអស់ទៅណាចាស!ហើយក្រោយមកទៀតនឹងប្តីរបស់ខ្ញុំនឹងគាត់បានស្លាប់ទៅ!គាត់បានស្លាប់នឹងនៅក្នុងឆ្នាំមួយពាន់ប្រាំងបួនរយប៉ុន្មាននោះទេដូចជា១៩៩១អីនឹងគាត់បានស្លាប់ទៅ!អីនឹងកាលនឹង!

គ៖ ហឺស!អ៊ុំកាលនឹងឆ្នាំប៉ុន្មានមួយពាន់ប្រាំងបួនរយប៉ុន្មាន?

ខ៖ ហេសកាលនឹងដូចជាឆ្នាំបានពីរពាន់ប៉ុន្មានទេណេស!ហើយឥឡូវនឹងវាបានឆ្នាំពីរពាន់ប៉ុន្មានហើយ?

ក៖ ឥឡូវនឹងឆ្នាំ២០១៨។

ខ៖ អឺ!កាលនឹងគាត់នឹងបានស្លាប់ទៅនឹងនៅក្នុងឆ្នាំ២០១៥ចាស!

ក៖ ចឹងបាន៣ឆ្នាំហើយ!

ខ៖ ចាស!កាលនឹងគាត់បានស្លាប់ទៅនឹងបានរយៈពេលនឹងបាន៣ឆ្នាំហើយ!ដែលគាត់នឹងបានស្លាប់នឹងណា!ហើយពេលនឹងខ្ញុំនឹងបានយកគាត់នឹងទៅមើលដល់វៀតណាមឯណ៎កាលនឹងគ្រាន់តែគេ...កាលនឹងគាត់នឹងបានដាច់សរសៃរឈាមនឹងចឹងហើយយើងបាននាំគាត់នឹងទៅវៀតណាមដើម្បីនឹងមើល!

ក៖ ហឺស!....

ខ៖ ពេលដែលបានទៅយកគាត់នឹងទៅមើលដល់វៀតណាមហើយនឹងកាលនឹងគាត់បានទៅមើនឹងខ្ញុំបានតាមគាត់ទៅមើលដល់វៀតណាមនឹងទៀតកាលនឹង!គេបានយកទៅហើយឡានគេនឹងបានជូនគាត់នឹងទៅដល់វៀតណាមនឹងចឹងទៅកាលនឹងហើយគេនាំទៅកាលនឹងទៅដេកនៅឯពេទ្រនឹងកាលនឹងអត់មានបាននឹងអស់លុយនោះទេកាលនឹងព្រោះអីរដ្ឋគេនឹងបានជួយប្តីយើងនឹងណាគាត់ជាអ្នកធំដែរចឹង!ណាកាលនឹងប្តីយើងនឹង!ហើយកាលនឹងប្តីរបស់ខ្ញុំនឹងគាត់បានទៅនៅឯផ្ទះនឹងធ្វើជាអង្គរ:របស់សម្តេចនឹងចឹង!ហើយក្រោយមកទៀតនឹងគាត់បានកាន់ខុសគ្នានគាត់បានកាត់កងពលទៅឯនេះនឹងចឹងហើយកាលនឹងគាត់នឹងទៅឯនេះនោះកាលនឹង!

កៈ ហឺស....

ខៈ
ទៅឯនេះនោះចឹងទៅបានជាគាត់នឹងបានស្លាប់ទៅហើយបានរដ្ឋនឹងគេបានជួយជាស្អីៗនឹងវារាងបានស្បៀមនឹងដៃរនឹងដៃរគេនឹងបានជួយនឹងនោះ
ហើយចឹងកាលនឹងគាត់នឹងបានស្លាប់រហូតមកដល់ឥឡូវនឹងហើយខ្ញុំនឹងបាននៅតែឯងនឹងមកចឹងទៅ! ចាស!
ហើយកូនរបស់ខ្ញុំនឹងក៏ខ្ញុំបានចែកផ្ទះសំរាប់យកទៅអោយវានឹងមានមួយម្នាក់ៗនឹងចឹងទៅណាអូន!

កៈ ហឺស!

ខៈ
ចាស!ការខិតខំប្រឹងប្រែងរបស់ខ្ញុំនឹងខ្ញុំបានខិតខំប្រឹងប្រែងណាស់!តស៊ូហើយខ្ញុំនឹងបានដឹងខ្លួនរបស់ខ្ញុំនឹងច្បាស់ណាស់ថា!ជាតិមុននឹងប្រហែលជាខ្ញុំនឹងបានធ្វើបុណ្យអីនឹងបានល្អហើយបានជាខ្ញុំនឹងទៅនៅឯក្នុងសម័យសង្គ្រាមនឹងហើយពេលដែលបានថាកាលនឹងបាននៅក្នុងសម័យដែលគេហៅថាសម័យពពតនឹងណាដែលគេថានឹងយកខ្ញុំនឹងទៅវៃនៅឯក្នុងព្រៃនឹងហើយក៏នៅតែថាខ្ញុំនឹងនៅតែមានជីវិតនឹងវាបានរស់រាននឹងមកដល់ពេលសព្វថ្ងៃនេះ!

កៈ ហឺស!....

ខៈ
ខ្ញុំនឹងក៏នឹកឃើញថាប្រហែលជាវាជាផលបុណ្យរបស់ខ្ញុំនឹងហើយដល់ពេលចឹងទៅខ្ញុំនឹងក៏បានខិតខំប្រឹងវានឹងបន្តមកទៀតបន្តបន្ទាប់មកទៀតចឹងទៅណាអូន!

កៈ ហឺស!...

ខៈ
ហើយចឹងទៅនឹងខ្ញុំនឹងក៏បានមានចេះធ្វើបុណ្យសន្សំមកទៀតនឹងទុកបន្តបន្ទាប់មកទៀតចឹងទៅណា!ដូចថាឥឡូវនឹងមកខ្ញុំមានអាយុបានវា៦៨ឆ្នាំនឹងមកហើយ!!ចាស!

គៈ ហើយអ៊ុំ!ដូចជាកូនចៅរបស់អ៊ុំអីនឹងគេបានរៀនដល់កំរិតណាដែលទៅអ៊ុំ?

ខៈ ចាស!កូនរបស់ខ្ញុំនឹងគេបានរៀនចប់បរិញ្ញាប័ត្រនឹងអស់ហើយនឹង!

ក៖ អូ!

គ៖ អូ!

ខ៖
នេះវាបានធ្វើជាពេទ្យទាហានហើយមួយទៀតនឹងគេបានរៀននឹងចប់ៗអស់ហើយ!គេបានរៀនចប់បរិញ្ញាប័ត្រហើយនឹងគេបានទៅរៀនធ្វើជាទាហាននៅឯនោះនឹងចឹងទៅណា!ហើយមានមួយទៀតនឹងប្តីរបស់គេនឹងគេបានធ្វើជាប៉ូលិសហើយទៅប្តីរបស់គេនឹងមួយនាក់ទៀតប្តីគេបានធ្វើជាទាហាន!
ហើយមួយទៀតដែលមានប្តីទៅនឹងគេបានប្តីគេធ្វើជាទាហានដែលដែលគេបានទៅធ្វើជាកងពល!នោះ!

ក៖ ហឺស!!

ខ៖ ចាស!កូនរបស់ខ្ញុំនឹងគេសុទ្ធតែបានធ្វើការងារទាំងអស់!

គ៖
ហើយអ៊ុំមកដល់ឥឡូវនឹងពេលម្តងៗពេលដែលអ៊ុំអង្គុយហើយអ៊ុំបាននឹកឃើញពីសម័យពពតនឹងណាអ៊ុំ...

ខ៖ ចាស!

គ៖ ពេលដែលបាននឹកឃើញជីវិតពេលនៅក្នុងសម័យពពតនឹង.....

ខ៖ អូយ!!...

គ៖ ពេលដែលអ៊ុំបាននឹងឃើញនឹងបានម្តងៗ!

ខ៖
ពេលនឹងអ៊ុំមានអារម្មណ៍ថាមកដល់ពេលនេះនឹងណាអ៊ុំនឹងមានអារម្មណ៍ថាវាបានសុខស្រួលអ៊ុំមានផ្ទះថ្ម
ហើយមានសរសេរតដ្ឋសំរាប់នឹងចែកកូនចែកចៅដែលមានដំបូងសំរាប់នឹងយកទៅជ្រកគ្រាប់ៗហើយអ៊ុំក៏មិនបានបំផ្លេចគុណដែលអ៊ុំបានសុខស្រួលនឹងណាស់អ៊ុំក៏មិនបាននឹងបំផ្លេចគុណនឹងដែលអ៊ុំមិនបំផ្លេចដូចថាអ្នកដែលគេនឹងបានដឹកនាំប្រទេស ដូចថាជាលោកហ៊ុនសែននឹងជាដើមនឹង!

គឺអ៊ុំមិនបាននឹងបំភ្លេចគុណគាត់នោះទេទោះបីជាគាត់នឹងបាននៅសល់តែ១កៅអីនឹងក៏អ៊ុំនៅតែបោះអោយគាត់ដែរ!! អ៊ុំនិយាយចឹង!ទោះបីជាអូននឹងអូន
ឯងទៅខាងណាខាងនែចឹងខ្ញុំវាមិនបានដឹងនោះទេ!

ក៖ ចាស!

ខ៖
គឺខ្ញុំនឹងបានស្រណុកស្រួលតាំងពីខ្ញុំនឹងបានដឹងក្តីនឹងមកណាគឺថាជីវិតរបស់ខ្ញុំនឹងវាបានស្រណុកស្រួលអីនោះទេ!គឺខ្ញុំនឹងបានតែជួបនឹងសង្គ្រាមនឹងមករហូតកាលនឹងហើយខ្ញុំនឹងបានចោលអារបស់របបរបស់ខ្ញុំនឹងច្រើនណាស់ដែលកាលដែលខ្ញុំនឹងបាននៅឯស្រុកស្វាយរៀងនឹងកាលនឹងខ្ញុំមានតុទូសាឡុងហើយខ្ញុំមានឡាន១ទៀតដែលបានរត់ពីស្វាយរៀងនឹងទៅបរិតហើយពីបរិតនឹងទៅកំពង់លោ!
ដលល់ពេលដែលខ្ញុំនឹងបានឡើងមកភ្នំពេញវិញនឹងហើយព្រោះអីកាលនឹងវាបានដាច់ផ្លូវនឹងមកអស់ហើយចឹងកាលនឹងបានកាច់ផ្លូវពីភ្នំពេញមកឯស្វាយរៀងនឹងចឹងកាលនឹងខ្ញុំបានឡើងយន្តហោះមក!ហើយខ្ញុំបានចូលឡាន ចោលម៉ាស៊ីនដេរខ្ញុំ!
ខ្ញុំមកនៅកវែកកឆ្នាំងនឹងនៅឯភ្នំពេញហើយចឹងបានប្តីរបស់ខ្ញុំនឹងគាត់បានចូលធ្វើជាទាហានអាកាសចរមកនឹងខ្ញុំបានមកទិញបានផ្ទះ១នៅឯអីនៅអឺ....ផ្លូវទៅផ្សារនៅឯវត្តសំរោងអន្ទេងនឹងនៅឯផ្លូវរទេះភ្លើងនឹងកាលនឹងខ្ញុំបានទិញនៅក្នុងតំលៃ៦០០០០ណាកាលជំនាន់នឹងចាស!
ហើយខ្ញុំបានកវែកកឆ្នាំងនឹងទៅកាលនឹងជំនាន់នឹងក៏បានរត់ចោលផ្ទះសំបែងទៅកាលនឹងវាក្រខ្សត់ចឹងទៀតទៅណា!ហើយបានបន្ទាប់មកនឹង!អឺ..មកទល់ដល់សម័យពពតនឹងបានធ្វើបានផ្ទះខ្ទម១ទៀតក៏បានរត់ចោលផ្ទះនឹង១ទៀត!

ក៖ ហឹស....

ខ៖
កាលនឹងបានន័យថាកាលនឹងសេចក្តីទុក្ខ១ជីវិតរបស់ខ្ញុំនឹងខ្ញុំវាមិនដែលបានសុខសប្បាយនោះទេទើបបាន១សម័យឆ្នាំ១៩៧៩នឹងទេដែលខ្ញុំបានមានទាល់ដល់ថ្ងៃនេះចឹងណា!
ទាល់មកដល់សព្វថ្ងៃនឹងបានមកដល់ខ្ញុំនឹងវាបានសុខស្រួល
ហើយចឹងទោះបីជាថាខ្ញុំនឹងបានមានប៉ុន្មានក៏ដោយក៏ខ្ញុំនឹងក៏នៅតែថា
វាបានសុខសន្តិភាពនឹងវាបានទុកឧកាសកើម្បីអោយខ្ញុំនឹងបានចិញ្ចឹមកូននឹងណា។
ហើយទៅដែលថាបានកូនអោយកូនរបស់ខ្ញុំនឹងវាបានមិនភ័យទៅរត់លូនអីនឹងថា!

ក៖ ហឺស!...

ខ៖
កាលនឹងមិនដូចជាកាលមុននឹងខ្ញុំបានរត់វេចក្រវិចនឹងទៅក្នុងព្រៃហើយពីក្នុងព្រៃនឹងមកវិញចឹងទៅណាអូន!ចាស!មកទល់ពេលនឹងចឹងនឹងក៏ខ្ញុំនឹងក៏វាមិនបាននឹងបំភ្លេចគុណនោះដែរ!

ក៖ ហឺ

ខ៖ ដូចថានូវគុណបំណាចដែលបានសុខសប្បាយរាល់តែថ្ងៃនេះ។

ក៖ ហឺស!

ខ៖
រួមទាំងប្ដីរបស់ខ្ញុំដែលគាត់នឹងបានខិតខំតស៊ូកសាង់រួមគ្នាកមកនឹងដើម្បីនឹងរំដោះកម្ពុជាដែលបានរំដោះនៅថ្ងៃទី៧មករានឹងប្ដីរបស់ខ្ញុំ!គាត់បានរួចចំណែកបានកសាងជាតិដែរ!

ក៖ ចាស!

ខ៖
ហេតុដូចនេះហើយនឹងចឹងបានជាបងប្អូននឹងក្រុមគ្រួសាររបស់ខ្ញុំនឹងគេមានរួមចំណែកជួយកសាងជាតិនឹងហើយគេបានរួចនៅក្នុងថ្លៃទី១
៧មករានឹងដែល!ដែលបានរំដោះទឹកដីយើងនឹងទាំងមូលនឹងខ្ញុំសូមអរគុណណាស់!

ក៖ ហឺស!!

ខ៖ ចាស!

គ៖ ចង់សួរចែសអ៊ុំ...

ខ៖ ចាស!

គ៖
ដូចថាពេលនឹងម្ដាយក្មេករបស់ខ្ញុំពេលដែលគាត់នឹងបានយំហើយដោយសារតែការបែកប្ដីនឹងកូន....

ខ៖ ចាស!គាត់នឹងបានត្រហាយំនឹង!

គ៖
ចាសហើយចឹងកាលនឹងគេនឹងយំនឹងអត់បានហើយបើថាពេលដែលយំនឹងគេនឹងអាចយកគាត់នឹងទៅសំលាប់ចោលចឹងទៅណាអ៊ុំ?

ខ៖ ចាស!កាលនឹងយំនឹងអត់បាននោះទេកាលនឹងគេនឹងយកទៅសំលាប់ចាស!អូន!

គ៖
ចុះអ៊ុំកាលនឹងទោះបីជាយើងទោះបីជាយើងនឹងពិកបាកនឹងប៉ុន្មានហើយយើងនឹងចង់យំស្រែនឹងក៏គេមិនអោយដែរ?

ខ៖ នឹងហើយក៏គេមិនអោយយំ
ហើយយើងនឹងវាមិនហ៊ាននឹងនិយាយហើយនិយាយទៅនឹងវាមិនចេញ!

គ៖ ហើយចឹងពេលនឹងដែលពេលដែលអ៊ុំមានទុក្ខលំបាកខ្លាំងចឹងណាអ៊ុំ
ព្រោះអីចឹងនិយាយថាពេលនឹងបើយើងនឹងធ្វើអីនឹងក៏អត់បានចឹងដើម្បីនឹងសំរាយទុក្ខនឹងចឹងចុះអ៊ុំ ចុះពេលដែលអ៊ុំបានការលំបាកនឹងម្តងៗនឹង....

ខ៖ ចាស!

គ៖
តើអ៊ុំនឹងធ្វើអ្វីដើម្បីនឹងអោយវាបានធូនៅក្នុងចិត្តដើម្បីនឹងសំរាយនឹងបន្ធូលអាភាពតានតឹងនឹងខ្លះចឹងទៅណា?

ខ៖
មិនដឹងធ្វើយ៉ាងម៉េចនឹងទេអូនអើយកាលនឹង!ព្រោះអីពេលនឹងបើសិនជាយើងនឹកឃើញឃ្លានអានំគេនឹងបានពូនស្កនឹងចង់ដាច់ពោះនឹងស្លាប់នឹងក៏យើងមិនបានដឹងវាជាយ៉ាងម៉េចនោះដែរ!យើងកាលនឹងស្អីក៏យើងនឹងវាមិនបាននឹងហ៊ាននិយាយនោះដែរកាលនឹងហើយស្អីក៏យើងនឹងមិនហ៊ាននឹងហូបនោះទេហើយកាលនឹងយើងនឹងវាអត់មានអីស្អីដូចជារបស់អីនឹងថាអោយវាបានទីពឹងនៅឯក្នុងខ្លួនរបស់យើងនឹងក៏វាអត់មានទេ!

ក៖ ហឹស!

ខ៖ ចាស!មានតែការហូបបាយនឹងរួមតែប៉ុណ្ណឹងនោះទេ!

ក៖ ហឹស!

គះហឹស!

ខះ
ចាស!យើងកាលនឹងគេមិនអោយយើងមានអីនោះទេកាលនឹងគេបានអោយយើងនឹងអត់មាន
អ្នកក្រនឹងអ្នកមាននោះទេ!

កះ ចាស!

ខះ ចាស!និយាយទៅនឹងវាបានប៉ុណ្ណឹង!

កះ ចាសអ៊ុំ!ចឹងតាមរយៈជីវិតរបស់ខ្ញុំដែរអ៊ុំបានឆ្លងកាត់បទពិសោធន៍ច្រើនចឹង .....

ខះ ច្រើនជាន់ណាស់!

កះ
តើអ៊ុំចាស!តើអ៊ុំមានបទពិសោធន៍ល្អអ្វីគេខ្លះដែរក្នុងជីវិតរបស់អ៊ុំដែរបានធ្វើអោយអ៊ុំនឹកឃើញ
ហើយសប្បាយចិត្ត?

ខះ
ចាស!...មកដល់ពេលឥឡូវនឹងខ្ញុំមានរឿងដែលបានធ្វើអោយខ្ញុំនឹងបានសប្បាយចិត្តនឹងវាបាន
សប្បាយចិត្តនឹងយ៉ាងបែបយ៉ាងម៉េចចាស!(គាត់បានប្រាប់ចៅគាត់នៅជិតនឹងកំពុងតែលេង
ហើយគាត់ថាអោយថាណោស!!!)ចឹងសប្បាយចិត្តនឹងយ៉ាងម៉េចគឺថាកូនរបស់ខ្ញុំនឹងគេបានរៀន
ចេះដឹង ហើយគេបានមានការងារនឹងគ្រាប់ៗគ្នា!

កះ ហឹស...

ខះ
ហើយចាស!ខ្ញុំក៏ដូចថាវាការនឹងវាបានការកូននឹងបានបំពេញកាព្វកិច្ចជាឪពុកម្ដាយនឹងបានរួច
រាល់ហើយចឹងនឹងណាចាស!ចឹងពេលដែលកូនៗនឹងវាបានការនឹងរួចអស់ហើយចឹងនេះហើ
យដែលជាការសប្បាយចិត្តរបស់ខ្ញុំ!ចាស!មកទល់ដល់ថ្ងៃនេះចឹងគឺខ្ញុំនឹងបានសប្បាយចិត្តបាន
មើលឃើញកូនខ្ញុំនឹងមានការងារមានកូនមានផ្ទះសំបែងអីនឹងមានការងារមានកូនបានគ្រាប់ៗ
គ្នានឹងចឹងអស់ហើយចឹងនឹងចាស!

(សំលេងចៅគាត់កំពុងតែយំនៅជិតនឹង)

កៈ ចាស!ចុះចំណែកឯបទពិសោធន៍
អីអត់ល្អវិញដែលដូចជារឿងកន្លងៗមកនឹងដែលវាបានកើតឡើងហើយវាបានធ្វើអោយអ៊ីនឹងបានចង់ចាំហើយនឹងបាននឹងចង់ចាំវាមកដល់សព្វថ្ងៃនឹងដែលបានធ្វើអោយអ៊ីនឹកវាមិនអាចនឹងបំភ្លេចបានសោះឡើយនឹងមានតែឬទេអ៊ី?

ខៈ ខ្ញុំ!ការចង់ចាំរបស់ខ្ញុំនឹងាមានតែការចង់ចាំការរឿងពីក្នុងសម័យពពត!

គៈ ហឺស!

ខៈ
ដែលថាបានធ្វើបាបខ្ញុំហើយបានធ្វើបានបងរបស់ខ្ញុំនឹងណាដែលថាអោយគាត់នឹង...ពេលនឹងបងរបស់ខ្ញុំនឹងគាត់គឺជាគ្រូបង្រៀនសាស្រ្តចារ្យបន្ទាប់មកបងខ្ញុំនឹងទី២នឹងឈ្មោះម៉ាសុទៈរីនឹងគាត់បានរៀនចប់!គាត់បានរៀនចប់ថ្នាក់បញ្ចប់នឹង
ហើយកាលសម័យពីដើមនឹងវិញគេបានហៅថា ខ្លះទៃលមីណាល!ណា!នឹងថ្នាក់ទីបញ្ចប់
ហើយរបស់ខ្ញុំនឹងគាត់បានរៀនចប់ហើយចេះដឹងហើយកាលនឹងណា!តែគេនឹងបានយកគាត់ទៅវៃចោលអស់!

កៈ ហឺស!

គៈ ហឺស!

ខៈ ចាស!នៅសល់តែបងស្រី!

កៈ ហឺ

ខៈ
បងស្រី៥នាក់នឹងនៅដល់សព្វថ្ងៃមិនទាន់ស្លាប់នោះទេតែពួកគាត់ចាស់ៗអស់ទៅហើយ!បងខ្ញុំនឹងគាត់បានតេមកខ្ញុំដែលគាត់បានកំពង់តែឈឺនៅឯខេត្តស្វាយរៀងឯនោះចាស!ហើយឥឡូវនឹងនៅមានបងស្រីខ្ញុំនឹង ឈ្មោះម៉ាធម៍នឹងម៉ា ធាននឹងហើយនឹងខ្ញុំម៉ាធៀងនឹងហើយមានម៉ាសុន នឹងម៉ាសៀងនឹងនៅទាំងអស់គ្នានឹង៥នាក់នឹងចាស!

គៈ ចុះកាលនឹងមានប៉ុន្មាននាក់ដែលគេបានសំលាប់ចោលអ៊ី?

ខៈ ចាស!កាលនឹងមានប៉ុន្មានមើលកាលនឹងខ្ញុំវាមានអាយុ២០
២០ជាងកាលនឹងវាបាន២៥ទៅ២៦អីនឹងហើយដល់ចឹងទៅបងខ្ញុំនឹងគាត់បានបងខ្ញុំនឹង១ជួននឹ

ងណាព្រោះអីគាត់បានបងខ្ញុំនឹងគាត់កើតនៅឆ្នាំថោះ
ហើយខ្ញុំនឹងគាត់កើតនៅក្នុងឆ្នាំខាល!បងរបស់ខ្ញុំនឹងគេបានយកទៅសំលាប់ចោលនឹងអស់ទៅ
!

(មានសំលេងថៅៗគាត់យំនៅជិតនឹង)

គ៖ ហើយកាលនឹងគេបានសំលាប់បងរបស់អ៊ុំនឹងប៉ុន្មាននាក់ទៅ?

ខ៖ តែ២នាក់នឹង!

គ៖ តែ២នាក់ទេ!អ៊ុំ!

ខ៖ ចាស!

(មានលឺសំលេងថៅគាត់កំពុងតែយំនៅជិតនឹងហែសៗៗៗ!!)

ក៖ ចាសអ៊ុំចឹងអ៊ុំមានពាក្យអ្វីជាចុងក្រោយដើម្បីនឹងនិយាយ
ដើម្បីនឹងបណ្ដែរបណ្ដាំទៅដល់កូនចៅអ៊ុំនឹងកូនចៅជំនាន់ក្រោយនឹងមកទៀត?

(មានសំលេងថៅគាត់យំខ្លាំងៗនៅជិតនឹង)

ខ៖ ចង់សួរថាយ៉ាងម៉េចគេខ្លះ?

ក៖
អឺ..អ៊ុំជាចុងក្រោយនៃការសំភាសន៍ខ្ញុំចង់សួរអ៊ុំនូវពាក្យដែលអ៊ុំចង់និយាយជាចុងក្រោយដែល
សំរាប់បផ្ដែរបផ្ដាំងដល់កូនចៅជំនាន់ចៅជំនាន់ក្រោយទៀតនឹងដែលគេបានស្លាប់សំលេងរប
ស់ផ្ទាល់នៅថ្ងៃនេះចឹងណា!តើអ៊ុំមានពាក្យអ្វីដើម្បីនឹងបផ្ដែបផ្ដាំទៅដល់ពួកគាត់នឹង?

ខ៖
ចាស!ខ្ញុំនឹងសូមផ្ដែផ្ដាំនឹងទៅជាចុងក្រោយនឹងដែលបានដឹងពីជីវៈប្រវិត្តនឹងការតស៊ូដល់លំបា
ករបស់ខ្ញុំនៅក្នុងសម័យពពតហើយចឹងមកដល់សម័យនេះខ្ញុំនឹងបានសុខស្រួលហើយ!ចាស!
ទោះបីយ៉ាងម៉េចក៏ដោយយើងខំប្រឹងប្រែងខិតខំតស៊ូការពារប្រទេសជាតិយើងអោយបានរុង
រឿងទៅថ្ងៃខាងមុននឹងណាអូន!

ក៖ ចាស!

ខ៖
ចាស!កូនរបស់ខ្ញុំនឹងគេសុទ្ធតែជាអ្នកធ្វើការងារទាំងអស់!សុទ្ធតែជាទងទាំងស្រីនឹងទាំងប្រុស!

ក៖ ល្អមែនទែនអ៊ុំ!

ខ៖ ចាស!ទាំងស្រីនឹងទាំងប្រុស!

ក៖ ចាសចឹងអរគុណអ៊ុំ!.....

ខ៖
ចាសពូជរបស់ខ្ញុំនឹងសុទ្ធជាពូជជាទាហានចាស!(មានសំលេងថៅៗគាត់នៅជិតនិយាយគ្នាលេងជិននឹង)

ក៖
ចាស!ចឹងអរគុណអ៊ុំច្រើនសំរាប់នឹងថ្ងៃនឹងដែលបានចំណាយពេលសំរាប់នៅក្នុងការសំភាសន៍!

ខ៖
ចាស!ខ្ញុំនឹងក៏សូមអរគុណដែលព្រោះអីខ្ញុំនឹងក៏ចង់ថ្លែងពីរឿងដ៏កំសត់របស់ខ្ញុំនឹងប្រាប់ទៅដល់...ដូចថាមហាជននឹងប្រាប់អោយគេបានដឹងជ្រៀបអំពីសេចក្ដីទុក្ខលំបាករបស់ខ្ញុំនឹងកាលនពីសម័យពពត!
មកទល់សព្វថ្ងៃនេះនឹងខ្ញុំមិនដែលបាននឹងគិតថាខ្ញុំនឹងបានសំនឹងមានជីវិតបានរស់រានមកដល់សព្វថ្ងៃនឹងនេះទេព្រោះអីរូបខ្ញុំនឹងគឺជាបានត្រៀមយកទៅសំរាប់ចោលនឹងឆ្ពោះទៅនឹងសំលាប់នឹង២ដងហើយចាស!ទី១នឹងខ្ញុំនៅអឺ....កន្លែងកំបែកនឹងគេបានត្រូវយកខ្ញុំនឹងទៅសំលាប់ចោលអាអឺ..អា១ទូកៗនឹងណា!!ហើយទី២គឺគេយកខ្ញុំនឹងទៅសំលាប់ចោលនៅឯក្នុងព្រៃតែវាជាសំណាងល្អរបស់ខ្ញុំនឹងហើយដែលខ្ញុំបានរត់មករស់នៅ
ជួបជុំដល់ក្រុមគ្រួសារវិញ!ចាស!ខ្ញុំសូមថ្លែងអំណគុណដល់ជ្រៀលជ្រៅដែលក្មេងបានមកសំភាសន៍ខ្ញុំនឹង! ហើយចំខ្ញុំនឹងដែរនឹងចង់និយាយហោសៗៗ!
!(មានសំលេងថៅៗគាត់នៅជិតនិយាយគ្នាលេងជិននឹង)

ក៖ចាស!អ៊ុំអរគុណច្រើន!

គ៖ ចាសអ៊ុំ!

(មានសំលេងថៅៗគាត់នៅជិតនិយាយគ្នាលេងជិននឹង)

ខ៖ ហេសៗៗចង់ថ្លែងនឹងកាលពីសម័យពីដើមនឹងគឺវាបានលំបាកនោះលំបាកហើយណា!

ក៖ ចាសអរគុណច្រើនអ៊ុំ!

ខ៖ ចាស!